ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១១៨/ គ.ជ.ប.ជ
/២១

# របាយការណ៍ឆមាសទី១ ឆ្នាំ២០២១
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆមាសទី២ ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

ក្នុងឆមាសទី១ ឆ្នាំ២០២១នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួងស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួនជួបគ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ ១៩ និងមេរោគបម្លែងថ្មី ។

ព្រឹត្តិការណ៍ ២០កុម្ភៈ ឆ្នាំ២០២១ បានធ្វើឲ្យរបៀបរបបការងារ ត្រូវផ្លាស់ប្តូរតាមគន្លងថ្មី ។

ស្ថានភាពប្រែប្រួល ចាប់ផ្តើមពីខែមករា ឆ្នាំ២០២១ ដែលធ្វើឱ្យក្រសួងស្ថាប័ន និងរាជធានី ខេត្ត ត្រូវប្តូរទិសដៅ និងរបៀបរបបការងារ ឱ្យផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ ១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស អ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួន ច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ដើម្បីបង្ការទប់ស្កាត់ការនាំចូលជំងឺកូវីដ ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់សកម្មភាពមេខ្យល់ក្នុងការចលនាអូសទាញឱ្យពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលកំពុងតែមានការរឹតបន្តឹងពីប្រទេសគោលដៅដើម្បីការពារជម្ងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក បែងចែកការទទួលខុសត្រូវ ឱ្យនៅប្រចាំការនៅតាមព្រំដែន ដើម្បីទទួល និងសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ ការរៀបចំទីតាំងសម្រាប់ការធ្វើចត្តាឡីស័ក ការតាមដានអ្នកដែលមានផ្ទុកមេរោគកូវីដ ១៩ និងការផ្តល់សេវាសុខភាព ការអនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូនឱ្យបានដល់លំនៅដ្ឋាន និងបន្តតាម

ដានស្ថានភាពសុខភាព ជីវភាព ព្រមទាំងផ្ដល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាពសុខភាព និងជីវភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅ ក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្ដល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិកគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងបង្កើន កិច្ចប្រតិបត្តិការក្នុងគោលដៅដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ បាន៖
  - បន្តពិនិត្យសេចក្ដីព្រាងច្បាប់ ស្ដីពី ការប្រឆាំងអំពើរត់ពន្ធមនុស្ស និងច្បាប់ស្ដីពី អំពើពពោះជំនួស។
  - រៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសបារាំង ស្ដីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌ។
  - រៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសប៉េរូ ស្ដីពី ការផ្ទេរទណ្ឌិត។
  - រៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ ស្ដីពី ការផ្ទេរទណ្ឌិត។
  - រៀបចំសេចក្ដីព្រាងសន្ធិសញ្ញាស្ដីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឥណ្ឌា។

#### ក.២. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ បានចុះអនុស្សរណៈយោគយល់គ្នា រវាងអង្គការវើលអនលូស(We World Onlus)ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយនិងប្រធានអង្គការវើលអនលូស នៅប្រទេសកម្ពុជា។

#### ក.៣. បទដ្ឋានគតិយុត្ត

- ក្រសួងមហាផ្ទៃ បានចេញសេចក្ដីជូនដំណឹងទៅអភិបាលខេត្តជាប់ព្រំដែន លេខ១៣៩៦ សជណ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២០ ស្ដីពី «ការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរកុំឱ្យឆ្លងដែនដោយខុសច្បាប់ចូលទៅប្រទេសជិតខាងតាមច្រករបៀងនានា» និងវិធានការជាបន្តបន្ទាប់ ដើម្បីពង្រឹងការគ្រប់គ្រងច្រកព្រំដែន និងដាក់បញ្ហាទៅថ្នាក់ក្រោមជាតិ ក្នុងការតាមដាន ស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ដែលព្យាយាមនាំពលករចេញទៅប្រទេសថៃ ក្នុងដំណាក់កាលរឹតបន្តឹង។
- ក្រសួងយុត្តិធម៌ បាន៖
  - ចេញសេចក្ដីសម្រេច លេខ០៨ កយ.សសរ/២០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ស្ដីពីការបង្កើត គណៈកម្មាការដឹកនាំយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង នៅតាមសាលាដំបូងរាជធានី ខេត្ត។ ព្រោះស៊ុ

- ចេញសេចក្តីសម្រេច លេខ២០ កយ.សសរ/២០ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការបែងចែក ភារកិច្ច របស់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ ដែលក្នុងនោះមាន រដ្ឋលេខាធិការមួយរូប (ឯកឧត្តម **កេង សុម៉ារិទ្ធ**) ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖
  - ចេញសេចក្តីអំពាវនាវចំពោះបងប្អូនពលករកម្ពុជា ដែលកំណពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របស់គណៈកម្មាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។
  - ចេញសេចក្តីជូនដំណឹងលេខ ០០៦/២១ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការពិន័យចំពោះបងប្អូនពលករកម្ពុជា ដែលគេចវេះមិនបានធ្វើចត្តឡីស័កត្រឹមត្រូវតាមវិធានការ សុខាភិបាល របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
  - សហការជាមួយក្រសួងកិច្ចការនារី បង្កើតគណៈកម្មការប្រឹក្សាយោបល់ ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៃកម្មវិធីពលករក្នុងតំបន់អាស៊ាន តាមរយៈប្រកាសអន្តរក្រសួងលេខ ០៨៦/២១ ក.ប/ប្រ.ក.ម.ហ ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១។

- **ក្រសួងអប់រំ យុវជននិងកីឡា** បាន៖
  - អនុម័តគោលនយោបាយជាតិ ស្តីពីសុខភាពសិក្សា និងក្រុមការងារអន្តរវិស័យសុខភាពសិក្សា ព្រមទាំងក្រុមលេខាធិការដ្ឋានសុខភាពសិក្សា។
  - អនុម័តគោលនយោបាយ ស្តីពីកិច្ចការពារកុមារពីអំពើហិង្សាគ្រប់ទម្រង់ ទាំងក្នុង និងក្រៅសាលារៀន។
  - ចេញសេចក្តីសម្រេច លេខ០១ អយក.សសរ ចុះថ្ងៃទី៣ មករា ២០២០ ស្តីពីការបង្កើតក្រុមការងារចងក្រងសៀវភៅសិក្សា និងជំនួយវិធីសាស្ត្របង្រៀន ពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ។
  - ចេញសេចក្តីណែនាំ ស្តីពីការសម្របសម្រួលចេញលិខិតបញ្ជាក់ការសិក្សា និងការចូលរៀន សម្រាប់សិស្សទេសន្តរប្រវេសន៍ និងសិស្សដែលមាតាបិតាធ្វើមាតុភូមិនិវត្តន៍ពីចំណាកស្រុក។
  - ចេញសេចក្តីសម្រេច លេខ ០៣២/២០សសរ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សអន្តរនាយកដ្ឋាន។

- **ក្រសួងកិច្ចការនារី** បានរៀបចំ៖
  - សេចក្តីព្រាងវិសោធនកម្មអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (COMMIT)។
  - សេចក្តីព្រាងយន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដាររួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោលរបស់ប្រទេសជាសមាជិកខមមីតនីមួយៗ។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បាន៖
  - ធ្វើសេចក្តីព្រាងអនុក្រឹត្យ «ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះ ស្នាក់នៅក្នុងមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍ ដែលរងគ្រោះដោយការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត» ។
  - ប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការ "នីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ(SOP)"។
  - កែសម្រួលគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

▪ **ក្រសួងសុខាភិបាល បាន៖**

- សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមានការគាំទ្រពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) បានរៀបចំ និងពិនិត្យសម្រេច "គោលនយោបាយជាតិស្តីពីសុខភាពជនទេសន្តរប្រវេសន៍" និងត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅខែមីនា ឆ្នាំ២០២១។ គោលនយោបាយនេះ បានផ្តោតការយកចិត្តទុកដាក់លើកញ្ចប់សេវាសុខាភិបាល សម្រាប់ជនទេសន្តរប្រវេសន៍មានជាអាទិ៍ ការផ្តល់សេវាសុខភាព ការពិនិត្យវាយតម្លៃសុខភាព ជំងឺឆ្លង ជំងឺមិនឆ្លង សុខភាពមាតានិងទារក សុខភាពបន្តពូជ សេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន ការលើកកម្ពស់ និងអប់រំសុខភាពមុន និងពេលធ្វើទេសន្តរប្រវេសន៍ ទៅប្រទេសគោលដៅ និងក្រោយពេលត្រឡប់មកវិញ។

## ក.៤. ការពង្រឹងកិច្ចសហប្រតិបត្តិការ

▪ **គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាន៖**

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ កម្រិតថ្នាក់ដឹកនាំ ដើម្បីសម្រេចជ្រើសរើសគោលបំណងអាទិភាព និងសូចនាករសម្រាប់អភិបាលកិច្ចទេសន្តរប្រវេសន៍(Migration Governance Indicators) ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពី «ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់» ។
- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ ០២លើក ស្តីពី "វឌ្ឍនភាព នៃការអនុវត្តអនុសាសន៍ប្រចាំឆ្នាំ របស់សហរដ្ឋអាមេរិក លើកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា" រវាងមន្ត្រីជាន់ខ្ពស់ក្រសួងពាក់ព័ន្ធជាមួយឯកឧត្តមអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាព សហរដ្ឋអាមេរិក និងគណៈប្រតិភូអមស្ថានទូត និងបានជួបពិភាក្សាជាមួយ មន្ត្រីជំនាញជាច្រើនលើក។
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ០២លើក រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ រហូតឈានដល់ការរៀបចំ និងអនុវត្តគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាលនៃការរាតត្បាតដោយជំងឺកូវីដ ១៩ នៅក្នុងខេត្តបាត់ដំបង សៀមរាប បន្ទាយមានជ័យ ក្រោមមូលនិធិ MPTF របស់អង្គការសហប្រជាជាតិ។
- ពិភាក្សាពិគ្រោះយោបល់ជាមួយ រាជធានី ខេត្ត អង្គការដៃគូជាតិ និងអន្តរជាតិជាច្រើនលើក ដើម្បីរកគន្លឹះដោះស្រាយបញ្ហាប្រឈម បន្ថែមលើគោលនយោបាយជាតិសម្រាប់ប្រជាពលរដ្ឋនៅក្នុងប្រទេស ចំពោះការវិលត្រឡប់របស់ពលករដ៏ច្រើន មិនតាមច្រកផ្លូវការ និងបន្តចូលដោយគ្មានពេលវេលា និងចំនួនកំណត់ ហើយប្រឈមនឹងស្ថានភាពសុខភាព និងជីវភាពយ៉ាងធ្ងន់ធ្ងរ។

▪ **ក្រសួងទេសចរណ៍** បានរៀបចំ និងត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

- បានបន្តពិភាក្សាការងារ ជាមួយក្រសួងការងារថៃ តាមប្រព័ន្ធអនឡាញ ដើម្បីរកគន្លឹះដោះស្រាយភាពប្រឈមរបស់ពលករទេសន្តរប្រវេសន៍ ដែលកំពុងស្ថិតនៅក្នុងប្រទេសថៃ ក្នុងស្ថានភាពតឹងបន្តឹង និងប្រឈមនឹងការរាតត្បាតនៃជំងឺកូវីដ ១៩។
- ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី៦ នៃប្រទេស CLMTV (កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម) ដើម្បីត្រៀមរៀបចំ សេចក្តីព្រាងសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការងារស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ ពលករទេសន្តរប្រវេសន៍នៃប្រទេស CLMTV ដែលនឹងប្រព្រឹត្តនៅឆ្នាំ ២០២១។

▪ **ក្រសួងកិច្ចការនារី** បានបន្តពិភាក្សាការអនុវត្តផែនការសកម្មភាពមហាអនុតំបន់មេគង្គ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស លើកទី៤ សម្រាប់ឆ្នាំ២០២០-២០២២(SPA-IV 2015-2018) ត្រូវបានបន្តសុពលភាពអនុវត្តលើកទី១ ឆ្នាំ២០១៨-២០២០) និងត្រៀមរៀបចំផែនការសកម្មភាពនេះ លើកទី៥

(SPA-V) ដែលត្រូវបញ្ចូលនិន្នាការថ្មីនៃអំពើជួញដូរមនុស្ស ព្រមទាំងមានការចូលរួមពីអង្គការសង្គមស៊ីវិល និងបណ្ដាញយុវជន។

- ក្រសួងអប់រំ យុវជន និងកីឡា៖
  - បានទទួលកិច្ចសហប្រតិបត្តិការក្នុងការបោះពុម្ពលើកទី១ សៀវភៅសិក្សា ស្ដីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន សម្រាប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ ពីអង្គការ A21 និង CWCC ។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ:

| | ការផ្សព្វផ្សាយដោយផ្ទាល់ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | កិច្ចប្រជុំផ្សព្វផ្សាយ និងវេទិកាសាធារណៈ: ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព | ៥៦.៤៣១ លើក | ២.២៨១.០២១ នាក់ | ១.១៥១.៧៤៦ នាក់ |
| ២ | កម្មវិធីផ្សេងៗ | ០១ លើក | ២៥០ នាក់ | |
| ៣ | អង្គការដៃគូ | ១៥ លើក | ៣.១២៣ នាក់ | ១.៥២៤ នាក់ |
| | សរុប | ៥៦.៤៤៧ លើក | ២.២៨៤.៣៩៤ នាក់ | ១.១៥៣.២៧០ នាក់ |

#### ខ.១.២. ការអប់រំផ្សព្វផ្សាយដោយផ្ទាល់

នៅក្នុងឆមាសទី១ ឆ្នាំ២០២១ នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៥៦.៤៤៧លើក មានអ្នកចូលរួមសរុបចំនួន ២.២៨៤.៣៩៤នាក់(បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២០ មានចំនួន ២.៥៤០.៨២៥នាក់ គឺមានការថយចុះចំនួន ២៥៦.៤៣១នាក់ ស្មើនឹង ១០,០៩%) ក្នុងនោះស្ត្រីចំនួន ១.១៥៣.២៧០នាក់ដូចមានតារាងលម្អិតខាងក្រោម៖

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៨៥២ | ៦២.៣៩៣ | ៣៦.៩៧៩ | ៨៦៥ | ៤៥.៨០៩ | ២៣.៦៤៧ |
| | សរុប ក្រសួង ស្ថាប័ន | ៨៥២ លើក | ៦២.៣៩៣ នាក់ | ៣៦.៩៧៩ នាក់ | ៨៦៥ លើក | ៤៥.៨០៩ នាក់ | ២៣.៦៤៧ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 |
| ២ | ខេត្តកណ្ដាល | ៣.០៤១ | ១០១.៧៩៨ | ៥២.៣៥០ | ៣.៩៦៣ | ២២០.៥០៥ | ១០៣.១៤៧ |
| ៣ | ខេត្តបាត់ដំបង | ២.៦៦២ | ៧៨.៣០២ | ៤២.៧៦២ | ១.៧០១ | ៣៤.៥៦៣ | ២៣.៧៨០ |
| ៤ | ខេត្តពោធិ៍សាត់ | ២.៥៧៦ | ១២១.៩១៤ | ៥៨.៦៩៤ | ៦៥១ | ២៩.២៣៨ | ១៣.០៦០ |
| ៥ | ខេត្តសៀមរាប | ១.៦៤១ | ៦៣.០៣០ | ៣៨.១៨៩ | ៤៤៨ | ១២.៧៧៦ | ៧.០៦២ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧.៧៨០ | ១៩០.៤៥១ | ៨១.១៨០ | ៤.៤៤៣ | ១២០.៧៣៨ | ៥៣.៤៦១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | ខេត្តកំពង់ចាម | ១៣.៥៤៣ | ៦៣៦.១៩៦ | ៣៦០.៥៤៩ | ៨.២៧៦ | ៤០១.៧៩៧ | ១៧៧.៣៩៨ |
| ៨ | ខេត្តព្រះសីហនុ | ៥ | ១៩៣ | ១០១ | ០ | ០ | ០ |
| ៩ | ខេត្តព្រះវិហារ | ៧ | ២២៨ | ៩០ | ០ | ០ | ០ |
| ១០ | ខេត្តស្វាយរៀង | ១.២២៨ | ៣៧.៤៦០ | ២០.៨៥៩ | ៥៧៩ | ១៧.៥១៥ | ៩.៧២៣ |
| ១១ | ខេត្តប៉ៃលិន | ១៨២ | ៣.០០៨ | ១.១០៦ | ៧១ | ២.៣៨៤ | ៩៧៦ |
| ១២ | ខេត្តកោះកុង | ០ | ០ | ០ | ២២០ | ៤.៣០៩ | ២.២១៣ |
| ១៣ | ខេត្តកំពត | ១៩៤ | ៣.៨៤៤ | ១.៨៦៥ | ៥៤ | ១.២៦៦ | ៨២០ |
| ១៤ | ខេត្តកំពង់ធំ | ០ | ០ | ០ | ០ | ០ | ០ |
| ១៥ | ខេត្តតាកែវ | ៦៨៦ | ៣១.០៣៦ | ១៣.៨៣១ | ១៦០ | ៥.៥៤៨ | ២.៥៤៧ |
| ១៦ | ខេត្តក្រចេះ | ១៦១ | ១៣.២២៦ | ៦.៩២១ | ០ | ០ | ០ |
| ១៧ | ខេត្តកែប | ៧៨ | ១៥.២៨៦ | ៥.១៥១ | ៨ | ៣០៨ | ១៣២ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៣១៣ | ១៣.៧៩៨ | ៦.៩៧០ | ៥ | ៣០៧ | ៩៦ |
| ១៩ | ខេត្តស្ទឹងត្រែង | ០ | ០ | ០ | ០ | ០ | ០ |
| ២០ | ខេត្តរតនគិរី | ០ | ០ | ០ | ០ | ០ | ០ |
| ២១ | ខេត្តព្រៃវែង | ០ | ០ | ០ | ០ | ០ | ០ |
| ២២ | ខេត្តត្បូងឃ្មុំ | ១៣ | ៤.៦៣៥ | ២.៦៨៥ | ០ | ០ | ០ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៩ | ១.៩០១ | ៣០១ | ៤ | ៩៤៨ | ២៥៧ |
| ២៤ | ខេត្តឧត្តរមានជ័យ | ១០ | ៤.២៣០ | ២.៧៩៤ | ០ | ០ | ០ |
| ២៥ | ខេត្តមណ្ឌលគិរី | ២ | ៨១ | ៥០ | ០ | ០ | ០ |
| សរុប រាជធានី-ខេត្ត | | ៣៤.១៣១ | ១.៣២០.៦១៧ | ៦៩៦.៤៤៨ | ២០.៥៨៣ | ៨៥២.២០២ | ៣៩៤.៦៧២ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៥៦.៤៣១ លើក | | ចំនួនមនុស្សសរុប ២.២៨១.០២១ នាក់ | | ចំនួនស្ត្រី ១.១៥១.៧៤៦ នាក់ | |

### ខ.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ APLE បើកកម្មវិធីយុទ្ធនាការ ស្តីពីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាស្ថានជាតិអប់រំ អ្នកចូលរួមមាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ សរុបប្រមាណ ២៥០នាក់។

- **អង្គការដៃគូ**

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំនានា របស់អង្គការដៃគូ*

| អង្គការ | សកម្មភាព | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្រី |
|---|---|---|---|---|
| សាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ) | ផ្សព្វផ្សាយ អប់រំ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ពលករ | ០១ | ២.៥៥៧ | ១.២០៨ |
| តំណក់ទឹក គ្រួសារថ្មី និងភឿន (ខេត្តបន្ទាយមានជ័យ) | ចែកលេខទូរស័ព្ទមជ្ឈមណ្ឌលព័ត៌មានចំណាកស្រុកដោយសុវត្ថិភាព និងផ្សព្វផ្សាយដល់ពលករត្រឡប់មកពីប្រទេសថៃ និងប្រទេសម៉ាឡេស៊ី | ០១ | ១៨៤ | ៨១ |

| | | | | |
|---|---|---|---|---|
| APLE (ខេត្តសៀមរាប) | ផ្សព្វផ្សាយ អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាន ដល់ក្រុមគោលដៅយុវជន និងកុមារនៅក្នុងអង្គការដៃគូ | ០២ | ២៣ | ១៤ |
| មូលនិធីអេ២១ (ខេត្តសៀមរាប) | ផ្សព្វផ្សាយអំពីសិទ្ធិកុមារ និងអំពើជួញដូរមនុស្ស ដល់កុមារតាមដងផ្លូវ និងសហគមន៍ | ០៨ | ៣១០ | ១៩៥ |
| ILO, ការីតាស់ (ខេត្តបាត់ដំបង) | ផ្សព្វផ្សាយស្តីពី ចំណាកស្រុកប្រកបដោយសុវត្ថិភាព និងឱកាសការងារក្នុងស្រុក នៅស្រុកភ្នំស្រុក និងស្រុកសំឡូត។ | ០២ | ៣៨ | ១៦ |
| បន្ទាយស្រី (ខេត្តសៀមរាប) | រៀបចំវេទិកាកុមារស្តីពី ការទទួលបានការអប់រំសម្រាប់កុមារដែលធ្វើចំណាកស្រុក | ០១ | ១១ | ១០ |
| សរុប | | ១៥ លើក | ៣.១២៣ នាក់ | ១.៥២៤ នាក់ |

### ខ.១.៤. ការផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សព្វផ្សាយ (IEC)

- **ថ្នាក់ជាតិ៖**
  - **ក្រសួងអប់រំ យុវជន និងកីឡា** បានសហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានជំនួយឧបត្ថម្ភថវិកាពីអង្គការ Caritas, A21, SOLIDAR និងអង្គការ CWCC បានធ្វើការបោះពុម្ពសៀវភៅអប់រំ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន ចំនួន **៦.០០០ក្បាល** សម្រាប់ការបង្រៀនសាកល្បង។ សៀវភៅសិក្សានោះបានរៀបចំចងក្រងដូចជា៖ ១-ផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីកិច្ចការពារកុមារ។ ២.ស្តីពីសុខភាពសិក្សា។ ៣.ផ្សព្វផ្សាយពីគោលការណ៍អប់រំពីចម្ងាយ។ ៤.ផ្សព្វផ្សាយសៀវភៅសិក្សា ស្តីពីការអប់រំ បង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ៥.បានអនុវត្តវគ្គ បណ្តុះបណ្តាលមន្ត្រីអប់រំគ្រូឧទ្ទេស គណៈនាយក គ្រូបង្រៀន ស្តីពីការប្រើប្រាស់សៀវភៅ ២.១.៤។ ៦-បានជំរុញការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមរយៈការប្រតិបត្តិកម្មវិធីសិក្សាពីចម្ងាយតាមរូបភាពបណ្តុំសិក្សាតាមភូមិ ដែលគ្រូបង្រៀនអាចក្តាប់បានពីទំនោរគ្រួសារសិស្ស។ ៧-បានចូលរួមក្នុងនាមជាក្រុមការងារថ្នាក់ជាតិ ក្នុងកិច្ចការរៀបចំផែនការជាតិទប់ស្កាត់អំពើហិង្សាលើកុមារ ក្មេងស្រី និងស្ត្រី។
  - **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយ៖**
    - អង្គការសាម៉ារីតាន់ភីស អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការកឿន(ថៃ) អង្គការអន្តរជាតិទេសន្តរប្រវេសន៍អន្តរជាតិ(IOM) អង្គការក្តីស្រឡាញ់គ្មានព្រំដែន និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការប្រឹក្សាយោបល់អំពីរបៀបក្លាយខ្លួនជាពលករស្របច្បាប់ និងការធ្វើតេស្តកេមេរោគកូវីដ១៩ ជូនដល់ពលករ ចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃ និងម៉ាឡេស៊ី។
  - **ក្រសួងកិច្ចការនារី៖** បានសហការជាមួយអង្គការសហប្រជាជាតិ តាមរយៈកម្មវិធីសុវត្ថិភាព និងយុត្តិធម៌សម្រាប់ស្ត្រីពលករទេសន្តរប្រវេសន៍ បានសម្រេចនូវសកម្មភាពមួយចំនួនដូចជា៖
    - ផលិតផ្ទាំងរូបភាព ដែលមានភ្ជាប់នូវសារចំនួន ៨ សម្រាប់ផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម Facebook របស់ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី ក្នុងគោលបំណងចូលរួមទប់ស្កាត់អំពើហិង្សា ការរើសអើងលើស្ត្រីពលករចំណាកស្រុក ការផ្តល់សេវាគាំទ្រនានា និងការផ្តល់ពត៌មានអំពីប្រព័ន្ធទំនាក់ទំនងដែលអាចជួយដល់ស្ត្រី និងក្មេងស្រីរងគ្រោះបាន។
    - ផលិតខិត្តប័ណ្ណសម្រាប់ផ្តល់ពត៌មានអំពីលេខទូរស័ព្ទក្នុងការទំនាក់ទំនង ដែលអាចរាយការណ៍សុំកិច្ចអន្តរាគមន៍ក្នុងករណីបានឃើញ ឬបានជួបប្រទះអំពើហិង្សា អំពើជួញដូរស្ត្រី ឬការរំលោភបំពានលើស្ត្រីពលករចំណាកស្រុក ដែលនឹងធ្វើការផ្តល់ជូនទៅថ្នាក់ក្រោមជាតិ។

▪ **អង្គការដៃគូ៖**

- **អង្គការIOM (ខេត្តបន្ទាយមានជ័យ)** ផ្តល់សៀវភៅចំណាកស្រុកដោយសុវត្ថិភាពជូនពលករ ចំនួន ១៨៤ក្បាល និងខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ១៨៤ច្បាប់។
- **អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង)** បោះពុម្ពចែកចាយខិត្តប័ណ្ណផ្សព្វផ្សាយ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ៤.៧៩៣ច្បាប់។ និងបានចែកជូនដល់ពលករចំណាកស្រុកដែលវិលត្រឡប់ពីប្រទេសថៃវិញចំនួន ២.៣៥៧នាក់(ស្រី ៤៥៣នាក់ កុមារ ១៨២នាក់)។

**ខ.១.៥. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក**

• **ថ្នាក់ជាតិ៖**

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៤១.០៥៦កន្លែង និងវគ្គអប់រំបណ្តុះបណ្តាលនិងអាហារូបករណ៍ចំនួន ៤៣៣វគ្គ ដោយផ្សព្វផ្សាយតាមរយៈគេហទំព័រ, មជ្ឈមណ្ឌលការងារ, Facebook, និងកម្មវិធីនាទីទីផ្សារការងារ និងមុខរបរ នៅតាមស្ថានីយទូរទស្សន៍នានា។
- បានពង្រីកការផ្តល់ព័ត៌មានទីផ្សារការងារតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដោយមានអ្នកចូលប្រើប្រាស់គេហទំព័រចំនួន ៨៩៥ ៤៣៤ លើក, Facebook ចំនួន ៥ ៤៣០នាក់, YouTube ចំនួន ២៤ ៧៤៧នាក់ និងអ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើ Mobile App ចំនួន ១២៤នាក់។

▪ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** បានអប់រំផ្សព្វផ្សាយទូលំទូលាយក្នុងប្រព័ន្ធព័ត៌មានសង្គម ស្តីពី៖១-បរិមាណទីផ្សារតម្រូវការកសិផលកម្ពុជា ដែលអាចអូសទាញកម្លាំងពលករក្នុងវិស័យកសិកម្មមិនធ្វើចំណាកស្រុក។ ២-បានកៀរគរការចូលរួមពីផ្នែកឯកជនធ្វើការផ្សព្វផ្សាយ ស្តីពីការអប់រំវិធីសាស្រ្តដាំដុះដំណាំអនុផលដែលអាចលើកកម្ពស់ជីវភាពគ្រួសារមិនចាំបាច់ការធ្វើចំណាកស្រុក។

▪ **ក្រសួងព័ត៌មាន៖** បានពង្រឹងសមត្ថភាពដល់អ្នកសាព័ត៌មានឲ្យយល់ពីតម្លៃខ្លឹមសារព័ត៌មាន ដែលមិនមានការរើសអើងនិងជំរុញឲ្យមានការឲ្យតម្លៃលើការផ្សព្វផ្សាយដល់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដូចជាបាន៖ ១-គ្រប់គ្រងគេហស្ថានព័ត៌មានធ្វើការផ្សព្វផ្សាយព័ត៌មានពិតទាន់ហេតុការណ៍ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការសង្គ្រោះជនរងគ្រោះទាន់ពេលវេលា។ ២-បញ្ចូលសារអប់រំ ស្តីពីការចូលរួមបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមកម្មវិធីទូរទស្សន៍ជាតិ។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- បានសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជំរុញប្រតិបត្តិករផ្នែកសេវាកម្មទូរគមនាគមន៍មានដូចជាក្រុមហ៊ុន (១)ស្មាតអាស្យាតា ខូអិលធីឌី (២)ខេម ជីអេសអេម អែលធីឌី (៣)សៅអ៊ីស្ត អេស៊ា ធេលីខម ខេមបូឌា (៤)វៀតធេល ខេមបូឌា ធ្វើការផ្ញើសារ(SMS) ផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ ចំនួន ០២លើក៖
   ១. យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់ សីលធម៌ ដើម្បីសុវត្ថិភាពសង្គម ដែលមានខ្លឹមសារថា "រាល់ទម្រង់នៃការរំលោភបំពាន និងការជួញដូរកុមារជាបទល្មើស"
   ២. អបអរសាទរទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ២០២១ ដែលមានខ្លឹមសារថា "យើងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពលើកុមារ"
- បានផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក បានចំនួន ៥មាត្រា ដែលមានអ្នកឃើញចំនួន ៤.០១៥នាក់។

- **ថ្នាក់ក្រោមជាតិ៖**
  - **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ជ.ប.ជ និង មន្ទីរព័ត៌មានខេត្ត៖ បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM 103 MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងពាក់ព័ន្ធការជួញដូរមនុស្ស សរុបចំនួន ៣១១លើក (ផ្សាយផ្ទាល់ ១៣១លើក ចាក់ផ្សាយឡើងវិញ ១៨០លើក)។
  - **ខេត្តតាកែវ៖** ផ្សព្វផ្សាយព័ត៌មាន ស្តីពីច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោគធ្លក បានចំនួន ១២១លើក។
  - **ខេត្តមណ្ឌលគិរី៖** មន្ទីរធម្មការ និងសាសនាខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ FM 97MHz ចំនួន ៤០លើក ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងកម្មវិធី "ព្រះពុទ្ធ សាសនា ផ្សាភ្ជាប់សង្គម" ចំនួន ១២០លើក។
  - **ខេត្តកំពង់ចាម៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិភ្នំប្រុសភ្នំស្រី នូវកម្មវិធី ដូចជាៈ ចាក់ស្ប៉តអប់រំស្តីពីជំងឺកូវីដ១៩របស់ក្រសួងសុខាភិបាល ៣០ដង និងសេចក្តី សម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបិទចរាចរឆ្លងខេត្ត ០៥ដង។

**ខ.១.៦. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា**

- **ថ្នាក់ជាតិ៖**
  - **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
    - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសនៃកម្មវិធីវិទ្យុជាតិ កម្ពុជា ទ.ទ.ក ក្នុងវេទិកាជជែកពិភាក្សាតុមូល ស្ត្រីនិងការអភិវឌ្ឍក្នុងបរិការណ៍កូវីដ-១៩ ។ វេទិកានេះធ្វើឡើង ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីស្ថានភាព និងការចូលរួមរបស់ស្ត្រីដើម្បីការអភិវឌ្ឍន៍លើគ្រប់វិស័យ ជាពិសេសការបង្កើនភាពអង់អាចរបស់ស្ត្រី និងការទប់ស្កាត់អំពើហិង្សាក្នុងបរិការណ៍កូវីដ ១៩ ព្រមទាំងស្វែងយល់ពីអនុសាសន៍គន្លឹះៗ និងការប្តេជ្ញាចិត្តរបស់ក្រសួងស្ថាប័ននឹងដៃគូពាក់ព័ន្ធក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមនានា ក៏ដូចជាដើម្បីចូលរួមអបអរសាទរខួបលើកទី១១០ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០២១។ វេទិកានេះ មានការអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស និងភ្ញៀវកិត្តិយស លោកជំទាវ ហូ និមិត្ត អនុរដ្ឋលេខាធិការ តំណាងពីក្រសួងកិច្ចការនារី ឯកឧត្តមតំណាងពីក្រសួងអប់រំ យុវជននិងកីឡា លោកតំណាងពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ថ្នាក់ដឹកនាំ មន្ត្រីពីក្រសួងកិច្ចការនារី អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។
  - **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ចូលរួមជាវាគ្មិនក្នុង៖
    - វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការធ្វើផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការ CWCC នៅភ្នំពេញ។ចំនួន០១លើក។
    - ក្នុងកម្មវិធីវិទ្យុលើប្រធានបទ "យើងទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងអំឡុងពេលការឆ្លងរាលដាលនៃជម្ងឺកូវីដ ១៩" ដោយលោកស្រី **ឈាន ម៉ានិត** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត។
    - វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការធ្វើផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ មានការចូលរួមដោយលោកស្រី **ព្រុំ សុខន** ប្រធាននាយកដ្ឋាន និងរៀបចំដោយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC)។
  - **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមជាវាគ្មិនក្នុង៖
    - ការផ្សាយផ្ទាល់កម្មវិធី "សម្លេងសមភាពយេនឌ័រ" ដើម្បីជជែកពិភាក្សាអំពីរបៀបនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេសប្រកបដោយសុវត្ថិភាព និងរបៀបការពារខ្លួន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១។

- សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង "ចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព" ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១៩-២១ ខែមករា ឆ្នាំ២០២១ នៅសាលាខេត្តកំពុងស្ពឺ និងសាលាខេត្តព្រះសីហនុ។

- **ក្រសួងអប់រំ យុវជន និងកីឡា ៖** បានចូលរួមជាវាគ្មិននៅក្នុងកិច្ចសន្ទនាស្តីពី "អន្តរាគមន៍សមខាន់ៗក្នុងការទប់ស្កាត់ និងឆ្លើយតបហានិភ័យរបស់កុមារ ជាពិសេសក្មេងស្រីតាមប្រព័ន្ធអនឡាញ"។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ និងបានដឹកនាំក្រុមការងារជំនាញមានលោកឧត្តមសេនីយ៍ទោ **រ៉ែន សុភ័ក្រ្តវឌ្ឍនា** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងលោកអនុសេនីយ៍ឯក **ហង្ស ពុទ្ធារិទ្ធិ** ចូលរួមធ្វើជាគ្រូឧទ្ទេសជាមួយក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយ **លោកជំទាវ សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្នុងវគ្គសិក្ខាសាលាបំប៉ន ស្តីពីការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ជូនលោកគ្រូអ្នកគ្រូនៅខេត្តកំពង់ឆ្នាំង តាមប្រព័ន្ធហ្សូម (zoom) និង ខេត្តកំពង់ចាម។

- **ថ្នាក់ក្រោមជាតិ៖**
  - **ខេត្តសៀមរាប** ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុ ស្តីពីដំណើរការគ្រប់គ្រងស្ថិតិពលករចំណាកស្រុក ស្តីពីការបង្ការទប់ស្កាត់ការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ និងការលើកទឹកចិត្តឱ្យមាន មន្ត្រីនគរបាលជាស្ត្រីនៅតាមមូលដ្ឋាន និងការលើកកម្ពស់ការយល់ដឹងរបស់ស្ត្រីពីការជួញដូរផ្លូវភេទចំនួន ០៦លើក។
  - **ខេត្តបាត់ដំបង៖** បានចូលរួមជាវាគ្មិន៖
    - ក្នុងកិច្ចពិភាក្សា ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងផលប៉ះពាល់ ពីការធ្វើចំណាកស្រុកដោយខុសច្បាប់ នៅវិទ្យុជាតិចំការចេក 92.70MHz។
    - ក្នុងប្រធានបទទប់ស្កាត់ការរំលោភបំពានសិទ្ធិ និងការកេងប្រវ័ញ្ចពលកម្មកុមារ នៅវិទ្យុជាតិចំការចេក 92.70MHz។
  - **ខេត្តកំពង់ចាម៖**
    - ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ស្តីពីដំណើរការគ្រប់គ្រងស្ថិតិពលករចំណាកស្រុក និងស្តីពីការរាយការណ៍ករណីរំលោភសេពសន្ថវៈ ចំនួន ០២លើក។
    - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ស្តីពីការលើកទឹកចិត្ត ឱ្យមាននគរបាលជាស្ត្រីនៅតាមមូលដ្ឋាន និងការទប់ស្កាត់ភាពមិនប្រក្រតី ក្នុងទិវាបុណ្យនៃក្តីស្រឡាញ់។
    - បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទាមតិ ដើម្បីផ្សព្វផ្សាយ តាមរយៈវិទ្យុជាតិ នៃមន្ទីរព័ត៌មានខេត្ត និងផ្សព្វផ្សាយតាមបណ្តាញសង្គម ហ្វេកប៊ុក លើប្រធានបទ (រួមគ្នាលុបបំបាត់ និងទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ និងវិធានការទប់ស្កាត់ជំងឺកូវីដ១៩ របស់ក្រសួងសុខាភិបាល ដល់ពលចំណូលស្រុក បានចំនួន ០២លើក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ខ.២.១. ការបង្កើតកម្មវិធីសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

- **ថ្នាក់ជាតិ៖**
  - **ក្រសួងអប់រំ យុវជននិងកីឡា៖**
    - បានសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ Plan International រៀបចំ «សៀវភៅមេរៀន ស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស» សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីសិក្សា កម្រិតបឋមសិក្សា និងមធ្យមសិក្សា និងបានបញ្ចប់ជាស្ថាពរ។

សៀវភៅសិក្សានេះ នឹងត្រូវប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នៅខែកុម្ភៈ ឆ្នាំ២០២១ ហើយនឹងបន្តធ្វើការបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់ការបន្តបណ្តុះបណ្តាលវិធីសាស្ត្រប្រើប្រាស់សៀវភៅនេះ នៅទូទាំងប្រទេស និងរៀបចំឧបករណ៍សម្រាប់ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ និងគ្រូឧទ្ទេសសាលាគរុកោសល្យ។

- បាន និងកំពុងសហការជាមួយអង្គការភ្លែនអន្តរជាតិថៃ សិក្សាលើលទ្ធភាពនៃការបង្កើតកម្មវិធីសិក្សាពីរភាសា កម្ពុជា-ថៃ សម្រាប់កុមារជាប់ព្រំដែនកម្ពុជា-ថៃ ដែលត្រូវបានសាកល្បង នៅខេត្តត្រាត និងកោះកុង ដើម្បីបន្តរកលទ្ធភាពផ្តល់ការសិក្សាទៅកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ក្នុងប្រទេសថៃ។

**ខ.២.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

▪**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** (ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍)ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២១ ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានប្រមូលទិន្នន័យជាប្រចាំរបស់រដ្ឋបាលរាជធានី ខេត្ត នូវចំនួនពលករ វិលត្រឡប់ជារៀងរាល់ថ្ងៃ ក្នុងអំឡុងពេលនៃការរីករាលដាលជម្ងឺកូវីដ ១៩ សរុបប្រមាណ ៦៣.២៦៩នាក់ មានស្ត្រីប្រមាណ ២៧.១៦២នាក់ ដែលភាគច្រើនមិនមានសេសសល់ប្រាក់ចំណូលសម្រាប់ការផ្គត់ផ្គង់ខ្លួន ឬគ្រួសារនៅឯស្រុកទេ។

▪**អគ្គស្នងការដ្ឋាននគរបាលជាតិ៖** ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៥០.៨៨៥នាក់ (ស្រី ៥៤.៥៥៦នាក់) អនីតិជន៥៦៤នាក់(ស្រី១៥៧នាក់)។

**ខ.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងពលករធ្វើចំណាកស្រុកខុសច្បាប់**

▪**អគ្គស្នងការដ្ឋាននគរបាលជាតិ៖**កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តចំនួន០៥ បានធ្វើការងារបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសដោយខុសច្បាប់បានចំនួន ១០៩លើក មនុស្សចំនួន ៨៤១នាក់(ស្រី ៣១៨នាក់អនីតិជន ៤៥នាក់ ស្រី ០៧នាក់ ) ក្នុងនោះមាន៖

- ខេត្តបាត់ដំបង ៤០លើក មនុស្សចំនួន ១៨៨នាក់(ស្រី ៨៣នាក់)អនីតិជន ២៦នាក់ ។
- ខេត្តកោះកុង ២៧លើក មនុស្សចំនួន១២៤នាក់(ស្រី២៧នាក់)។
- ខេត្តបន្ទាយមានជ័យ ២៦លើក មនុស្សចំនួន ៣៣៦នាក់(ស្រី ១៣៤នាក់) អនីតិជន០៥នាក់
- ខេត្តតាកែវ ចំនួន ១១លើក មនុស្សចំនួន ១៦៥នាក់ (ស្រី ៥៥នាក់)។
- ខេត្តស្វាយរៀង បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរវៀតណាមបញ្ជូន ត្រឡប់មកវិញចំនួន០៥លើក មាន១៨គ្រួសារ មនុស្ស២៨នាក់(ស្រី១៩នាក់)ក្នុងនោះមានអនីតិជន១៤នាក់(ស្រី០៧នាក់)។ ក្រោយពីបានទទួល និងឃាតខ្លួនពលរដ្ឋទាំងនោះ ក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឲ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត។

**ខ.២.៤. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ**

- ថ្នាក់ជាតិ៖

▪ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

- បានធ្វើការអប់រំណែនាំតម្រង់ទិសពលករមុនចេញដំណើរអំពីភាសា បណ្តុះបណ្តាលជំនាញបឋម របៀបរបបធ្វើការងារ និងច្បាប់របស់ប្រទេសទទួលពលករ លក្ខខណ្ឌការងារ ការរស់នៅ និងទំនៀមទម្លាប់ប្រពៃណីនៃប្រទេសទទួលបានចំនួន ៦៣៤នាក់ ស្រី ១៥៦នាក់។
- បានរៀបចំពិព័រណ៍ការងារចល័តចំនួន ២២ដង មានអ្នកចូលរួមចំនួន ២.៩៥៤នាក់ និងរៀបចំវេទិកាការងារចំនួន ១០លើក មានអ្នកចូលរួមចំនួន ១.១៣៧នាក់។
- បានចុះឈ្មោះអ្នកស្វែងរកការងារ ចំនួន ៣.៣០៥នាក់ ស្រី២.៣០៩នាក់ និងជួយស្វែងរកការងារជូនប្រជាពលរដ្ឋតាមរយៈយន្តការផ្គូរផ្គងការងារតាមបច្ចេកវិទ្យាព័ត៌មាន មជ្ឈមណ្ឌលការងារ និងវេទិកា

ការងារថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាន ចំនួន ៦.៨៥៨នាក់ ស្រី៣.៩៧២នាក់ និងមានអ្នកទទួលបានការងារធ្វើចំនួន ៨៣៧នាក់ ស្រី៤៤៥នាក់។

- បានផ្តល់សេវាប្រឹក្សាយោបល់អាជីពការងារ និងវិជ្ជាជីវៈដល់អ្នកស្វែងរកការងារធ្វើចំនួន ១.៨៧៧នាក់ ស្រី ១.០៥៥នាក់។
- បាននិងកំពុងធ្វើការងារមួយចំនួនទៀតផងដែរ ដែលជាការទប់ស្កាត់ដោយប្រយោលនូវលំហូរពលកម្មចេញទៅក្រៅប្រទេស តាមរយៈការលើកកម្ពស់លក្ខខណ្ឌការងារ កន្លែងធ្វើការងារឱ្យបានកាន់តែល្អប្រសើរ ដោយបានតម្លើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០ មានចំនួន ១៩០ដុល្លារអាមេរិក និងបានតម្លើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២១ បានចំនួន ១៩២ដុល្លារអាមេរិក សម្រាប់កម្មករវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ហើយបើបូកបូកទាំងអត្ថប្រយោជន៍ផ្សេងៗ កម្មករម្នាក់ៗអាចទទួលបានជាង ២០០ដុល្លារអាមេរិក។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

- ក្រុមការងារការិ.នីតិកម្ម និងអធិការកិច្ច បានចុះអធិការមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀង ជាមួយក្រសួងស.អ.យ និងមណ្ឌលសំចត សរុបចំនួន ១៨មណ្ឌល (មជ្ឈមណ្ឌលរបស់អង្គការមាន ១៧មណ្ឌល និងមណ្ឌលសំចតប៉ោយប៉ែត របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះចំនួន០១កន្លែង) ដែល មានទីតាំងស្ថិតនៅ រាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីត្រួតពិនិត្យដល់មជ្ឈមណ្ឌលទាំងអស់នោះត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ក្រសួង។
- មន្ត្រីជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស បានចូលរួមសហការជាមួយអង្គការដៃគូ ចុះត្រួតពិនិត្យធ្វើការប៉ាន់ប្រមាណគ្រួសារស្ត្រីរងគ្រោះ ដោយអំពើជួញដូរមនុស្សចំនួន ៣០នាក់ ដែលមានទីតាំងស្ថិតនៅ រាជធានី-ខេត្ត ទាំង២៥ ។
- ឯកឧត្តម **ញឹក ខណ្ឌារ៉ា** រដ្ឋលេខាធិការក្រសួង ស.អ.យ បានដឹកនាំក្រុមការងារអន្តរក្រសួង ចុះត្រួតពិនិត្យការគ្រប់គ្រងស្ថាភាពការទទួលជនរងគ្រោះ និងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានវិលត្រឡប់តាមច្រព្រំដែនអន្តរជាតិ និងច្រកតំបន់នៃខេត្ត(ឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន កោះកុង ពោធិ៍សាត់ និងខេត្តស្វាយរៀង) និងដោយបានយកអំណោយនូវសម្ភារ គ្រឿងឧបភោគបរិភោគទៅចែកជូនដល់មន្ត្រីប្រចាំការនៅតាមច្រកនីមួយៗ និងកងកម្លាំងប្រចាំការនៅច្រកបឹងត្រកួនមួយចំនួនផងដែរ ដោយមានការចូលរួមសហការពីអង្គការ A21 ក្នុងអំឡុងពេគរាតត្បាតកូវីដ១៩នេះ។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានដាក់ចេញនូវវិធានការគ្រប់គ្រងស្ថានភាព ការទទួល ការបញ្ជូនពលករតាមបណ្តាច្រកព្រំដែន និងការធ្វើសមាហរណកម្មតាមបណ្តាមូលដ្ឋានថ្នាក់ក្រោមជាតិ ដោយរក្សាសុវត្ថិភាពសុខភាព តាំងពីដំណាក់កាលដំបូង នៃការប្រកាសបិទព្រំដែនរបស់ថៃ។

▪ **អង្គការដៃគូ៖**

- **អង្គការរតនៈអ៊ីនធើណេសិនណល** បានសហការជាមួយមន្ទីរ ស.អ.យ រាជធានី-ខេត្ត ធ្វើការត្រួតពិនិត្យតាមដាន និងសួរសុខទុក្ខជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញចំនួន៨០នាក់(ស្ត្រី ៦៥នាក់) ដែលមាននៅក្នុងរាជធានី-ខេត្ត ដូចជា៖ រាជធានីភ្នំពេញ និងខេត្ត(ឧត្តរមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ធំ កំពង់ស្ពឺ កណ្តាល តាកែវ តាខ្មៅ ព្រៃវែង និងខេត្តរតនៈគិរី)។

• **ថ្នាក់ក្រោមជាតិ៖**

▪ **លេខាធិការដ្ឋានរាជធានី ខេត្ត** បានធ្វើសេចក្តីរាយការណ៍ជាប្រចាំ អំពីពលករ និងពលរដ្ឋ ដែលវិលត្រឡប់ពីបរទេស ដើម្បីតាមដានស្ថានភាពសុខភាព ជីវភាព និងធ្វើការអប់រំបង្ការទប់ស្កាត់ ការវិលត្រឡប់

ទៅប្រទេសគោលដៅដោយប្រថុយប្រថាន តាមការញុះញង់ពីមេខ្យល់ និងសហការជាមួយអង្គការដៃគូ ដើម្បីធ្វើការប៉ាន់ប្រមាណអំពី ភាពប្រឈម និងសេចក្តីត្រូវការ ក្នុងពេលធ្វើសមាហរណកម្ម និងបានសហការជាមួយអង្គការដៃគូ សប្បុរសជន ផ្តល់ការឧបត្ថម្ភគាំទ្រ ផ្នែកសុខភាព និងជីវភាព។

**ខ.២.៥. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក**

ក្នុងឆមាសទី១ ឆ្នាំ២០២១នេះ តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈ ទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈ ប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System (EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប ២.១៨៩នាក់ ស្រី ៦៩៦នាក់ ក្នុងនោះមានៈ

| | | | | |
|---|---|---|---|---|
| - សាធារណរដ្ឋកូរ៉េ | ចំនួន | ១.៧៥៩នាក់ | ស្រី | ៤៦៧នាក់ |
| - ប្រទេសជប៉ុន | ចំនួន | ៣៨៧នាក់ | ស្រី | ១៨៦នាក់ |
| - ប្រទេសសិង្ហបុរី | ចំនួន | ០២នាក់ | ស្រី | ០២នាក់ |
| - តំបន់រដ្ឋបាលពិសេសហុងកុង | ចំនួន | ៤១នាក់ | ស្រី | ៤១នាក់ |

ពលករត្រូវត្រឡប់ចូលមកកម្ពុជាវិញ តាមច្រកមិនផ្លូវការ និងរាយប៉ាយតាមព្រំដែន ដែលចាំបាច់ត្រូវមានកម្លាំងអាជ្ញាធរ សមត្ថកិច្ច របស់ខេត្តជាប់ព្រំដែន និងខេត្តផ្សេងៗដែលមានពលករ សហការជាមួយមន្ត្រីសុខាភិបាល មធ្យោបាយដឹកជញ្ជូនពីយោធា កងរាជអាវុធហត្ថ នគរបាលព្រំដែន កម្លាំងយុវជន នារី អង្គការសមាគម និងវិស័យឯកជនជាច្រើន ចូលរួមក្នុងការទទួលពលករ ចុះបញ្ជី ពិនិត្យកម្តៅ សម្ភាសន៍ពីស្ថានភាព ផ្តល់សេវាចាំបាច់ រៀបចំកន្លែង និងបញ្ជូនទៅធ្វើចត្តាឡីស័ក ពិនិត្យរកមេរោគកូវីដ ១៩ ផ្តល់ការព្យាបាល និងផ្តល់ការឧបត្ថម្ភជាគ្រឿងឧបភោគ បរិភោគ សម្ភារៈអនាម័យ និងការអប់រំផ្សេងៗ។ ប្រព័ន្ធទិន្នន័យ នៃពលករវិលត្រឡប់ ត្រូវបានបង្កើតឡើង និងប្រើប្រាស់ ជាមូលដ្ឋានសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមានរបាយការណ៍ជាប្រចាំពីគ្រប់ខេត្ត និងរាជធានី ។

តាមរបាយការណ៍ពីស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដែលបានតាមដានបច្ចុប្បន្នភាពទិន្នន័យនៃពលករដែលធ្វើចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ ឃើញថា ក្នុងរយៈពេល៦ខែដើមឆ្នាំ មានប្រជាជនចំណាកស្រុកចេញ ចូលជាប្រក្រតី។ ប៉ុន្តែនៅ ឆ្នាំ២០២១ ចំនួននៃអ្នកធ្វើចំណាកស្រុកឆ្លងដែន នៅតិចតួចបំផុត ហើយសុទ្ធតែជាការឆ្លងដែនខុសច្បាប់ក្នុងអំឡុងពេល នៃការរឹតបន្តឹង និងបិទព្រំដែន នៃប្រទេសជិតខាង និងការបិទជើងយន្តហោះ។ អ្នកដែលប្រថុយប្រថានឆ្លងដែនដោយខុសច្បាប់ក្នុងអំឡុងពេលនេះ ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា និងប្រទេសពាក់ព័ន្ធ ធ្វើការហាមឃាត់ ឬបញ្ជូនត្រឡប់មកមូលដ្ឋានសហគមន៍ដែលគាត់រស់នៅវិញ។

**ខ.២.៦. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ល្បាតឃ្លាំមើលគោលដៅ សង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទបានចំនួន **៥៤៦លើកលើគោលដៅ ១៨២គោលដៅ** ដែលមានចំនួនមនុស្សសរុបចំនួន១.២៤៩នាក់ (ស្រី ១.០៣៦នាក់)។

*ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ*

| ស្នងការដ្ឋានរាជធានី-ខេត្ត | ឆមាសទី១ ឆ្នាំ២០២១ | | | | | |
|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| | ១២០លើក | ១១២លើក | ១០៨ លើក | ៩៦លើក | ១០០លើក | ១០លើក |
| សរុប | ៥៤៦លើក | | | | | |

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមគោលដៅបម្រើសេវាកំសាន្ត ដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ ដូចមានតារាងខាងក្រោម៖

*តារាងបច្ចុប្បន្នភាពគោលដៅសេវាកំសាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០២១*

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| ចំនួនគោលដៅ | ៨៩ | ២០ | ១៨២ | គ្មាន | គ្មាន | គ្មាន |
| ចំនួនមនុស្ស | ៣៦១ | ១៥៣ | ៧៣៥ | គ្មាន | គ្មាន | គ្មាន |
| ចំនួនស្ត្រី | ២៤៨ | ១២៩ | ៦៥៩ | គ្មាន | គ្មាន | គ្មាន |

**ខ.២.៤. ការបង្ការ ទប់ស្កាត់តាមរយៈ ការជួញដូរមនុស្សតាមរូបភាព រៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) នៃច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យ និងសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ២១១គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅ នារីខ្មែរដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស ក្នុងនោះសាធារណរដ្ឋកូរ៉េ ១៣នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

**ខ.៣. កិច្ចការពារ និងការតាមដានពលករដែលចេញទៅធ្វើការនៅក្រៅប្រទេស**

▪ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ក្រុមការងាររបស់ក្រសួងបានបន្តសហការជាមួយស្ថានឯកអគ្គរាជទូត/អនុព័ន្ធការងារ/អគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំ ប្រទេសទទួល ក្នុងការគាំពារពលករ ការផ្តល់អត្ថប្រយោជន៍ និងការសម្របសម្រួលដោះស្រាយបញ្ហាជូនពលករកម្ពុជា ដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសទទួល ក្នុងអំឡុងពេលវិកាលជាលនៃជំងឺកូវីដ-១៩ ៖

- ប្រទេសថៃ បានចុះ៖(១-ចែកស្បៀងអាហារជូនពលករជួបផលវិបាកកំឡុងពេលកូវីដ-១៩ ចំនួន ១២៧០នាក់។ ២-សួរសុខទុក្ខពលករគ្រោះថ្នាក់ការងារចំនួន ២ទីតាំង ដែលមានពលករចំនួន ៥៧នាក់ដោះស្រាយនិងប្រឹក្សាយោបល់តាមទូរស័ព្ទចំនួន ៣៣២ខ្សែ។ ៣-ដោះស្រាយវិវាទជូនពលករជាមួយនិយោជក ១ករណី ដែលមានពលករ ២នាក់)។
- ប្រទេសកូរ៉េ បានចុះ៖(១-ជួបដោះស្រាយ ប្រឹក្សាយោបល់ និងចុះសួរសុខទុក្ខពលករតាមទីតាំងផ្សេងៗ ចំនួន ៨៧លើក។ ២-ដោះស្រាយវិវាទ និងបញ្ហាជូនពលករ តាមរយៈសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ច និងអង្គការ សមាគម មជ្ឈមណ្ឌល ចំនួន ១៣៧លើក។ ៣-ផ្សព្វផ្សាយព័ត៌មានអប់រំ ចំណេះដឹងច្បាប់ ការថែទាំសុខភាពនិងស្ថានភាពទូទៅ ១៤៨លើក។ ៤-ប្រឹក្សាយោបល់តាមទូរស័ព្ទប្រមាណ ៧៥០លើក)។
- ប្រទេសម៉ាឡេស៊ី បានជួយ៖(១-អន្តរាគមន៍ដល់ពលករ ពលការិនីឱ្យបានត្រឡប់ទៅកម្ពុជាវិញ សរុបចំនួន ៣៣៧នាក់ (ស្ត្រី ១៥៣នាក់) ក្នុងនោះកុមារចំនួន ៣២នាក់ (កុមារី ១៦នាក់) តាមរយៈកម្មវិធី Repatriation Recalibration Plan របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ម៉ាឡេស៊ី។

២-សម្របសម្រួលឯកសារធ្វើដំណើរជូនពលរដ្ឋកម្ពុជាដែលជាប់នៅតាមមន្ទីរឃុំឃាំងនានាសរុបចំនួន ១៧៦នាក់។ ៣-សម្របសម្រួលអន្តរាគមន៍ដល់ក្មេងស្រីពលការិនីខ្មែរ ចំនួន ១៤ករណី ៤-បាននាំយកអំណោយជាស្បៀងអាហារជូនពលរដ្ឋកម្ពុជា តាមរយៈតំណាងស្ម័គ្រចិត្ត សរុបចំនួន ៨២គ្រួសារ ដែលជួបការខ្វះខាតខ្លាំង នៅរដ្ឋ Pahang និងរដ្ឋ Selangor ក្នុងអំឡុងពេលបិទខ្ទប់ប្រទេសម៉ាឡេស៊ីទាំងមូលជាលើកទី៣ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១។ ៥-និងបានសហការជាមួយអង្គការក្នុងស្រុក Youth With A Mission Malaysia ចែកជំនួយសង្គ្រោះបន្ទាន់ជាស្បៀងអាហារដល់ពលរដ្ឋខ្មែរសរុបចំនួន ១០គ្រួសារ នៅតំបន់ Kampar រដ្ឋ Perak។ ៦-កំពុងសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ IOM Malaysia ដើម្បីជួយឱ្យពលរដ្ឋខ្មែរកំពុងជាប់ទោសនៅ Tanah Merah រដ្ឋ Kelantan ចំនួន ២០នាក់ ឱ្យបានត្រឡប់ទៅកម្ពុជាវិញ។ សហការជាមួយអង្គការបានធ្វើការសម្ភាសផ្ទាល់រួចរាល់ជាមួយពលរដ្ឋចំនួន១០នាក់ ហើយគ្រោងនឹងទិញសំបុត្រយន្តហោះជូនពួកគាត់នៅថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០២១។

- **ប្រទេសជប៉ុន** បានចុះ៖(១- ជួបសំណេះសំណាលជាមួយសហគម និងពលករនៅតាមខេត្ត-ក្រុងចំនួន **២៧**លើក។ ២-សហការជាមួយមន្ត្រី កុងស៊ុលចុះសួរសុខទុក្ខពលករនៅមន្ទីរឃុំឃាំង ចំនួន ០៣លើក។ ៣-សម្របសម្រួលនៅព្រលានយន្តហោះអន្តជាតិ Narita ដល់ពលករដែលមានបញ្ហាស្មារតីវិលត្រលប់ទៅប្រទេសកម្ពុជាវិញចំនួន ០១លើក។ ៤-សហការជាមួយក្រុមមេធាវីស្ម័គ្រចិត្តជប៉ុនចុះផ្តល់សេវាប្រឹក្សាយោបល់ដល់ពលករចំនួន០១លើក។ ៥-ជួបប្រជុំដោយផ្ទាល់ និងតាម Online ជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធចំនួន ១១លើក។ ៦- ជួបប្រជុំការងារជាមួយបុគ្គលិកសមាគមនិយោជកជប៉ុនស្តីពី "ការពង្រឹងកិច្ចសហការផ្តល់សេវាគាំពារដល់ពលករឱ្យបានល្អប្រសើរ និងទូលំទូលាយ" ចំនួន ០៩លើក។ ៧-ប្រជុំការងារជាមួយអនុព័ន្ធ/ទីប្រឹក្សាទទួលបន្ទុកការងារអមស្ថានទូតថៃ បង់ក្លាដេស ឡាវ ហ្វីលីពីន ស្តីពី "ការចែករំលែកបទពិសោធន៍ និងយន្តការដោះស្រាយបញ្ហាការងាររបស់កម្មសិក្សាការី និងពលករជំនាញឱ្យបានល្អប្រសើរ និងទទួលបានជោគជ័យ" ចំនួន ០៤លើក។ ៨-ប្រជុំការងារជាមួយវិស័យឯកជន ស្តីពី "ការពង្រីកទីផ្សារកម្លាំងពលកម្ម និងលើកទឹកចិត្តនិយោជកជប៉ុនជ្រើសរើសកម្មសិក្សាការី និងពលករជំនាញខ្មែរ" ចំនួន ០៨លើក។ ៩-ដោះស្រាយវិវាទការងាររបស់ពលករចំនួន ៧៤ករណី។ ១០-ជួយស្វែងរកការងារចំនួន ២៥រូប និងបានផ្តល់ប្រឹក្សាយោបល់ការងារតាមទូរស័ព្ទ និងPageស្ថានទូតចំនួន ៥៤០លើក។

## ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ថ្នាក់ជាតិ៖**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានយកចិត្តទុកដាក់ខិតខំអនុវត្តលើការងារកុមារដោយផ្តោតលើគោការណ៍ចម្បងបីគឺ (១)ដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឱ្យកុមារទទួលបានការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មកុមារទៅក្នុងសង្គមជាតិ (២)កិច្ចសហការជាមួយអង្គការសង្គមស៊ីវិលនានា និងការប្រយុទ្ធប្រឆាំងការជួញដូរស្ត្រី និងកុមារ (៣)ការលើកកម្ពស់ការងារសមរម្យ និងសុវត្ថិភាពការងារកុមារ។ ទន្ទឹមនឹងនេះ ក្រសួងបាន៖

- ចុះធ្វើអធិការកិច្ចការងារសាមញ្ញតាមបណ្តាសិប្បកម្មផលិតឥដ្ឋ ក្នុង រាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ សៀមរាប និងខេត្តកណ្តាល ចំនួន៤៥លើក ដើម្បីផ្សព្វផ្សាយការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ដែលមានកម្មករនិយោជិតចូលរួមសរុប១.៤៧៨នាក់ (ស្រី៦៣៧នាក់)

- សហការជាមួយអង្គការ ILO BFC បានចុះត្រួតពិនិត្យនៅតាមរោងចក្រ សហគ្រាសចំនួន ០៤ ដូចជា ក្រុមហ៊ុន Yumark Pacific (Cambodia) Co.,Ltd ក្រុមហ៊ុន JS Leather Collection Phnom Penh Co.,Ltd ក្រុមហ៊ុន ជី & អិល (ខេមបូឌា) ហ៊ែនប៉ែក អ៊ិនដាសស្រ្ទៀល ឯ.ក និង ក្រុមហ៊ុន ញូផិច ខូ អិលធីឌី ដែលឈ្មោះក្រុមហ៊ុនពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងពលកម្មកុមារ។

- **ថ្នាក់ក្រោមជាតិ៖**
  - **ខេត្តត្បូងឃ្មុំ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះអប់រំ ធ្វើកិច្ចសន្យា និងដាក់ស្លាក សញ្ញាហាមកុមារចូលបរិវេណឡូតជ្ជ ជាមួយម្ចាស់សិប្បកម្ម ចំនួន ០២លើក បាន ២៣សិប្បកម្ម។
  - **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញ ដែលបានដាក់ចំនួន ១.១៣៣នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។
  - **ខេត្តសៀមរាប៖**

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដោយដកហូតកុមារ ចំនួន ០៦នាក់ ស្រី ០៤នាក់ និងទប់ស្កាត់កុមារ ចំនួន ១២៤នាក់ ស្រី ៦៩នាក់។ ២.បានបន្តផ្សព្វផ្សាយសារ និងវីដេអូអប់រំស្តីអំពី **"សុវត្ថិភាពតាមអនឡាញ"** ចំនួន០៨គ្រូសារ និង០៨វីដេអូ តាមទំព័រហ្វេសប៊ុករបស់អង្គការសកម្មភាពដើម្បីកុមារ ដែលបានដល់ក្រុមគោលដៅដែលជាកុមារ យុវជន ឪពុកម្តាយ អ្នកមើលថែកុមារ និងអ្នកធ្វើការជាមួយកុមារចំនួន ១,២៤៦,១៤៤នាក់ និងមានការឆ្លើយតបចំនួន ១២០,៦៣៦នាក់ សំដៅលើកទឹកចិត្តឲ្យមានការរក្សាសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ៣.បានបញ្ចប់ និងផ្សព្វផ្សាយសៀវភៅជំនួយស្មារតី ស្តីអំពីសេវាសម្រាប់ជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។
- មន្ទីរទេសចរណ៍ខេត្ត បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីទេសចរណ៍ សេវាកម្មទេសចរណ៍ តាមមូលដ្ឋានអាជីវកម្ម និងបញ្ជ្រាបអំពីការទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ លើកុមារ និងធ្វើការណែនាំអំពីវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ចំនួន ២៥លើក មនុស្ស ចំនួន ១៩២នាក់ (ស្រី ១៧៥នាក់)។

  - **ខេត្តប៉ៃលិន៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡូតជ្ជ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។
  - **ខេត្តក្រចេះ៖** ១.មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ចំនួន ០២លើក។ ២.មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះផ្សព្វផ្សាយអំពីខ្លឹមសារ ការកេងប្រវ័ញ្ចលើពលកម្មកុមារ ការទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិកកម្មករ(ពិសេសកុមារ) តាមបណ្តាសិប្បកម្មស្រាល នៅស្រុកព្រែកប្រសព្វ បានចំនួន០២មូលដ្ឋាន មានបុគ្គលិកចំនួន ០៨នាក់ ស្រី០២នាក់។

## ខ.៥. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

ជាយន្តការសម្រាប់គ្រប់គ្រងពលករខ្មែរដែលចេញទៅធ្វើការនៅក្រៅប្រទេស ក្រសួងពាក់ព័ន្ធសំខាន់ចំនួន០៣ គឺ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចទទួលខុសត្រូវចំពោះសុវត្ថិភាព ផលប្រយោជន៍ និងការគោរពសិទ្ធិពល

ករក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ការងារ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល បានដាក់ចេញនូវអនុក្រឹត្យ លេខ ១៩០អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងប្រកាស ចំនួន ០៨ ដើម្បីកំណត់តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករ និងយន្តការនៃការដោះស្រាយបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានធ្វើបច្ចុប្បន្នភាពទីភ្នាក់ងារជ្រើសរើសពលករជាប្រចាំ និងបានផ្សព្វផ្សាយទូលំទូលាយតាមប្រព័ន្ធឌីជីថល(វិបសាយ និងហ្វេសប៊ុក) ថែមទៀត។ ជាការកត់សម្គាល់ ចំនួនទីភ្នាក់ងារជ្រើសរើសឯកជនមាន ១២៦ និងបានធ្វើសកម្មភាពដោយផ្តោតការយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាដែលពលករកំពុងប្រឈមក្នុងប្រទេសគោលដៅ ជាជាងការជ្រើសរើសពលករថ្មី ដើម្បីបញ្ជូនទៅក្នុងស្ថានភាពនៃការរឹតបន្តឹង ដោយមានវិបត្តិកូវីដ ១៩។

- ក្នុងចំណោមទីភ្នាក់ងារទាំង ១២៦ ត្រូវបានចងក្រងជាសមាគមចំនួនពីរ គឺ (១).សមាគមទីភ្នាក់ងារជ្រើសរើសពលករ(ACRA) (២).សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងផ្សព្វផ្សាយអំពីគោលការណ៍ផ្សេងៗ។

- ក្រសួងបានជួបប្រជុំផ្សព្វផ្សាយដល់ទីភ្នាក់ងារជ្រើសរើសឯកជនចំនួន ៧៥ អំពីគោលការណ៍ជ្រើសរើសប្រកបដោយក្រមសីលធម៌(IRIS Ethical Recruitment) របស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) ដែលផ្តោតសំខាន់លើការមិនយកថ្លៃឈ្នួលពីពលករ នៅក្នុងដំណាក់កាលជ្រើសរើស និងក្នុងដំណាក់កាលដាក់ឱ្យធ្វើការងារ ដែលថ្លៃឈ្នួលទាំងនោះនឹងត្រូវចេញជំនួសដោយនិយោជក។

- ដោយមានកិច្ចសហការពីអង្គការពលកម្មអន្តរជាតិ (ILO) បានជំរុញឱ្យទីភ្នាក់ងារជ្រើសរើសពលករបង្កើតនូវក្រមសីលធម៌របស់ទីភ្នាក់ងារ ដើម្បីធានានូវគុណភាព និងសុវត្ថិភាពពលករក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ការងារ។

- ក្រសួងមានប្រព័ន្ធទិន្នន័យសម្រាប់ការចុះបញ្ជីរបស់ទីភ្នាក់ងារ និងរបស់ពលករដែលត្រូវបានជ្រើសរើសដោយទីភ្នាក់ងារ និងស្ថានភាពការងារក្នុងប្រទេសគោលដៅ ដែលទីភ្នាក់ងារត្រូវផ្តល់របាយការណ៍ជាប្រចាំដល់នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម។

- នៅតាមបណ្តាស្ថានទូតនៃបណ្តាប្រទេសគោលដៅ ដែលមានពលករកម្ពុជាបាននិងកំពុងស្នាក់នៅនិងធ្វើការច្រើន ក្នុងនោះមាន ព្រះរាជាណាចក្រថៃ សាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន និងប្រទេសម៉ាឡេស៊ី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់បញ្ជូនទីប្រឹក្សាអមស្ថានទូតទទួលបន្ទុកការងារ ដើម្បីដោះស្រាយបញ្ហា ពលករដែលនៅទីនោះ។

▪ **ឯក្រសួងមហាផ្ទៃ** ដែលមានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គស្នងការដ្ឋាននគរបាលជាតិ (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានកណ្តាលព្រំដែន) និងរដ្ឋបាលថ្នាក់ក្រោមជាតិ សុទ្ធតែមានតួនាទី សម្របសម្រួល ផ្តល់ឯកសារស្របច្បាប់ ត្រួតពិនិត្យតាមដានរំហូរចេញចូលរបស់ពលករ និងការស៊ើបអង្កេត ស្រាវជ្រាវរកបទល្មើសក្នុងប្រព័ន្ធនៃការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស។

▪ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** មានតួនាទីទំនាក់ទំនង សហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធ ក្នុងការធានាសុវត្ថិភាព ផលប្រយោជន៍ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពលករដែលបាននិងកំពុងធ្វើការក្នុងប្រទេសគោលដៅ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖**

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី- ខេត្ត។

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៩៨ករណីលើ៦៣ករណី (ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ១៣៥ករណី ស្មើនឹង២១៤.២៨%) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២៩១នាក់(ស្រី៣១នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ១៣នាក់ និង(ជនបរទេស ០៤នាក់ មានជនជាតិវៀតណាម ០៣នាក់ និងបែលហ្សិក០១នាក់)។

សង្គ្រោះជនរងគ្រោះចំនួន ៧២១នាក់ ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ ៨៨នាក់ អាយុ១៥-១៧ឆ្នាំ ៦៣នាក់ និងអាយុពី១៨ឆ្នាំឡើង ៥៧០នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២៥នាក់ និងប្រគល់ឱ្យគ្រួសារ ៦៩៦នាក់) ក្នុងនោះមានចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ១៣៩ករណី/១៦ករណី(កើនឡើង ១២៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២៣១នាក់(ស្រី ២៥នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០៣នាក់ (ជនបរទេសជាជនជាតិវៀតណាម ០២នាក់ និងបែលហ្សិក០១នាក់) និងសង្គ្រោះជនរងគ្រោះចំនួន ៦៣៥នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ៣៣នាក់ អាយុ១៥-១៧ឆ្នាំ ៤២នាក់ និងអាយុពី១៨ឆ្នាំឡើង ៥៦០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៣នាក់ និងប្រគល់ឱ្យគ្រួសារ ៦៣២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០២ | ០៣ | ០៣ | |
| -ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ០៣ | ០៣ | វៀតណាម០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១២១ | ៥៥៥ | ១៩៨ (ជាអនីតិជន ០៣នាក់) | វៀតណាម០១ |
| -អំពើលក់ដូរមនុស្ស | ០៣ | ០២ | ០៤ | |
| -ការទទួលមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០៥ | ៣១ | ០៩ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០២ | ៣០ | ០៨ | |
| -អំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន | ០១ | ០ | ០២ | |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ០១ | ០៤ | ០២ | |
| -ការទិញពេស្យាកុមារ | ០២ | ០៧ | ០២ | |
| | | | | បែលហ្សិក០១ |
| *សរុប* | *១៣៩ ករណី* | *៦៣៥នាក់* | *២៣១នាក់ (ជាអនីតិជន ០៣នាក់)* | *វៀតណាម ០២នាក់* បែលហ្សិក០១ |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៥៩ករណី/៤៧ករណី(កើន ១២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៦០នាក់ (ស្រី ០៦នាក់) អនីតិជន ១០នាក់ ជនបរទេសជាជនជាតិវៀតណាម ០១នាក់ ។ សង្គ្រោះជនរងគ្រោះចំនួន ៨៦នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ៥៥នាក់ អាយុ១៥-១៧ឆ្នាំ ២១នាក់ និងអាយុពី១៨ឆ្នាំឡើង ១០នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច ២២នាក់ និងប្រគល់ឱ្យ គ្រួសារ ៦៤នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០៥ | ២៤ | ០៦ (ជាអនីតិជន០២ នាក់) | វៀតណាម១ នាក់ |
| -សញ្ចាកម្ម(មានអនីតិជន) | ០១ | ០៥ | ០១ | |
| -សញ្ចាកម្ម | ០១ | ០ | ០១ | |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០៣ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៤ | ៤៤ | ៤៤ (ជាអនីតិជន០៨ នាក់) | |
| -អំពើអាសប្រផាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ | ១០ | ០៧ | |
| *សរុប* | *៥៩ករណី* | *៨៦នាក់* | *៦០នាក់ (អនីតិជន១០)* | *វៀតណាម ០១ នាក់* |

**គ.១.២. ការងារដំណោះស្រាយវិវាទការងាររវាងពលករទៅធ្វើការនៅក្រៅប្រទេស និងក្រុមហ៊ុនជ្រើសរើសពលករ**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម បានដោះស្រាយតាមពាក្យបណ្តឹងរបស់ពលករចំនួន ៤នាក់ ក្នុងករណីករណីដែលពួកគាត់បានបង់ប្រាក់ទៅអោយក្រុមហ៊ុន CPS Best Team Service ដើម្បីបញ្ជូនពួកគាត់ទៅធ្វើការនៅប្រទេសថៃ តែក្រុមហ៊ុនមិនបានធ្វើតាមកិច្ចសន្យា ដូច្នេះត្រូវបានដោះស្រាយឱ្យពួកគាត់បានទទួលសំណងប្រាក់មកវិញគ្រប់ចំនួន និងសុំដកពាក្យបណ្តឹង។

## គ.២. កិច្ចការយុត្តិធម៌

### ក. លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ ដូចមានក្នុងតារាងលម្អិតខាងក្រោម៖

១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖

សរុបមានចំនួន ៤០៥សំណុំរឿង ជនរងគ្រោះចំនួន ៣៨៤នាក់(ស្រី ១៦២នាក់) ក្នុងនោះមានអនីតិជន ១៤២នាក់(ស្រី៧៥នាក់) ជនត្រូវចោទមានចំនួន ៤៣៨នាក់(ស្រី ១៦០នាក់) ក្នុងនោះមានអនីតិជន ១៥នាក់ (ស្រី ០២នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ៣៨៤សំណុំរឿង តម្កល់ទុកឥតចាត់ការ

១០សំណុំរឿង បញ្ជូនរឿងទៅជម្រះផ្ទាល់ ០៧សំណុំរឿង នីតិវិធីបង្គាញខ្លួនភ្លាម ០២សំណុំរឿង និងកំពុងចាត់ការចំនួន ៤២សំណុំរឿង។

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | បញ្ជូនរឿងទៅជម្រះផ្ទាល់ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | |
| ៤០៥ | ៤០ | ១៦២ | ៦៧ | ៧៥ | ២៦៣ | ១៦០ | ១៣ | ០២ | ៣៨៤ | ១០ | ០៧ | ៤២ |
| សរុប | ២០២នាក់ | | ១៤២ | | ៤២៣ | | ១៥ | | | | | |
| សរុបរួម | ៣៤៤ នាក់ | | | | ៤៣៨ នាក់ | | | | ៤០៥សំណុំរឿង ក្នុងនោះ(នីតិវិធីបង្គាញខ្លួនភ្លាម ០២សំណុំរឿង) | | | |

២. <u>ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត</u> ៖

សរុបមានចំនួន ៣៣២សំណុំរឿង ជនរងគ្រោះចំនួន ៣៩៦នាក់ (ស្រី ១៨១នាក់) ក្នុងនោះមានអនីតិជន ១៣៨នាក់(ស្រី ១២៣នាក់) ជនត្រូវចោទមានចំនួន ៤៥៤នាក់ (ស្រី ៩២នាក់) ក្នុងនោះមានអនីតិជន ៧៥នាក់ (ស្រី ១០នាក់) ក្នុងនោះបានចំណាត់ការ(បញ្ជូនទៅជម្រះចំនួន ១១៧សំណុំរឿង លើកលែងចោទ ០៥សំណុំរឿង និងកំពុងចាត់ការចំនួន ២១០សំណុំរឿង)។

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | | | |
| ៣៣២ | ៧៧ | ១៨១ | ១៥ | ១២៣ | ២៨៧ | ៩២ | ៦៥ | ១០ | ១១៧ | ៥ | ២១០ |
| សរុប | ២៥៨នាក់ | | ១៣៨នាក់ | | ៣៧៩នាក់ | | ៧៥នាក់ | | | | |
| សរុបរួម | ៣៩៦ នាក់ | | | | ៤៥៤ នាក់ | | | | ៣៣២សំណុំរឿង | | |

៣. <u>ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត</u>៖

សរុបមានចំនួន ២០៤សំណុំរឿង ជនរងគ្រោះចំនួន ១៨៧នាក់(ស្រី ៨១នាក់) ក្នុងនោះមានអនីតិជន ៨៣នាក់(ស្រី ៧៥នាក់) ជនជាប់ចោទសរុប ១៩៩នាក់(ស្រី ៨៦នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរ ០២នាក់ ពិន័យជាប្រាក់ ០១សំណុំរឿង រួចផុតពីបទចោទ ០៤សំណុំរឿង រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ៦៥ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ៣៧សំណុំរឿង និងកំពុងចាត់ការ ១៣៩សំណុំរឿង)។

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | ប្រភេទចំណាត់ការ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | | | | | | | |
| ២០៤ | ២២ | ៨១ | ០៨ | ៧៥ | ១១៣ | ៨៦ | ២ | ១ | ៤ | ០ | ៦៥ | ៣៧ | ១៣៩ |
| សរុប | ១០៤នាក់ | | ៨៣នាក់ | | ១៩៩នាក់ | | | | | | | | |
| សរុបរួម | ១៨៧ នាក់ | | | | ១៩៩ នាក់ | | | | | | | | |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ

### ឃ.១.ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

▪ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានតំណាងនៅបរទេស បានសង្គ្រោះ ឧបត្ថម្ភ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណបឋម រកភាពរងគ្រោះ និងបានធ្វើការសន្និដ្ឋានបឋមថាជា ករណីស្នាក់នៅ និងធ្វើការងារដោយខុសច្បាប់ ឬសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស សរុបចំនួន ២.៣១៧នាក់ (ស្រី ៩៧២នាក់) ក្នុងនោះពលករដែលមកពីប្រទេសថៃមានរហូតដល់ ១.៦០៨នាក់ ស្រី ៤៨០នាក់ ដែលជាពលករខុសច្បាប់។ ខាងក្រោមនេះជាតារាងនៃពលករដែលបានទទួលការសង្គ្រោះ ៖

| ល.រ. | ប្រទេសគោលដៅ | មូលហេតុនៃការវិលត្រឡប់ | សរុប | ស្រី |
|---|---|---|---|---|
| ១ | ម៉ាឡេស៊ី | ពលករខុសច្បាប់ | ៣៣២ | ១៧៥ |
| ២ | ចិន | សង្ស័យជួញដូរ និងចាញ់បោកមេខ្យល់ | ២៣១ | ២៣០ |
| ៣ | សឹង្ហបុរី | ទ្រាំការងារមិនបាន | ០៧ | ០៧ |
| ៤ | វៀតណាម | ឆ្លងដែនខុសច្បាប់ | ៣៨ | ៣០ |
| ៥ | ថៃ | ពលករខុសច្បាប់ | ១.៦០៨ | ៤៨០ |
| ៦ | ឡាវ | ឆ្លងដែនខុសច្បាប់ | ២៦ | ០៥ |
| ៧ | ឥណ្ឌា | ឆ្លងដែនខុសច្បាប់ | ៧៤ | ៤៤ |
| ៨ | ឥណ្ឌូណេស៊ី | ឆ្លងដែនខុសច្បាប់ | ០១ | ០១ |
| សរុប | | | ២.៣១៧ នាក់ | ៩៧២ នាក់ |

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សដែលបានធ្វើមាតុភូមិនិវត្តន៍ និងទទួលពីប្រទេសនានា សរុបចំនួន ៤០.៨២២នាក់(ស្ត្រី ១៦.១៣៣នាក់ កុមារ៉ា ២.៣៩៥នាក់ កុមារី ២.១៧៥នាក់ មានដូចខាងក្រោម៖

- ក្រុមការងារការពារជនរងគ្រោះ ទទួលពីប្រទេសនានា សរុបចំនួន ២២៤នាក់ (ស្ត្រី ១៧៤នាក់ កុមារ៉ា ០៤នាក់ កុមារី ៣០នាក់) មកពីប្រទេសៈ ចិន ១៧៧នាក់ វៀតណាម(ឆ្លងទៅចិន) ១៤នាក់ ថៃ ១៤នាក់ ឥណ្ឌូនេស៊ី ០១នាក់ និងប្រទេសម៉ាឡេស៊ី ១៤នាក់ និងសង្ហបូរី ០៤នាក់ ក្នុងនោះដូចជាករណី( *កេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ ជួញដូរកម្លាំងពលកម្ម ១១នាក់ អាពាហ៍ពិពាហ៍ផ្ទុយពិធនៈ/បង្ខំ ១៦២នាក់ និងករណីងាយរងគ្រោះ ៣២នាក់*) បានធ្វើការសម្ភាសន៍រួចបញ្ជូនទៅទទួលសេវានៅអង្គការដៃគូ និងសហគមន៍វិញ។
- មណ្ឌលសំចតប៉ោយប៉ែត បានទទួលជនងាយរងគ្រោះពីប្រទេសថៃ[២] សរុបចំនួន ៤០ ៥៩៨នាក់ (ស្ត្រី១៥ ៩៥៩នាក់ កុមារ៉ា២ ៣៩១នាក់ កុមារី២ ១៤៥នាក់) និងបានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះចំនួនសរុប ៦០នាក់ (បុរស១១នាក់ ស្ត្រី២៥នាក់ កុមារា១៣ នាក់ កុមារី១១នាក់ )ជាករណី ( *កេងប្រវ័ញ្ចកម្លាំងពលកម្ម ១៧នាក់ និងជនងាយរងគ្រោះ ៤៣នាក់*) និងបញ្ជូន ទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជាៈ ក្រុម3PC (អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការភឿន អង្គការសាម៉ារីតាន់ភឺស និងអង្គការរតនៈអ៊ិនធើណេសិនណល)។

➢ *សូមបញ្ជាក់៖*

[១]តាម ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ១៩៦នាក់ ច្រកទ្វារព្រំដែនអន្តរជាតិបាវិត ១៤នាក់ និង ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ១៤នាក់។

២មានៈ ច្រកម៉ាឡេ ៩ ២៤១នាក់ ច្រកអូរបីជាន់ ២៧ ០៧៧នាក់ ច្រកអន្តរជាតិប៉ោយប៉ែត និងច្រក (១១៩) ៤ ២៨០នាក់។

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ៖

នាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួល និង សម្ភាសជនរងគ្រោះ និងជនទេសន្តរប្រវេសន៍ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១១១នាក់ (ស្រី៩៧នាក់) ក្នុងនោះមកពីប្រទេសចិនចំនួន៩៩នាក់(ស្រី៩៦នាក់) ឥណ្ឌូនេស៊ី០១នាក់ និង ប្រទសម៉ាឡេស៊ីចំនួន១០នាក់(ស្រី០១នាក់)និងសង្ហបុរី០១នាក់។ លទ្ធផលបំភ្លឺជនរងគ្រោះទៅតាមរយៈមេខ្យល់ស្គាល់អត្តសញ្ញាណ០៤នាក់ ទៅតាមរយៈមេខ្យល់មិនស្គាល់អត្តសញ្ញាណចំនួន១០៦ និងទៅតាមក្រុមហ៊ុន០១នាក់ បច្ចុប្បន្នជនរងគ្រោះប្រគល់ឲ្យមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្តារនីតិសម្បទា ។

**ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់**

▪ ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ ទទួលសពពលរដ្ឋ មកពីប្រទេសថៃ តាមច្រកប៉ោយប៉ែតបានចំនួន ១១សព (ស្រី ០៦សព )។

**ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស(៦ខែ)**

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រុមការងារការពារជនរងគ្រោះ និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយ អង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ២៣៩នាក់ (ស្ត្រី ១៥៣នាក់ កុមារា ១៥នាក់ កុមារី ៦៧នាក់) ជាករណី( *ងាយរងគ្រោះ ២៥នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០៧នាក់)* ក្នុងនោះមាន មន្ទីរស.អ.យ រាជធានី ខេត្ត ៨០នាក់ និងអង្គការដៃគូ ១៥៩នាក់ ។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការ ជាមួយអាជ្ញាធរ មូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើ ជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ៦៨នាក់ (ស្ត្រី៦៤នាក់) ក្នុងនោះជា ករណី( *អាពាហ៍ពិពាហ៍ដោយផ្ទុយពីឆន្ទៈ/បង្ខំ៦២នាក់ ជួញដូរកម្លាំងពលកម្ម០៤នាក់ រំលោភបំពានផ្លូវភេទ ០២នាក់*) ដោយមានកិច្ចសហការពីអង្គការដៃគូក្នុងការបញ្ជូន។

## III.ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

**ក.១. ការងារបណ្តុះបណ្តាល**

**ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការ ដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលចំនួន ៤៧វគ្គ មានសិក្ខាកាមចូលរួមចំនួន ២.១៦៨នាក់ ក្នុងនោះមានស្ត្រី ៤៨០នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិកគ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងវគ្គ បណ្តុះបណ្តាលខាងក្រោម៖

តារាងវគ្គបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន៖<br>-សហការ ជាមួយ អង្គការ MOI រៀបចំវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីប្រព័ន្ធអន្តរជាតិនៃការជ្រើសរើសពលករដោយសុចរិត (IRIS) ដល់ទីភ្នាក់ងារជ្រើសរើសពលករ។ | ០១ | ៣២ | ១០ |

| | | | |
|---|---|---|---|
| -រៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "ការត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារធ្វើ"។<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង បានសហការរៀបចំ និងចូលរួមបិទវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី "ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស" ដល់គ្រូបង្គោល ថ្នាក់ភូមិ ឃុំ ស្រុក ដែលរៀបចំដោយអង្គការការីតាស់កម្ពុជា និងអង្គការ ILO។<br>-រៀបចំវគ្គបណ្តុះបណ្តាលពិសេសស្តីពី ប្រព័ន្ធស្វ័យប្រវត្តិកម្មអធិការកិច្ចពលកម្មកុមារ។ | ២០<br>០២<br><br><br><br>០១ | ៥០៥<br>៣៨<br><br><br><br>១២ | ០០<br>២១<br><br><br><br>០៤ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** | | | |
| **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន** បានសហការជាមួយ អង្គការសកម្មភាពដើម្បីកុមារ បើកវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នីតិវិធីអនីតិជនទំនាក់នឹងច្បាប់ និងការសម្ភាសន៍បែបកុមារមេត្រី។ | ០១ | ៣០ | ០៥ |
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសហគ្រាសចំនួន ០៧ បើកវគ្គបណ្តុះបណ្តាល ស្តីពីបំណិនជីវិត និងច្បាប់ស្តីពីការងារ សុខភាព សុវត្ថិភាព និងការជួយសង្គ្រោះ។ | ០២ | ៤៨៣ | ១១៩ |
| **ខេត្តកំពង់ចាម៖** គ.ខ.ប.ជ ស្រុកចំការលើ បើកវគ្គបណ្តុះបណ្តាលលើកកម្ពស់ កិច្ចការពារសិទ្ធិការងារ សម្រាប់ពលករចំណាកស្រុកដែលមានជំនាញទាបទៅប្រទេសថៃ។ | ០១ | ១៨ | ១២ |
| **ខេត្តត្បូងឃ្មុំ៖** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ។ | ០១ | ៣៤ | ០៤ |
| **ខេត្តសៀមរាប៖**<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត និងអង្គការជីវិតនៅកម្ពុជា បើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងកិច្ចការពារកុមារ ដល់មន្ត្រីនគរបាល និងអាវុធហត្ថ នៅស្រុកសូទ្រនិគម ស្វាយលើ ជីក្រែង បន្ទាយស្រី ប្រាសាទបាគង និងក្រុងសៀមរាប។<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ធ្វើការផ្សព្វផ្សាយតាមសាលារៀន និងក្នុងសិប្បកម្មឥដ្ឋ។<br>-អង្គការAPLE បានបើកវគ្គបណ្តុះបណ្តាលតាមអនឡាញ ជាមួយបុគ្គលិកអង្គការចំនួន ០៧ក្នុងខេត្តសៀមរាប ស្តីពីទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាន។<br>-អង្គការមូលនិធិ២១អេ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិការធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្ស នៅតាមមូលដ្ឋាន និងសាលារៀន។<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការបន្ទាយស្រី បានបើកវគ្គបណ្តុះបណ្តាលតាមអនឡាញ ស្តីពី៖ ១-កិច្ចការពារកុមារ ដល់បណ្តាញអង្គការដៃគូ។ ២-ការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារនៅ សហគមន៍ ដល់រដ្ឋបាលឃុំចំនួន០៦ និងរដ្ឋបាលឃុំស្រុកអង្គរជុំ។ ៣-ស្តីពីការពង្រឹងសមត្ថភាពលើការកត់ត្រាទិន្នន័យពលករចំណាកស្រុមក និងការ វិលត្រឡប់ពីការក្រៅប្រទេស។ | ០៤<br><br><br><br><br>០១<br>០១<br>០៩<br>០៣ | ៣៣៣<br><br><br><br><br>២០<br>២៧<br>៦០០<br>៣៦ | ១៤<br><br><br><br><br>១៤<br>១៦<br>២៤០<br>២១ |
| សរុប | **៤៧ វគ្គ** | **២.១៦៨ នាក់** | **៤៨០ នាក់** |

## ក.២. សិក្ខាសាលា

### ក.២.១.សិក្ខាសាលាក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលចំនួន ១៣៨វគ្គ មានសិក្ខាកាមចូលរួមចំនួន ៦.៨៩៦នាក់ ក្នុងនោះមានស្ត្រី១៦៣នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិកគ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងវគ្គសិក្ខាសាលាខាងក្រោម៖

**តារាងសិក្ខាសាលា**

| សកម្មភាពរៀបចំសិក្ខាសាលា | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** បានរៀបចំសិក្ខាសាលា<br>-ពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍(MGI) របស់កម្ពុជា និងការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់(GCM) នៅសណ្ឋាគារ Raffles ភ្នំពេញ។ | ០១ | ៣៨ | ១២ |
| **-បានសហការជាមួយអង្គការសង់គ្រាល់** រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត) "Topic: 2nd Consultation Workshop on Ethical Recruitment Process (Virtual)" តាមប្រព័ន្ធវីដេអូអនឡាញ Zoom ក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ឧ.ឯក ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ។** | ០១ | ៥៧ | ០០ |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំសិក្ខាសាលា៖<br>-ការរៀបចំផែនការអាជីព និងជ្រើសរើសជំនាញសិក្សា សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិចំនួន ១០៩ដង ដែលមានអ្នកចូលរួម ៥ ៤៦៤នាក់ | ១០៩ | ៥.៤៦៤ | ០០ |
| -ការណែនាំអាជីព ការងារ និងវិជ្ជាជីវៈសម្រាប់និស្សិត នៅគ្រឹស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសកលវិទ្យាល័យ។ | ០៨ | ៤០០ | ០០ |
| -ស្តីពីការផ្សព្វផ្សាយ និងការចុះឈ្មោះអ្នកស្វែងរកការងារនៅតាមមូលដ្ឋាន។ | ១២ | ៥៩៣ | ០០ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងកែសម្រួលលើសៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានកិច្ចសហការជាមួយអង្គការ IOM ។ | ០១ | ២៧ | ១៣ |
| **ក្រសួងអប់រំ យុវជន និងកីឡា៖** បានសហការជាមួយអង្គការក្លែន និងក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំសិក្ខាសាលា៖<br>- ស្តីពីការបំប៉នគ្រូឧទ្ទេសលើការអប់រំបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការប្រើប្រាស់សៀវភៅ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម ដោយមានការចូលរួមពីលោកគ្រូ អ្នកគ្រូមកពីសាលាគរុកោសល្យចំនួន៧ខេត្ត នៅសាលាគរុកោសល្យ និងវិក្រិដ្ឋការ ខេត្តកំពង់ចាម ។ | ០១ | ៨៦ | ២៣ |
| -បានរៀបចំសិក្ខាសាលាវគ្គបំប៉នស្តីពី ការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន តាមប្រព័ន្ធហ្សូម ដល់លោកគ្រូ អ្នកគ្រូ នៅខេត្តកំពុងឆ្នាំង។ | ០១ | ៥៣ | ៣០ |

| | | | |
|---|---|---|---|
| **រាជធានីភ្នំពេញ៖** អង្គការជំហ៊ានដំបូងកម្ពុជា រៀបចំសិក្ខាសាលា "ស្តីពីការស្វែងយល់ និងការរាយការណ៍ពីការរំលោភបំពានផ្លូវភេទលើកុមារ" នៅសណ្ឋាគារហ៊ីម៉ាវ៉ារី។ | ០១ | ៤៣ | ១៧ |
| **ខេត្តកំពង់ស្ពឺ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការយែកម្ពុជាអន្តរជាតិ រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារប្រចាំឆ្នាំ២០២០ នៃគម្រោងចំណាកស្រុក ដោយសុវត្ថិភាព ក្រោមអធិបតីភាព លោកជំទាវឧ.ទោ រ៉ែន **សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ **ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ | ០១ | ៥០ | ៣៥ |
| **ខេត្តព្រះសីហនុ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការយែកម្ពុជាអន្តរជាតិ រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារប្រចាំឆ្នាំ២០២១ នៃគម្រោងចំណាកស្រុកដោយសុវត្ថិភាព ក្រោមអធិបតីភាព លោកជំទាវឧ.ទោ រ៉ែន **សិរីលក្ខិណា** អគ្គលេខាធិការរង តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ **ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ | ០១ | ៤០ | ២៨ |
| **ខេត្តសៀមរាប៖** បានសហការរៀបចំសិក្ខាសាលា ស្តីពីគោលការណ៍ណែនាំក្នុងការដោះស្រាយវិវាទរបស់ពលករទេសន្តប្រវេសន៍ និងគោលនយោបាយទេសន្តរប្រវេសន៍ការងារ ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣។ | ០១ | ៤៥ | ០៥ |
| សរុប | ១៣៨ វគ្គ | ៦.៨៩៦នាក់ | ១៦៣ នាក់ |

## ២. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.១. សន្និសីទ កិច្ចប្រជុំ ក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេស**

- **ថ្នាក់ជាតិ**
  - គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
    - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សា ៖ ១-ទ្វេភាគីកម្ពុជា-ថៃ តាមប្រព័ន្ធអនឡាញ "ដែលកិច្ចប្រជុំបានពិភាក្សាលើចំណុចដែលនៅសេសសល់ក្នុងសេចក្តីព្រាងចុងក្រោយ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់រវាងកម្ពុជា-ថៃ" នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួម ២៩នាក់(ស្រី ០៦នាក់)។ ២-SOP ទ្វេភាគីកម្ពុជា-ថៃ តាមប្រព័ន្ធអនឡាញ "ស្តីពីស្តង់ដានីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់" នៅសណ្ឋាគារកាំបូឌីយ៉ាណា អ្នកចូលរួមចំនួន ៣២នាក់ (ស្រី ០៨នាក់)។ ៣-កែសម្រួលជាភាសាបរទេស លើគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តប្រវេសន៍ ជាមួយលោកស្រី **គ្រីស្ទីន ផាកូ** ប្រធានអង្គការអោយអុអឹម IOM នៅសាលប្រជុំ គ.ជ.ប.ជ។ ៤-ស្តីពី **"ការកែសម្រួលរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ គ.ជ.ប.ជ ឆ្នាំ២០២០ និងលើកទិសដៅការងារ ឆ្នាំ២០២១"** ចំនួន ០៣លើក អ្នកចូលរួមចំនួន ២៤នាក់ (ស្រី ០៥នាក់) នៅសាលប្រជុំ គ.ជ.ប.ជ ។ ៥-ជាអធិបតីភាព ក្នុងកិច្ចប្រជុំស្ថាប័នមិនមែនរដ្ឋាភិបាល ប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា បញ្ហាប្រឈម និងទិសដៅអនាគត ដែលរៀបចំ និងសម្របសម្រួលពីអង្គការ USAID ដោយមានការអញ្ជើញចូលរួម ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពី បណ្តាអង្គការដៃគូពាក់ព័ន្ធនានា មានដូចជា Caritas swiss, IJM, IOM,A21, Cambodia Act, Hope for justice, Care, Ratanak, USAID, LSCW, We world-GVC ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសេវាគាំទ្រដល់ជនរងគ្រោះជាពលករទេសន្តប្រវេសន៍ និងនៅ

ក្នុងប្រទេស នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ ៦-ជាមួយថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធនឹងគម្រោងការផ្តល់សេវាគាំទ្រទៅកាន់ពលករដែលវិលត្រលប់ មានស្ត្រី និងកុមារដែលងាយរងគ្រោះ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។ ៧-តាមរយៈ Video Conference ស្តីពី "REGIONAL  PEER LEANING BUILDING ON COMMITMENTS TO COMBAT IUU FISHING AND TO PROVIDE HUMAN RIGHTS PROTECTION IN THE CAPTURE FISHERY SECTOR in SOUTH-EAST ASIA" ដែលរៀបចំដោយ The Coordinating Ministry for Maritime and Investment Affairs of Republic of Indonesia in collaboration with Foundation for International Human Rights Reporting Standards (FIHRRST) នៅសាលប្រជុំគ.ជ.ប.ជ។ ៨-ស្តីពីការបង្កើតទស្សនាវដ្តីសម្រាប់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ។ ៩-តាមប្រព័ន្ធអនឡាញជាមួយលេខាធិការដ្ឋានអង្គការសហប្រជាជាតិ និងបណ្តាញអង្គការសហប្រជាជាតិស្តី ពីទេសន្តរប្រវេសន៍ (UNNetworkMigration) ស្តីពីការដាក់ បញ្ចូលកម្ពុជា ទៅក្នុងបញ្ជីប្រទេសជ័យលាភី នៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ នៅសាលប្រជុំ គ.ជ.ប.ជ។ ១០-តាមប្រព័ន្ធអនឡាញ ស្តីពីកិច្ចពិគ្រោះយោបល់លើការស្វែងរកការស្រាវជ្រាវ និងអនុសាសន៍  ស្តីពីការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ  សម្រាប់ជនទេសន្តរប្រវេសន៍ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស  រៀបចំសម្របសម្រួលដោយអង្គការវីនរ៉ក់ Winrock នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន លោកជំទាវ អគ្គលេខាធិការ អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការសហប្រតិបត្តិការអន្តរជាតិ ប្រធានក្រុមការងារ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អ្នកតំណាងពីក្រុមការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការយូសេដ USAID និងអង្គការដៃគូពាក់ព័ន្ធការងារជួយជនរងគ្រោះពីទេសន្តរប្រវេសន៍។ កិច្ចប្រជុំពិភាក្សានេះ ធ្វើឡើងក្នុងគោលបំណងយល់ដឹងពីទស្សនៈ ផ្តត់គំនិតរបស់ជនរងគ្រោះនិងផ្តល់សេវាឲ្យចំគោលដៅ ជាតម្រូវការចំបាច់របស់ជនទេសន្តរប្រវេសន៍។ និងស្វែងយល់ចែករំលែកបទពិសោធន៍ការងារពីប្រទេសសាមីពាក់ព័ន្ធ ដោយមានគាំទ្រពីគម្រោងអភិវឌ្ឍន៍របស់ USAID ក្នុងការអនុវត្តការងារនេះ។ គម្រោងស្រាវជ្រាវនេះ ក៏អាចឲ្យយើងសិក្សាយល់ដឹងបន្ថែមពីទម្រង់ផ្សេងៗបរិបទសម័យថ្មីអំពីបទល្មើសជួញដូរមនុស្ស និងអាចប្រើប្រាស់ជាភស្តុតាងចង្អុលផ្លូវក្នុងការអនុវត្តការងារជួយជនរងគ្រោះ ទេសន្តរប្រវេសន៍ពីអំពើជួញដូរមនុស្ស។ ១១-ការងារជាមួយតំណាងអង្គការសម្ព័ន្ធចាប់ដៃ ស្តីអំពីកិច្ចសហប្រតិបត្តិការ លើកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ ទីប្រឹក្សា និងប្រធានលេខាធិការដ្ឋាន នៅសាលប្រជុំអគ្គលេខាធិការការដ្ឋាន គ.ជ.ប.ជ។ ១២-តាមប្រព័ន្ធវីដេអូអនឡាញ កែសម្រួលលើរបៀបមួយចំនួន ត្រៀមមុនកិច្ចប្រជុំលើកម្រងឯកសារសិក្ខាសាលា ASEAN-ACT ស្តីពីការឆ្លើយតបយុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មីសិក្ខាសាលាទី ៦ ក្រោមប្រធានបទវិធីសាស្ត្ររបស់ ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងជួយកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការ ឆ្លើយតបការជួញដូរមនុស្ស មានការចូលរួមលោកជំទាវអគ្គលេខាធិការ ទីប្រឹក្សា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គលេខាធិការរង សហប្រតិបត្តិការជាតិ អន្តរជាតិ អគ្គលេខាធិការរង នៃក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់  ប្រធានក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ តំណាងពីក្រសួងយុត្តិធម៌ តំណាងអង្គការដៃគូពាក់ព័ន្ធ មាន ASEAN -ACT និង ពីអង្គការពីប្រទេសពាក់ព័ន្ធមួយចំនួន ដែលរៀបចំនិងសម្របសម្រួលដោយអង្គការ ASEAN-ACT ។ ១៣-សកម្មភាពពិនិត្យ និង កែសម្រួលខ្លឹមសារសេចក្តីព្រាង  សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាព

ជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ របស់ក្រសួងសុខាភិបាល មានការចូលរួមក្នុងកិច្ចប្រជុំនេះ ដោយលោកជំទាវអគ្គលេខាធិការលេខាធិការ អគ្គលេខាធិការរង ទទួលបន្ទុកកិច្ចការងារសហប្រតិបត្តិការអន្តរជាតិ លោកទីប្រឹក្សា គ.ជ.ប.ជ លោកប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ និងលោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ១៤-រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការសម្ព័ន្ធចាប់ដៃ ស្តីពីកិច្ចសហប្រតិបត្តិការ ការពារជនរងគ្រោះ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ លោកទីប្រឹក្សា គ.ជ.ប.ជ លោក **ឌី នឿត** នាយកប្រចាំប្រទេសអង្គការសម្ព័ន្ធចាប់ដៃ លោក **ចាន់ សារ៉ុន** ប្រធានកម្មវិធីអង្គការសម្ព័ន្ធចាប់ដៃ លោក **សៀង វន្ថា** អនុប្រធានកម្មវិធីអង្គការសម្ព័ន្ធចាប់ដៃ សរុបចំនួន ០៧រូប ស្រី ០២រូប នៅសាលប្រជុំអគ្គលេខាធិការ គ.ជ.ប.ជ។ ១៥-តាមប្រព័ន្ធអនឡាញ ស្តីពី "កិច្ចពិភាក្សាពិគ្រោះយោបល់លើការស្វែងរកការស្រាវជ្រាវ និង អនុសាសន៍ ស្តីពីការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ សម្រាប់ជនទេសន្តរប្រវេសន៍ ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស "ដែលរៀបចំសម្របសម្រួលដោយអង្គការវីនរ៉ក់ (Winrock)។ មានការអញ្ជើញចូលរួមពីអគ្គលេខាធិការរង ទទួលបន្ទុកកិច្ចការសហប្រតិបត្តិអន្តរជាតិ លោកប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ អ្នកតំណាងពីក្រុម ការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការយូសេដ និង អង្គការដៃគូពាក់ព័ន្ធការងារ ជួយជនរងគ្រោះពីទេសន្តរប្រវេសន៍ នៅបន្ទប់សាលប្រជុំ គ.ជ.ប.ជ។ ១៦-តាមប្រព័ន្ធវីដេអូអនឡាញ កែសម្រួលលើរបៀបវារៈមួយចំនួន ត្រៀមមុនកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលា ASEAN -ACT ស្តីពី "ការឆ្លើយតប យុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មីសិក្ខាសាលាទី៦ ក្រោមប្រធានបទ វិធីសាស្ត្ររបស់ ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងជួយកាត់ បន្ថយគម្លាតសមភាពយេនឌ័រក្នុងការឆ្លើយតបការជួញដូរមនុស្ស។ មានការចូលរួមក្នុងកម្មវិធីនេះ ដោយលោកជំទាវអគ្គលេខាធិការ លោកទីប្រឹក្សាអគ្គលេខា គ.ជ.ប.ជ លោកជំទាវអគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការរងទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ តំណាងពីក្រសួងយុត្តិធម៌ និងតំណាងអង្គការដៃគូពាក់ព័ន្ធមាន ASEAN -ACT និងពីអង្គការពីប្រទេសពាក់ព័ន្ធនៅសាលប្រជុំ គ.ជ.ប.ជ។ ១៧-បានអញ្ជើញចតាមរយៈប្រព័ន្ធវីដេអូ ស្តីពី"វឌ្ឍនភាពនៃការអនុវត្តគម្រោងសាកល្បងវគ្គបណ្តុះបណ្តាលថ្នាក់បឋមសិក្សារ វាងកម្ពុជា និងថៃ នៅខេត្តកោះកុង និងខេត្តត្រាត" លើកទី៤ ជាមួយក្រសួងអប់រំ យុវជន និងកីឡា និងភាគីថៃ វត្តមានសរុប ២៦នាក់។ ១៨-ក្នុងអង្គសិក្ខាសាលាថ្នាក់តំបន់ ដើម្បីគាំទ្រការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ ស្តីពីការប្រតិបត្តិមណ្ឌលស្នាក់នៅ នៅក្នុងរដ្ឋជាសមាជិកអាស៊ាន ជាពិសេសនៅក្នុងកំឡុងពេលមានការរីករាលដាលមេរោគកូវីដ១៩ តាមរយៈប្រព័ន្ធវីដេអូ។ រៀបចំដោយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN ACT) សហការជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស (MSDHS)ប្រទេសថៃ, ស្ថាប័នទំនាក់ទំនងនៃកិច្ចប្រជុំឧត្តមមន្ត្រី ស្តីពីការងារសង្គមកិច្ច និងអភិវឌ្ឍន៍(SOMSWD), តំណាងប្រទេសថៃសម្រាប់សិទ្ធិកុមារ នៅក្នុងគណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ(ACWC) និងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីន ជាអ្នកដឹកនាំស្ម័គ្រចិត្តលើការងារប្រឆាំងការជួញដូរមនុស្ស សម្រាប់ក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន (SOMTC) និងដោយមានការចូលរួមពីប្រទេសជាសមាជិកអាស៊ានអ្នកពាក់ព័ន្ធ សរុបចំនួន ២០០រូប។ ១៩-ស្តីពីសកម្មភាពការងារអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។

២០-រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាព ប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីផ្ញើទៅអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ មានអ្នកចូលរួម សរុបចំនួន ២២រូប ស្រី ០៥រូប។ ២១-រៀបចំទិសដៅឆ្នាំ២០២១របស់ គ.ជ.ប.ជ របៀបវារៈនៃ អង្គប្រជុំមានចំនួន២គឺ៖ ១.ឆ្លើយតបសំណើសុំផ្តល់ធាតុចូល ក្នុងរបាយការណ៍ស្តីពី អនុសញ្ញា អន្តរជាតិ របស់អង្គការ ILO។ **២២**.បច្ចុប្បន្នភាពការងារ និងទិសដៅសម្រាប់ឆ្នាំ២០២១។ ជាកិច្ចបន្ត **លោកជំទាវ ជូ ប៊ុនអេង** បានផ្តល់ជាអនុសាសន៍ ដល់ក្រុមការងារទាំង៦ ពិនិត្យមើលផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ដើម្បីជាទុនក្នុងការឆ្លើយតប និងដាក់ផែនការបន្តក្នុងឆ្នាំ២០២១។ **២៣**-កិច្ចប្រជុំស្តីពី សកម្មភាពការងារអាទិភាពសំខាន់ៗ និងរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។ **២៤**-កិច្ចប្រជុំពិភាក្សាសម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ "ស្តីពី គោលការណ៍មិនដាក់ទណ្ឌកម្ម លើជនរងគ្រោះដោយអំពើជួញដូរ" ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តម ទីប្រឹក្សា លោកប្រធានលេខាធិការដ្ឋានរដ្ឋ បាលសរុប ប្រធាន អនុប្រធានក្រុមការងារទាំង៦ និងក្រុមការងារ មន្ត្រីជំនាញពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអគ្គស្នងការដ្ឋាននគរបាលជាតិ។

- **ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន** គ.ជ.ប.ជ បានប្រជុំពិភាក្សា៖
  - រៀបចំសមាសភាពក្រុមការងារ និងឯកសារសម្រាប់វគ្គបណ្តុះបណ្តាលសៀវភៅ **ការអប់រំ ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន** ជាមួយនាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា វគ្គមានចូលរួមចំនួន ១២នាក់(ស្រី ០១នាក់)។
  - ស្តីពីការរៀបចំឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ ដើម្បីបង្រៀនបន្តដល់គរុសិស្ស សម្រាប់បង្រៀនសិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ លើសៀវភៅ **ការអប់រំស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន** ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលាគរុកោសល្យខេត្តកំពង់ចាម វគ្គមានចូលរួមចំនួន ១៦នាក់(ស្រី ០៣នាក់)។
  - តាមប្រព័ន្ធអនឡាញជាមួយអង្គការ APLE ស្តីពីការពង្រឹងនិងលើកកម្ពស់ការរាយការណ៍ ករណីសង្ស័យនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ នៅក្រសួងអប់រំ យុវជន និងកីឡា ។
  - ជាក្រុមការងារការពារជនរងគ្រោះស្តីពី "វឌ្ឍនភាពការងាររបស់ក្រុមការងារការពារជនរងគ្រោះប្រចាំត្រីមាសទី២ ឆ្នាំ២០២១"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំកិច្ចប្រជុំ៖**
  - ១-របាយការណ៍ឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ២០២១។ ២-ត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះនៅទីស្តីការក្រសួង ស.អ.យ។ ៣-កែសម្រួលកិច្ចព្រមព្រៀងរបស់អង្គការបេសកកម្មទូទាំងពិភពលោក (The Mssion WorlWide) ដោយការិយាល័យនីតិកម្ម និអធិការកិច្ច និងមានការចូលរួមពីមន្ត្រីជំនាញរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងតំណាងអង្គការ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ សរុបចំនួន ០៦នាក់ (ស្រ្តី ០២នាក់)។

- ៤-ចង្អៀតក្រុមការងារជួយជនរងគ្រោះចំនួន ០២លើក ស្តីពីកិច្ចពិភាក្សាស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីជួយជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា អំឡុងពេលរោគរាតត្បាតកូវីដ ១៩ តាមប្រព័ន្ធអនឡាញ ZOOM មានអ្នកចូលរួមចំនួន ៣៨នាក់(ស្រី ១២នាក់)។ ៥-ស្តីពីការគ្រប់គ្រងទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះ និងសមាហរណកម្ម តាមអនឡាញ ដែលបានដឹកនាំមន្ត្រីគ្រប់គ្រងករណីប្រជុំ ជាមួយអង្គការតេនៈអ៊ិនធើណេសិនណល ដោយលោកស្រី **ឈា ម៉ានិត** ប្រធានមណ្ឌលសំចតប៉ោយប៉ែត។ ៦-ត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៅទីស្តីការក្រសួង ស.អ.យ។ ៧-កែសម្រួលកិច្ចព្រមព្រៀងរបស់ អង្គការបេសកកម្មទូទាំងពិភពលោក (The Mission WorldWide) ដោយមានការចូលរួមពីមន្ត្រីជំនាញរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងតំណាងអង្គការ នៅនាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ដែលមានអ្នកចូលរួមសរុប ០៦នាក់(ស្រី០២នាក់) (ការិយាល័យនីតិកម្ម និងអធិការកិច្ច)។ ៨-ថ្នាក់បច្ចេកទេស (កម្រិតជំនាញ) ពិភាក្សាសម្រាប់ត្រៀមប្រជុំទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និង ថៃ លើទម្រង់របាយការណ៍សម្ភាសន៍ និងផែនការអនុវត្តនៃនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញZOOM អ្នកចូលរួមសរុប ៣៦នាក់ (ស្រី ១០នាក់) ដែលជាមន្ត្រីជំនាញពីបណ្តាក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធ ដោយសហការជាមួយអង្គការអន្តរជាតិ ទេសន្តរប្រវេសន៍(IOM)។
- ជាមួយអង្គការតេនៈអ៊ិនធើណេសិនណលចំនួន ៤លើក ស្តីពី៖ ១.គម្រោងផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២១ របស់នាយកដ្ឋាន។ ២.គម្រោងកំណត់អត្តសញ្ញាណ និងសមាហរណកម្មជនរងគ្រោះ នៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត(ខេត្តបន្ទាយមានជ័យ)។ ៣.ការអនុវត្តសកម្មភាពការងារសម្រាប់ឆ្នាំ២០២១។ ៤.ការពិនិត្យឡើងវិញនូវលំហូរនៃដំណើរការមាតុភូមិនិវត្តន៍ និងសេចក្តីព្រាង(តាមZOOM)។

- **អគ្គលេខាធិការ គ.ជ.ប.ជ**

- លោកជំទាវ ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញដឹកនាំប្រជុំពិភាក្សា៖ ១.ពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរណៈយោគយល់រវាងគ.ជ.ប.ជ និងអង្គការ We World Onlus។ ២.ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃ ការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។ ៣.ពិភាក្សាផ្តល់ចម្លើយតបជូនទៅអង្គការគំនិតផ្តួចផ្តើមសកលប្រឆាំង នឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង (Global Initiative against Transnational Organized Crime)ទាំង១២សំណួរ ពាក់ព័ន្ធអំពើជួញដូរមនុស្ស។ ៤.ក្នុងការបើកសិក្ខាសាលា "ពិគ្រោះយោបល់លើកទី២ ស្តីពីដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត) " Topic: 2nd Consultation Workshop on Ethical Recruitment Process (Virtual)តាមប្រព័ន្ធវីដេអូអនឡាញ Zoom ដែលរៀបចំសម្របសម្រួល ដោយអង្គការសង់គ្រាល់។ ៥.បំពេញបន្ថែមចូលទៅក្នុងឯកសារពីរប្រភេទ របស់ក្រសួងមហាផ្ទៃ ដើម្បីឆ្លើយតបក្នុងអនុសាសន៍ នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជា សកល(UPR)ឆ្នាំ២០១៩ ជុំទី៣ និងឆ្លើយតបសេចក្តីសង្កេតសន្និដ្ឋាន នៃរបាយការណ៍ជាតិ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(ICERD) ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អគ្គ

លេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៦.ត្រួតពិនិត្យ កែសម្រួលខ្លឹមសារ SOP រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ ជាភាសាខ្មែរ ដោយមានការចូលរួមពី ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការ គ.ជ.ប.ជ។ ៧.តាមរយៈប្រព័ន្ធវីដេអូ ស្តីពីលទ្ធផលនៃការអនុវត្តសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំត្រីមាសទី១ ឆ្នាំ២០២១ ជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប នៅសាលប្រជុំ គ.ជ.ប.ជ។ ៨.តាមរយៈប្រព័ន្ធវីដេអូ ស្តីពីការពង្រឹងដំណើរការ នៃការធ្វើមាតុភូមិនិវត្តន៍ សម្រាប់ជួយជនរងគ្រោះដោយសារការជួញដូរមនុស្សសញ្ជាតិកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **មុំ ប៊ុនថន** រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ៩.ផែនការបណ្តុះបណ្តាលការ កំនត់អត្តសញ្ញាណជនរងគ្រោះ"។ ១០.រៀបចំបង្កើតតារាងទិន្នន័យជនរងគ្រោះដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់"។ ១១.កិច្ចពិភាក្សា ការងារស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីជួយជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសនានា អំឡុងពេលរាតត្បាតកូវីដ-១៩" តាមប្រព័ន្ធអនឡាញ ZOOM ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការអភិវឌ្ឍន៍នានា ក្នុងប្រទេសកម្ពុជា។ ១២.កិច្ចប្រជុំពិភាក្សាស្តីពី "បែបបទ ផែនការសកម្មភាពការងារ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រាប់ដាក់បញ្ចូលផែនការជំរុញអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ" នៅសាលប្រជុំគ.ជ.ប.ជ។

- ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញដឹកនាំក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ចូលរួមកិច្ចប្រជុំពិភាក្សាតាមរយៈប្រព័ន្ធវីដេអូស្តីពី "**វឌ្ឍនភាពនៃការអនុវត្តគម្រោងសាកល្បង វគ្គបណ្តុះបណ្តាលថ្នាក់បឋមសិក្សារ វាងកម្ពុជា និងថៃ នៅខេត្តកោះកុង និងខេត្តត្រាត**" ចំនួន ០៣លើក ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា។

- ថ្នាក់ក្រោមជាតិ
  - **ខេត្តព្រៃវែង៖** បានដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ណែនាំដល់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងករណីពពោះជំនួស ដើម្បីជៀសផុតពីការជួញដូរមនុស្ស និងល្បិចកលជនល្មើស ដែលមានអ្នកចូលរួម ៨៤នាក់ ស្រី ១០នាក់។

## ខ.២. ការទទួលជួបពិភាក្សាការងារ

- ថ្នាក់ជាតិ
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជំនួបពិភាក្សាការងារជាមួយ៖
    - លេខាទូតរួមនិងក្រុមការងារ ដែលទទួលបន្ទុកកិច្ចការសិទ្ធិមនុស្សរបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ស្តីពីលទ្ធផលសកម្មភាពការងារនានា មានកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ ការបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស ការពង្រឹងការអនុវត្តច្បាប់ និងកិច្ចការយុត្តិធម៌ ដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រសួង-ស្ថាប័ន អង្គភាពជំនាញពាក់ព័ន្ធ និងអង្គការដៃគូអភិវឌ្ឍសម្រេចបានកន្លងមក ជាពិសេសការផ្តល់កិច្ចការពារ និងសេវាគាំទ្រជូនជនរងគ្រោះដោយអំពើជួញដូរ និងពលករចំណាកស្រុកដែលវិលត្រលប់ ក្នុងតំណាក់កាលការរីករាលដាលជំងឺកូវីដ-១៩ ។

- ក្រុមប្រឹក្សាជាតិដើម្បីកុមារ ពីកិច្ចសហការលើការរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅសាលប្រជុំ គ.ជ.ប.ជ។
- ជំនួបពិភាក្សា និង ប្រគល់-ទទួលអំណោយ ដែល ឧបត្ថម្ភកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (With compliment from ASEAN -ACT)។ ការអញ្ជើញចូលរួមក្នុងពិធីនេះមាន លោកជំទាវអគ្គលេខាធិការ ឯកឧត្តម លោកជំទាវអគ្គលេខាធិការរង លោកប្រធាននាយកដ្ឋានការពារជនរងគ្រោះ លោកទីប្រឹក្សា នៃ គ.ជ.ប.ជ និងតំណាងអង្គការASEAN-ACT ប្រចាំកម្ពុជា នៅសាលប្រជុំ អគ្គលេខាធិការ វត្តមានអង្គប្រជុំ មាន០៨នាក់ ស្រី ០៤នាក់ ។
- តំណាងរបស់អង្គការវីនរ៉ក់ អំពីកិច្ចសហការរវាងកម្មវិធី Cambodia CTIP/Winrock Int'l ជាមួយនិង គ.ជ.ប.ជ នៅការិយាល័យរបស់លោកជំទាវផ្ទាល់។
- អង្គការដៃគូអភិវឌ្ឍ និងអ្នកផ្តល់ប្រឹក្សាលើរបាយការណ៍ថ្នាក់ជាតិរបស់គ.ជ.ប.ជ មានតំណាងពីអង្គការការីតាសកម្ពុជា អង្គការUNFPA អង្គការIJM អង្គការCambodia-Act និងអង្គការជាដៃគូអភិវឌ្ឍមួយចំនួនទៀត អំពីផែនការសកម្មភាពការងារ និងគម្រោងការបោះពុម្ពផ្សព្វផ្សាយរបាយការណ៍ ឯកសារពាក់ព័ន្ធសំខាន់ៗផ្សេងទៀត សម្រាប់គ.ជ.ប.ជ ប្រើប្រាស់ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគម្រោង នៃការបង្កើតប្រព័ន្ធបញ្ចូលទិន្នន័យពលករ ក្នុងការគ្រប់គ្រងលំហូរពលករចេញចូល ទៅកាន់ប្រទេសគោលដៅ។

- **ថ្នាក់ក្រោមជាតិ៖**

- **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មន្ទីរកិច្ចការនារីខេត្ត និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ទទួលជួបពិភាក្សាការងារ ជាមួយអង្គការដៃគូបានចំនួន ០៥លើក៖
  - សង្គ្រោះដោតវាសនា ស្តីពីកិច្ចសហការលើការរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។
  - អង្គការដៃនដីមនុស្សហូរឡង់ដ៏ប្រចាំកម្ពុជា ស្តីពីការបញ្ចប់គម្រោងធ្វើការរួមគ្នាដើម្បីកុមារ (WATCH) និងពិភាក្សាលើការអនុវត្តគម្រោងថ្មីលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការផ្តល់នូវសម្ភារសម្រាប់ប្រើប្រាស់នៅក្នុងការិយាល័យចំនួន ០២លើក។
  - អង្គការសម្ពន្ធភាពដើម្បីកុមារ លើករណីការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ និងការផ្តល់សម្ភារសម្រាប់ការពារនៃការរីករាលដាលនៃជំងឺកូវីដ១៩ ចំនួន ០១លើក។ និង
  - ស្តីពីការអនុវត្តគម្រោងលើកម្ពស់ និងពង្រឹងអំណាចសេដ្ឋកិច្ចទៅលើវិស័យសេដ្ឋកិច្ចគ្រួសារ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាធ្ងន់ធ្ងរផ្នែកយេនឌ័រនៅក្នុងចំណោមពលករចំណាកស្រុកដែលបានវិលត្រឡប់មកកម្ពុជាវិញ តាមប្រព័ន្ធអនឡាញ ចំនួន ០១លើក។
- **ខេត្តព្រៃវែង៖** លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត
  - បានជួបសំណេះសំណាលការងារ និងសម្តែងការគួរសមជាមួយក្រុមការងារនៃអង្គការ បេសសកម្មយុត្តិធម៌អន្តរជាតិ ប្រចាំកម្ពុជា ស្តីពីភាពជាដៃគូក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
  - បានជំនួបពិភាក្សាការងារជាមួយអង្គការកុមារអាស៊ីប្រចាំកម្ពុជា អំពីដំណើរការនៃការគាំទ្រដល់មណ្ឌលកុមារកំព្រាខេត្ត។

### ខ.៣. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ ៣៤៧លើក មានអ្នកចូលរួមសរុប ៤.៨៧៩នាក់ (ស្រី ២.៣៧២នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១៦១លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២៥លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១៥លើក ក្រសួងអប់រំ យុវជន និងកីឡា ០៥លើក ក្រសួងកិច្ចការនារី ០៣លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ០៣លើក អង្គការរតនៈអ៊ីនធើណេសិនណល ០៥លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ១៣០លើក។ (ឧបសម្ព័ន្ធ១)

## IV.ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្ស ជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិ ផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួន នៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ជាប្រចាំ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V.ទិសដៅឆមាសទី២ ឆ្នាំ ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

**ក.ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ**

ក.១. គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើម្បីបន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពោះជំនួស។

ក.៣. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ ។

ក.៤. បន្តពង្រឹង និងជំរុញការអនុវត្ត អនុស្សរណៈ កិច្ចព្រមព្រៀង ស្តង់ដារនៃនីតិវិធីប្រតិបត្តិ ដែលមានស្រាប់ជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធ។

ក.៥. ត្រៀមចុះហត្ថលេខាលើស្តង់ដារនៃនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការអនុវត្តច្បាប់។

ក.៦. ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍របស់ក្រសួងសុខាភិបាល។

ក.៧. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីកសាងបទដ្ឋានគតិយុត្តិនានា សម្រាប់ការពារសិទ្ធិ សុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូរបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។

ក.៨. ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការ ទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។

ក.៩. ត្រៀមបន្តចុះហត្ថលេខាអនុស្សរណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធ។

**ខ.ការងារបង្ការ ទប់ស្កាត់**

ខ.១. សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំយុទ្ធនាការ "គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម"។

ខ.២. ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សៀវភៅសិក្សាអប់រំស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីសិក្សាកម្រិត បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

ខ.៣. ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ធ្វើការបោះពុម្ពសៀវភៅសិក្សាអប់រំស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" និងបើកវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ គ្រូឧទ្ទេសគរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស។

ខ.៤. សហការជាមួយអង្គការដៃគូ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីរកវិធានការទប់ស្កាត់អំពើរំលោភបំពានគ្រប់ទម្រង់លើកុមារ។

ខ.៥. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយអំពី ឱកាសការងារឱ្យកាន់តែទូលំទូលាយ នៅតាមសហគមន៍ ជាពិសេសសហគមន៍ដែលងាយរងគ្រោះ រួមទាំងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់។

ខ.៦. សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនីតិវិធីងាយស្រួលក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងការទទួលបានការប្រឹក្សាយោបល់ពីទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីជម្រើសការងារ ឬមុខរបរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗ សម្រាប់ក្រុមជនងាយរងគ្រោះ ជាពិសេស ពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីបរទេស។

ខ.៧. បន្តជំរុញការគ្រប់គ្រង និងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាការអនុវត្តគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តរប្រវេសន៍ការងារ។

ខ.៨. បន្តរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងវេទិកាជាតិអន្តរសាសនានៅកម្ពុជាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ខ.៩. បន្តសហការជាមួយអង្គការសហប្រជាជាតិ (IOM, WHO, UNFPA, UNICEF) និងដៃគូផ្សេងៗទៀត ដើម្បីរៀបចំកម្មវិធី ឆ្លើយតបទៅនឹងផលប៉ះពាល់លើសុខភាព និងជីវភាព ពលករទេសន្តប្រវេសន៍ និងគ្រួសារ ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺកូវីដ ១៩ និងគ្រោះមហន្តរាយផ្សេងៗទៀត។

ខ.១០. បន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ការផ្សព្វផ្សាយអំពីការបង្ការ ទប់ស្កាត់ ការឆ្លង និងចម្លងជំងឺកូវីដ ១៩ និងផលប៉ះពាល់ ព្រមទាំងចុះតាមដានការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។

ខ.១១. បន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទំនាក់ទំនងរវាងទេសន្តប្រវេសន៍និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងនិងក្រៅសាលារៀន និងជនងាយរងគ្រោះដទៃទៀត។

ខ.១២. បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ដើម្បីកំណត់រកអំពើកេងប្រវ័ញ្ចផ្សេងៗ និងមានវិធានការ ក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមរោងចក្រសហគ្រាស សហគ្រាសឡតដុត កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្ត ជាដើម។

ខ.១៣. បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ចំពោះទីភ្នាក់ងារជ្រើសរើសពលករឯកជន។

ខ.១៤. លើកកម្ពស់ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងការអនុវត្តក្រមសីលធម៌ របស់ទីភ្នាក់ងារ និងកាត់បន្ថយការយកថ្លៃឈ្នួលពីពលករ ក្នុងនីតិវិធីនៃការជ្រើសរើសពលករទេសន្តប្រវេសន៍។

ខ.១៥. បន្តរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន ។

**គ.ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ**

គ.១. បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

គ.២. បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ។

គ.៣. បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។

គ.៤. បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។

គ.៥. ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

**ឃ.ការងារការពារជនរងគ្រោះ**

ឃ.១. ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ នៅក្នុងវដ្តនៃទេសន្តប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តប្រវេសន៍ ជាពិសេស ដើម្បីផ្តល់ សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ដោយអាជ្ញាធរបរទេស និងពលករដែលវិលត្រឡប់ពីប្រទេសគោលដៅតាមច្រកព្រំដែនសំខាន់ៗ។

ឃ.២. សហការជាមួយអង្គការការីតាសស្វីស និងរដ្ឋបាល ខេត្តបាត់ដំបង សាងសង់ និងដាក់ឲ្យដំណើរការមណ្ឌលទទួលពលករ នៅស្រុកកំរៀង ។

ឃ.៣. រៀបចំយន្តការសម្រាប់ការទទួលពលករ និងការគ្រប់គ្រង និងដំណើរការមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្តា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការផ្តល់សេវា។

ឃ.៤. រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន ។

ឃ.៥. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ៖

- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់មន្ត្រីជួរមុខ។
- កម្មវិធីគ្រប់គ្រងករណីដល់មន្ត្រីដែលអនុវត្ត និងអ្នកពាក់ព័ន្ធទាំង២៥ រាជធានី ខេត្ត។

ឃ.៦. ធ្វើបច្ចុប្បន្នភាពលើសាវាចរ ស្តីពី នីតិវិធីប្រគល់ និងទទួល ជនរងគ្រោះដោយសារការជួញដូរមនុស្ស(SOPs) រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

ឃ.៧. បន្តកិច្ចសហប្រតិបត្តិការជាមួយៈ

- ក្រសួងយុត្តិធម៌ដើម្បីរៀបចំឱ្យមានមន្ត្រីសង្គមកិច្ចចូលរួមក្នុងប្រព័ន្ធតុលាការ នៅតាមសាលាដំបូង រាជធានី ខេត្ត។
- ក្រសួងសុខាភិបាល ក្នុងការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។
- ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស) ដើម្បីជួយដល់ជនរងគ្រោះ និងសម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។
- ក្រសួងស្ថាប័ន និងអង្គការដៃគូ ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- មន្ត្រីថ្នាក់ក្រោមជាតិ ក្នុងដំណើរការស្វែងរក ប៉ាន់ប្រមាណគ្រួសារ តាមដាន សមាហរណកម្ម និងបិទករណីរបស់ជនរងគ្រោះ។
- ភាគីថៃសម្រាប់ដំណើរការកសាងមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះគ្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

ឃ.៨. បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ឃ.៩. ពិនិត្យលទ្ធភាពដើម្បីបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។

ឃ.១០.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនៅក្នុងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

ឃ.១១.រៀបចំឧបករណ៍វាយតម្លៃអំពី ភាពប្រឈម និងមេរៀនទទួលបាន នៃ«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្នុងខេត្តដែលបានបណ្តុះបណ្តាលរួចហើយ ។

ឃ.១២.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការផ្តល់សេវា ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍ ។

**ង.ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ**

ង.១.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

ង.២.ធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃ ពាក់កណ្តាលអាណត្តិ ទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ង.៣.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការ

ប្រមូលទិន្នន័យថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្តន្ទាទោស និងការងារការពារជនរងគ្រោះឲ្យមានសង្គតិភាព។

ង.៤.គាំទ្រពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ង.៥.បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត ។

ង.៦.រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ ។

ថ្ងៃ...........ខែ.........ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.........ឆ្នាំ២០២១

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ៣៤៧លើក) មនុស្សចំនួន ៤.៨៧៩នាក់ (ស្រី ២.៣៧២នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | **គណៈកម្មាធិការជាតិបានដឹកនាំសម្របសម្រួល ចំនួន ១៦១លើក អ្នកចូលរួមសរុបចំនួន ១.០៥៧នាក់ (ស្រី ២៥០នាក់)**<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ (១)ចុះទៅជួបសំណេះសំណាលជាមួយក្រុមការងារធ្វើចត្តាលីស័ក នៅសាលាព្រហ្មនិមិត្ត សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (២)ជាអធិបតីភាពក្នុងពិធីប្រគល់-ទទួលសម្ភារប្រើប្រាស់ចាំបាច់សម្រាប់ស្ត្រី និងកុមារ ក្នុងស្ថានភាពប្រឈមជំងឺកូវីដ១៩ ពីអង្គការអភិវឌ្ឍន៍ UNFP។ (៣)ធ្វើទស្សនៈកិច្ចក្នុងទីស្នាក់ការអង្គការ តំណក់ទឹក ដែលជាអង្គការធ្វើកិច្ចសហប្រតិបត្តិការផ្តល់សេវាផ្នែកអប់រំ វិជ្ជាជីវៈ ទៅកាន់កុមារដែលងាយរងគ្រោះ នៅខេត្តបន្ទាយមានជ័យ។ (៤)កិច្ចប្រជុំពិភាក្សាអំពី "វឌ្ឍនភាពនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រឈម និងដំណោះស្រាយ" ជាមួយឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ វត្តមានចូលរួមចំនួន **៣៣**នាក់ ស្រី **១២**នាក់។ (៥)កិច្ចប្រជុំ របាយការណ៍ "ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១" នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន **១០៥**នាក់ ស្រី **៥៩**នាក់។ (៦)ពីធីសម្ពោធការចាប់ផ្តើមអនុវត្តន៍គម្រោងបញ្ចប់អំពើហឹង្សាលើកុមារនៅក្នុង និងជុំវិញសាលារៀន "End Violence Against Children Project ( EDN VAC ) in and around school " នៅសណ្ឋាគារសាន់វេភ្នំពេញ ដោយមានការរៀបចំសម្របសម្រួលអង្គការ Save the Children ដែលមានអ្នកចូលរួមសរុប៥០នាក់ ។ (៧)កិច្ចប្រជុំត្រួតពិនិត្យ កែសម្រួលទៅលើសេចក្តីព្រាង គោលនយោបាយជាតិស្តីពី សុខភាពជនទេសន្តរប្រវេសន៍ នៅសាលប្រជុំគ.ជ.ប.ជ។ (៨)ដឹកនាំក្រុមការងារគ.ជ.ប.ជ លោកស្រីអភិបាលរងខេត្តសៀមរាម រួមនិងប្រធានអង្គការអាយអូអឹម អង្គការWHO អង្គការយូនីសេហ្វ អង្គការយូអិនអេហ្វភីអេ អង្គការជីគីអូ មន្ត្រីគម្រោង RCO បានចុះតាមដាន ត្រួតពិនិត្យការអនុវត្តផែនការគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន សម្រាប់ពលករទេសន្តរប្រវេសន៍ ក្នុងតំណាក់កាលកូវីដ-១៩ នៅសាលាស្រុកក្រឡាញ់ ខេត្តសៀមរាប។ (៩) ដឹកនាំក្រុមការងារ និងអង្គការដៃគូអភិវឌ្ឍ បានចុះសាកសួរ និងសំណេះសំណាលផ្ទាល់ជាមួយ និងប្រជាពលរដ្ឋ ដែលជាពលករទេសន្តរប្រវេសន៍ទើបវិលត្រលប់ពីក្រៅប្រទេស ស្ថិតក្នុងភូមិល្បើក ឃុំដូនកែវ ស្រុកពួក និងភូមិ-ឃុំចាន់ស ស្រុកសូត្រនិគម ខេត្តសៀមរាប និងបានចុះទស្សនកិច្ច ពិនិត្យផ្ទាល់ទៅដល់ទីកន្លែងសួនច្បារដំណាំ និងរោងចិញ្ចឹមសត្វ ដែលពួកគាត់ទទួលបានពីការឧបត្ថម្ភគាំទ្រ ពីគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ។ (១០)ពិធីប្រគល់ទទួលសម្ភារដែលឧបត្ថម្ភដោយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(With compliment from ASEAN-ACT ) ពីតំណាងអង្គការ ASEAN-ACT ប្រចាំកម្ពុជា នៅសាលប្រជុំគ.ជ.ប.ជ មានអ្នចូលរួម ០៨នាក់ ស្រី០៤នាក់។ (១១)សកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ របស់ក្រសួងសុខាភិបាល នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (១២)ប្រគល់ទទួល សម្ភារៈ ជាម៉ាសចំនួន |

| | |
|---|---|
| | ៥កេស ធំ ពីតំណាងអង្គការការីតាសកម្ពុជា ជូនអគ្គលេខាធិការដ្ឋានគ ជ.ប.ជ.នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ **(១៣)**នាំយកនូវអំណោយ ផ្តល់ជូនរដ្ឋបាលក្រុងកំពង់ឆ្នាំងដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្តមានលោកស្រីអភិបាលរងខេត្ត លោកអភិបាលក្រុង និងមន្ត្រីចំណុះរដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រាប់ចែកជូនពលករវិលត្រឡប់ និងប្រជាជនដែលកំពុងធ្វើច័ត្តាឡីស័ក ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩។ (១៤)ចូលរួមកិច្ចប្រជុំអនឡាញលើកិច្ចពិភាក្សារវាង ASEAN-ACT និងគ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបង្កើនកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព។ **(១៥)**ក្នុងពិធីប្រគល់ទទួលសម្ភារៈការិយាល័យ មានតុ៥សម្រាប់ ជូនរដ្ឋបាលសាលាស្រុកកំរៀង ប្រើប្រាស់ក្នុងមណ្ឌលទទួលពលករកំរៀង ស្ថិតក្នុងឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ដែលអមដំណើរដោយលោកជំទាវឧត្តមសេនីយ៍ឯក **វេជ្ជ. ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ ឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ចាន់ណារុំ** អគ្គលេខាធិការរង លោកស្រី **ស៊ុំ ចិន្តា** អភិបាលរងខេត្តបាត់ដំបង លោកស្រីស្នងការរងនគរបាលបាលខេត្ត លោក ទិត្យ សត្យា អភិបាលរងស្រុកកំរៀង តំណាងពីមន្ទីរពាក់ព័ន្ធ មានមន្ទីរការងារ មន្ទីរសង្គមកិច្ច មន្ត្រីរដ្ឋបាលស្រុកកំរៀង ប្រធាន និងតំណាងអង្គការការីតាសស្វីសនៅមណ្ឌលទទួលពលករកំរៀងខេត្តបាត់ដំបង។ (១៦)ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមទេសរដ្ឋមន្ត្រី **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដែលបានធ្វើកាលកិរិយា ក្នុងជន្មាយុ៧៣ឆ្នាំ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២១ វេលាម៉ោង១៤ និង២៥នាទី។ **(១៧)**ប្រគល់ និងទទួលសៀវភៅ របាយការណ៍លទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០២០ និងទិសដៅ អនុវត្តឆ្នាំ២០២១ របស់ គ.ជ.ប.ជ ក្រតំណាងអង្គការអាស៊ាន-អាក់ Asian-Act ដែលជាអ្នក ឧបត្ថម្ភគាំទ្រដល់ការបោះពុម្ពផ្សាយរបាយការណ៍នេះ និងមានការអញ្ជើញចូលរួមពី ឯកឧត្តមលោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន និងមន្ត្រីក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **(១៨)**ដឹកនាំក្រុមការងារតាមដានត្រួតពិនិត្យ គោលនយោបាយរាជរដ្ឋាភិបាលខេត្តកំពង់ឆ្នាំង រួមនិងក្រុមការងារ លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការគ.ជ.ប.ជ លោកជំទាវ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង ឯកឧត្តម **យ៉ែម ចាន់ណារុំ** អគ្គលេខាធិការរង បាននាំយកនូវអំណោយជាសម្ភារៈប្រើប្រាស់ សម្ភារៈប្រើប្រាស់ជា(កញ្ចប់) ចំនួន៥០ ដែលបានមកពីការឧបត្ថម្ភគាំទ្រអង្គការUNFPA ផ្តល់ជូនរដ្ឋបាលក្រុងកំពង់ឆ្នាំងដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្តមាន លោកអភិបាលរងក្រុង និងមន្ត្រីចំណុះរដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រាប់ផ្តល់ជូនពលករវិលត្រឡប់ និងប្រជាជនដែលកំពុងធ្វើច័ត្តាឡីស័ក ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ នៅក្រុងកំពង់ឆ្នាំង។ សម្ភារៈសម្រាប់ផ្តល់ជូនបងប្អូនពលករ ក៏ដូចប្រជាពលរដ្ឋអាចទទួលបាន ក្នុងម្នាក់ៗទទួលបានមួយកញ្ចប់មាន៖ សារ៉ុង១ ក្រម៉ា១ សាប៊ូម្សៅ សាប៊ូដុំ ដែលលាងដៃ ម៉ាស់មួយប្រអប់ សំឡីអនាម័យ ថ្នាំដុសធ្មេញ ច្រាស់ដុសធ្មេញ។ **(១៩)**ដឹកនាំតាមដានត្រួតពិនិត្យគោលនយោបាយ ភូមិ/ឃុំមានសុវត្ថិភាពខេត្តកំពង់ឆ្នាំង និងថ្នាក់ដឹកនាំ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានលោកជំទាវ **ប៉ុណ្ណ សំខាន់**អគ្គលេខាធីការលោកជំទាវ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង ឯកឧត្តម **យ៉ែម ចាន់ណារុំ** អគ្គលេខាធិការរង បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសិកា **អ៊ុន គឹមសាន** ត្រូវជាម្តាយបង្កើតឯកឧត្តម **ហ៊ី ណាត** ទីប្រឹក្សាក្រសួងមហាផ្ទៃ ដែលបានទទួលមរណៈកាលពីថ្ងៃអង្គារ ១៣កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ វេលាម៉ោង១៥ និង២នាទីរសៀល ក្នុងជន្មាយុ ៩១ឆ្នាំ ដោយរោគាពាធ ដែលសពបានតំកល់ធ្វលបុណ្យ នៅគេហដ្ឋានរបស់ឯកឧត្តម បិតក្នុងភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង។ |

| | |
|---|---|
| | ▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ (១)កិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារមានអាយុក្រោម២ឆ្នាំ និងកម្មវិធីឧបត្ថមសាច់ប្រាក់ជូនគ្រួសារ ក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ១៩ ក្នុងឆ្នាំ២០២០ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២១ នៅសណ្ឋាគារភ្នំពេញ។ (២)ដឹកនាំកិច្ចប្រជុំសម្របសម្រួល ស្តីពី ១.ការវាយតម្លៃលើកម្រងសំណួរលក្ខណៈវិនិច្ឆ័យប្រចាំឆ្នាំ២០២០ របស់រាជធានី-ខេត្ត ២.កិច្ចប្រជុំរៀបចំឯកសា បញ្ចប់អនុស្សរណៈយោគយល់គ្នា រវាងគណៈកម្មាធិកាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាគមន៍មូលនិធិ **ឈាន ឆាយ** ដើម្បីមនុស្សធម៌ ៣.កិច្ចប្រជុំត្រៀម រវាងគណៈកម្មាធិកាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ WE WORLD ONLUS អ្នកចូលរួមចំនួន១០នាក់ ស្រី០១នាក់។ (៣)សិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជនក្នុងការអនុវត្តផែនការសកម្មភាពគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៩ នៅសណ្ឋាគារសាន់វេភ្នំពេញ។ (៤)ដឹកនាំសម្របសម្រួលសកម្មភាពពិនិត្យ និងបូកសរុបឯកសារនៃកិច្ចសហប្រតិបត្តិការ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយបណ្តា ប្រទេសជាមិត្ត និងអង្គការដៃគូជាតិ អន្តរជាតិពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន០៥នាក់ ស្រី០១នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។ (៥)សិក្ខាសាលា ស្តីពីការអភិវឌ្ឍន៍សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ឆ្នាំ២០២១ដល់ឆ្នាំ២០៣០ ក្រោមអធិបតីភាព ឯកឧត្តម **ស៊ា ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសណ្ឋាគារប៉ារ៉ាឌី ខេត្តសៀមរាប។ (៦)ពិធីបិទកិច្ចពិភាក្សាអំពីផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ នៅសណ្ឋាគារ ផារ៉ាដាយអង្គរ ខេត្តសៀមរាប។ (៧)ដឹកនាំបន្តពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ WE WORLD ONLUS និងវាយតម្លៃកម្រងសំណួររាជធានី-ខេត្ត នៅសាលប្រជុំ គ.ជ.ប.ជ។ (៨)បិទអង្គសិក្ខាសាលា ស្តីពីការបំប៉នគ្រូឧទ្ទេសលើការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការប្រើប្រាស់សៀវភៅ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកំពង់ចាម។ (៩)កម្មវិធីប្រគល់-ទទួល សម្ភារៈបច្ចេកវិទ្យាអនឡាញសម្រាប់ប្រើប្រាស់ ក្នុងបន្ទប់ប្រជុំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបើកវគ្គបណ្តុះបណ្តាលអនឡាញ ទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសោមាទេវីអង្គរ ខេត្តសៀមរាប។ -(១០)កិច្ចប្រជុំកែសម្រួលសេចក្តីព្រាងចុងក្រោយ ស្តីពីស្តង់ដារនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ កម្ពុជា-ថៃ "Pending points from the bilateral meeting" ជាមួយតំណាងអង្គការ IOM ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅប្រជុំ គ.ជ.ប.ជ។ (១១)កិច្ចប្រជុំពិភាក្សាលើចំណុចសេសសល់ទ្វេភាគីកម្ពុជា-ថៃ អំពីសេចក្តីព្រាងចុងក្រោយ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់រវាងកម្ពុជា-ថៃ SOP ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួម ២៩នាក់ ស្រី០៦នាក់។ (១២)ប្រជុំតាមវីដេអូរ (Conference Video) រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ប្រទេសថៃ ស្តីពី "ស្តង់ដារនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់" ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានអ្នកចូលរួមចំនួន ៣២នាក់ ស្រី ០៨នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ ។ (១៣)ដឹកនាំក្រុមការងារដើម្បីយកខ្លឹមសារ នីតិវិធីស្តង់ដារប្រតិបត្តិ SOP ស្តីពីនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ប្រទេសថៃ ដើម្បីសុំការសម្របសម្រួលចង្អុលបង្ហាញ |

| | |
|---|---|
| | និងកែសម្រួលភាសាខ្មែរមួយចំនួនពី ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ (១៤)កិច្ចប្រជុំរវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកជំទាវ **យូ សុភា** អភិបាលរងខេត្តសៀមរាប ប្រធានអង្គការ IOM ប្រចាំប្រទេសកម្ពុជា ប្រធានអង្គការយូនីសេហ្វ UNICEF អង្គការដៃគូអភិវឌ្ឍមាន តំណាងអង្គការយូអិនអេហ្វ ភីអេ UNFPA ជាមួយនឹងមន្ត្រីអភិបាលស្រុក ឃុំ សង្កាត់ និងមេភូមិ បងប្អូនប្រជាពលរដ្ឋ និងបងប្អូនដែលទើបវិលត្រលប់ពីក្រៅប្រទេស គោលបំណងដើម្បីតាមដានត្រួតពិនិត្យ និងសិក្សាស្វែងយល់ពីគម្រោងអនុវត្តរួមគ្នារវាងរាជរដ្ឋាភិបាល និងយូអិន នៅក្នុងរដ្ឋបាលស្រុក ឃុំ និងអង្គការដៃគូរអភិវឌ្ឍ នៅសាលាឃុំចាន់ស ស្រុកសូត្រនិគម ខេត្តសៀមរាប។ (១៥)ដឹកនាំសកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរណៈយោគយល់រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ We World Onlus នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (១៦)ដឹកនាំពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ជំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពជំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ នៅ គ.ជ.ប.ជ។ (១៧)ដឹកនាំសកម្មភាពពិភាក្សាផ្តល់ចម្លើយតបជូនទៅអង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង(Global Initiative against Transnational Organized Crime) ទាំង១២សំណួរពាក់ព័ន្ធអំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ។ (១៨)ដឹកនាំកិច្ចពិភាក្សាបំពេញបន្ថែមចូលទៅក្នុងឯកសារពីរប្រភេទ របស់ក្រសួងមហាផ្ទៃ ដើម្បីឆ្លើយតបក្នុងអនុសាសន៍នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ២០១៩ ជុំទី៣ និងឆ្លើយតបសេចក្តីសង្កេតសន្និដ្ឋាន នៃរបាយការណ៍ជាតិក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(ICERD) ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ (១៩)ពិធីបើកវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធវីដេអូ **«ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍»** ក្រោមអធិបតីភាពឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។ រៀបចំដោយក្រសួងមុខងារសាធារណៈ និងធនាគារពិភពលោក និងទទួលបានការឧបត្ថម្ភដោយ រដ្ឋាភិបាលអូស្ត្រាលី និងសហភាពអឺរ៉ុប នៅសាលប្រជុំ គជ។.ប.ជ. (២០)កិច្ចប្រជុំតាមរយៈប្រព័ន្ធវីដេអូ ស្តីពីការពង្រឹងដំណើរការ នៃការធ្វើមាតុភូមិនិវត្តន៍សម្រាប់ជួយជនរងគ្រោះដោយសារការជួញដូរមនុស្ស សញ្ជាតិកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **មុំ ប៊ុនថន** រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ (២១)បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី**«ភាពជាអ្នកដឹកនាំ និង នវានុវត្តន៍»** តាមរយៈប្រព័ន្ធវីដេអូ រៀបចំដោយ ក្រសួងមុខងារសាធារណៈ និងសាលាភូមិន្ទរដ្ឋបាល ERA មានការសហការជាមួយ Word Bank និងឧបត្ថម្ភគាំទ្រដោយ រដ្ឋាភិបាលអូស្ត្រាលី និងសហគមន៍អឺរ៉ុប។ កិច្ចប្រជុំនេះមានសមាសភាពចូលរួមសរុបចំនួន **១១២**នាក់។ (២២)សិក្ខាសាលាប្រចាំឆមាសរបស់សមាជិកអង្គការសម្ព័ន្ធចាប់ដៃទាំង៥៣អង្គការ ស្តីពីប្រធានបទ **"ចលនាឆ្ពោះទៅមុខចេញពីបរិបទកូវីដ១៩ការសម្របខ្លួនទៅនឹងបរិបទរស់នៅសារជាថ្មី"** តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ (២៣)ពិធីប្រគល់ទទួល សម្ភារៈ ជាម៉ាសចំនួន ៥កេសធំ ពីតំណាងអង្គការការីតាស់កម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។ (២៤)កិច្ចប្រជុំស្តីពីសកម្មភាពការងារជាអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មានអ្នកចូលរួមចំនួន **១៩**រូប ស្រី **០៣**រូប។ (២៥)រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ដើម្បីផ្ញើទៅអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **២២**រូប ស្រី **០៥**រូប។ (២៦)កិច្ចប្រជុំពិភាក្សាតាមអនឡាញរវាង ASEAN-ACT និងគ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបង្កើនកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព និងផ្តោតសំខាន់ទៅលើ |

| | |
|---|---|
| | គម្រោងរយៈពេលមួយឆ្នាំរបស់ ASEAN-ACT ក្នុងការជំរុញការអនុវត្តអនុសញ្ញា និងផែនការអាស៊ានស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៅសាលប្រជុំគ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** (១)លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៤៥ច្បាប់ លិខិតចូល ២៥ច្បាប់។ (២)លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៤១ច្បាប់ លិខិតចូល ៣៣ច្បាប់។ (៣)រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។ ៤-ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី។ (៥)បូកសរុបរបាយការណ៍ប្រចាំសប្ដាហ៍ និងប្រចាំខែ ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (៦)បូកសរុបរបាយការណ៍ខែ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ (៧)ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។ (៨)រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។ (៩)ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី ៤៣សកម្មភាព។ (១០)អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ១៨០ច្បាប់។ (១១) សហការជាមួយក្រុមការងារ ចម្រុះទទួលពលករ) ប៉ោយប៉ែត (ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពលករ បញ្ជូនត្រលប់ពីប្រទេសថៃ តាមប្រព័ន្ធបញ្ចូលទិន្នន័យស្វ័យប្រវត្តិ។(១២)ចុះបំពេញបេសកកម្មនៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន។ (១៣)-បង្កើតផេកថ្មីក្នុងបណ្ណាល័យវីគីសម្រាប់រក្សាទុកឯកសារ និងរូបភាពសកម្មភាពរបស់ លោកជំទាវ។ (១៤)- ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ (១៥)-លិខិតស្នើសុំបង់ថ្លៃអ៊ិនធើណេតសម្រាប់ខែ មិថុនា ឆ្នាំ២០២១។ (១៦)-ធ្វើបច្ចុប្បន្នភាពការងារព័ត៌មាន ទៅក្នុងគេហទំព័រ និងតាមបណ្ដាញទំនាក់ទំនងសង្គមផ្លូវការរបស់ គ.ជ.ប.ជ ស្ដីអំពីសកម្មភាពការងារថ្នាក់ដឹកនាំ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (១៧)-ការសហការ ស្រាវជ្រាវ ប្រមែប្រមូល ព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការពិនិត្យ វិភាគ សន្និដ្ឋាន វាយតម្លៃរាល់សកម្មភាព ដែលទាក់ទង នឹងអំពើជួញដូរមនុស្ស។ (១៨)-សហការជាមួយក្រុមការងារ ចម្រុះទទួលពលករ (ប៉ោយប៉ែត) ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពលករ បញ្ជូនត្រឡប់ពីប្រទេសថៃ តាមប្រព័ន្ធបញ្ចូល ទិន្នន័យស្វ័យប្រវត្តិ។ (១៩)-ថែទាំប្រព័ន្ធអ៊ិនធើណែត និងម៉ាស៊ីន Sever និងអនុវត្តការងារជាក់ស្ដែងមួយចំនួន ដែលថ្នាក់ដឹកនាំដាក់បញ្ជាមក។ (២០)-ចូលរួមពិភាក្សាការងារ ស្ដីពីរបៀបរបបការងារ នៃការប្រព្រឹត្តិទៅមណ្ឌលទទួលពលករប្រចាំមណ្ឌលទទួលពលករស្រុកកំរៀង ខេត្តបាត់ដំបងជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (២១)-ធ្វើ Backdrop ពិធីចុះអនុស្សរណៈយោគយល់គ្នា រវាងគ.ជ.ប.ជ និងអង្គការវីវើលអនលូស( We World Onlus)។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>១.បានចូលរួមកិច្ចប្រជុំរៀបចំឯកសារបទបង្ហាញ សម្រាប់អង្គសិក្ខាសាលា ស្ដីពីវគ្គបំប៉នគ្រូឧទ្ទេសថ្នាក់ជាតិ លើការប្រើប្រាស់ សៀវភៅអប់រំ ស្ដីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ក្រោមការដឹកនាំលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំក្រសួងអប់រំ។ ២.ចូលរួមកិច្ចប្រជុំពិនិត្យ និងវាយតម្លៃការផ្ដល់ពិន្ទុជូន គ.រ.ប.ជ/គ.ប.ខ.ជ ឆ្នាំ២០២០ នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម ២៤នាក់ ស្រី ០៣នាក់។ ៣.បានចូលរួមពិភាក្សា ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្ដីពីសំណើសុំផ្ដល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្ដល់ជាតុចូលលើផែនការ សកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់(២០១៧-២០៣០)។ |

| | |
|---|---|
| | ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ ៤.បានទទួលការចាត់តាំងដើម្បីដើម្បីចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពីការបាត់ខ្លួនជនទេសន្តរប្រវេសន៍អំឡុងពេលទេសន្តរប្រវេសន៍អន្តរជាតិ ក្រោមការសម្របសម្រួល ពីតំណាងអង្គការដៃគូមកពីប្រទេសពាក់ព័ន្ធមួយចំនួនផងដែរ។ ៥.ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត) Topic: 2nd Consultation Workshop on Ethical Recruitment Process (Virtual) តាមប្រព័ន្ធវីដេអូអនឡាញ ហ្ស៊ូម ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ ឧត្តមសេនីយ៍ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ មានការរៀបចំសម្របសម្រួល ដោយអង្គការសង់គ្រាល់។ ៦.ចូលរួមសិក្ខាសាលាប្រចាំឆមាសរបស់សមាជិកអង្គការសម្ព័ន្ធចាប់ដៃទាំង៥៣អង្គការតាមប្រព័ន្ធអនឡាញ ស្តីពីប្រធានបទ "**ចលនាឆ្ពោះទៅមុខចេញពីបរិបទកូវីដ១៩ការសម្របខ្លួនទៅនឹងបរិបទរស់នៅសារជាថ្មី**" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ មានសិក្ខាកាមសរុបចំនួន **១៦៣**នាក់។ **៧**.បន្តចូលរួមកិច្ចប្រជុំពិនិត្យទៅលើការអនុវត្តសកម្មភាពអទិភាពសម្រាប់អនុវត្តក្នុងត្រីមាសទី២របាយការណ៍ វឌ្ឍនភាពការងារ និងលើកទិសដៅបន្ត ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ ៨.បានរៀបចំកសាងឯកសារស្នើសុំចុះហត្ថលេខាពី **លោកជំទាវ អគ្គលេខាធិការ** គជ.ប.ជ. ស្តីពី កិច្ចសហការពីនិយ័តករទូរគមនាគមន៍កម្ពុជា ដើម្បីបញ្ជូនការស្នើសុំរត់អក្សរសារទៅតាមបណ្តាញទូរស័ព្ទចល័តទូទាំងប្រទេសក្នុងកម្មវិធីទិវាកុមារអន្តរជាតិ១មិថុនាឆ្នាំ២០២១ ដែលមានខ្លឹមសារថា "**យើងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពលើកុមារ**"។ ៩.ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំខែ របស់ក្រុមការងារបង្ការ ទប់ស្កាត់ ដោយធ្វើការបូកសរុបលទ្ធផលពីបណ្តារាជធានី ខេត្ត និងក្រសួងស្ថាប័នពាក់ព័ន្ធ។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ** ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួម៖<br>១.ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ជាមួយកុមារ និងយុវជនលើសេចក្តីព្រាងផែនការ សកម្មភាពគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៩ ក្រោមអធិបតីភាព លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារសាន់វ៉េ ភ្នំពេញ។ ២.កិច្ចប្រជុំឆ្លងសេចក្តីព្រាងផែនការសកម្មភាព ស្តីពីការរៀបចំសន្នានុក្រម បច្ចេកទេសសព្ទ ក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៃក្រសួងមហាផ្ទៃ រយៈពេល២ឆ្នាំ (២០២១-២០២២) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលជាតិ កម្ពុជា នៅសាលប្រជុំបណ្ឌិត្យសភានគរបាលជាតិកម្ពុជា ជីតជ្ញ។ ៣.កិច្ចប្រជុំ ពិភាក្សាការងារ ជាមួយអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីកិច្ចសហប្រតិបត្តិការការពារជនរងគ្រោះ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៤.បានចូលរួម និងសហការជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ចុះស្វែងយល់ពីបច្ចុប្បន្នភាព ក្នុងការបញ្ជូនពលករត្រឡប់មកវិញ និងការគ្រប់គ្រងពលករដែលតម្រូវអោយធ្វើចត្តាឡីស័ក ចំណុចប្រឈមផ្សេងៗ ដើម្បីរួមគ្នាដោះស្រាយ នៅតាមបណ្តាច្រក នៃខេត្តជាប់ព្រំដែន(ឧត្តរមានជ័យ បាត់ដំបង ប៉ៃលិន) ក្រោមការដឹកនាំរបស់ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ៥.បានចូលរួមអមដំណើរលោកជំទាវ អគ្គលេខាធិការចុះចែកសម្ភារៈមានដូចជា អាល់កុល ម៉ាស់ ជូនបុគ្គលិក សុខាភិបាល និងបានជួបសំណេះសំណាល ជាមួយពលករ ចំនួន ៥០រូប ដែលទើបបានបញ្ជូនត្រឡប់ |

មកពីប្រទេសថៃ នៅមណ្ឌលសំចត ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ៦.បានធ្វើការបូកសរុបរបាយការណ៍ខែឧសភា ឆ្នាំ២០២១ ដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបញ្ជូនមកអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ** លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានចូលរួមកិច្ចប្រជុំ៖

១. សម្របសម្រួលពិនិត្យ កែសម្រួល និងផ្តល់ធាតុចូលទៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៩-២០២១ នៅសាលប្រជុំ គ.ជ.ប.ជ។ ២.ពិភាក្សាជាមួយលោក **អៀង ប៊ុនថន** អ្នកប្រឹក្សាយោបល់ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល ដោយទទួលបានការអនុញ្ញាតចូលជំនួបពិភាក្សាជាមួយឯកឧត្តម **ហៃ ហ៊ុនឡេង** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ស្តីពីការរកដំណោះស្រាយ ឬក៏ជាគោលការណ៍ក្នុងការជួយជំរុញឱ្យពលករចំណាកស្រុក ដែលវិលត្រឡប់មកវិញ ដើម្បីទទួលបានការងារសមស្របធ្វើការនៅក្នុងស្រុក នៅសាលប្រជុំទីភ្នាក់ងារជាតិ។ ៣.ក្រុមជំនួយកិច្ចការ ស្តីពីការរៀបចំតារាងបច្ចុប្បន្នភាព ព័ត៌មាន អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងនានា តាមទម្រង់មួយ ដែលត្រូវបានផ្តល់ឱ្យក្រសួងមហាផ្ទៃ នៅសាលប្រជុំ គ.ជ.ប.ជ។ ៤.លើកទី១ ស្តីពីក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន ក្រោមអធិបតីភាពឯកឧត្តម **ផាត សុផានិត** នៅក្រសួងមហាផ្ទៃ។ **៥.**និងតំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ ជ.ប.ជ.អមដំណើរដោយ **ឯកឧត្តមអគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** បាន អញ្ជើញចូលរួមបើកសិក្ខាសាលាឆ្លុះបញ្ចាំង លទ្ធផលការងារប្រចាំឆ្នាំ នៃគម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព គម្រោងប្រចាំឆ្នាំរបស់អង្គការយែរ សហការជាមួយគ.ខ.ប.ជ ខេត្តកំពង់ស្ពឺ អ្នកចូលរួមសរុបចំនួន **៥០**នាក់ ស្រី **៣៥**នាក់។ **៦.**តំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** អមដំណើរដោយ **ឯកឧត្តមអគ្គលេខាធិការរងទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** ក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងប្រចាំឆ្នាំ របស់អង្គការយែរ ដែលបានសហការជាមួយ គ.ខ.ប.ជ ខេត្តព្រះសីហនុ ក្រោមការគាំទ្រពីមូលនិធិ UNWOMEN និងសហភាពអឺរ៉ុប អ្នកចូលរួមសរុបចំនួន៤៥នាក់ ស្រី**៣២**នាក់។ **៧.**និងតំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គ "គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច អាណត្តិទី២ លើកទី១ ឆ្នាំ២០២១" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដឹកនាំកិច្ចប្រជុំ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ ៨.កិច្ចពិភាក្សាតាមប្រព័ន្ធអនឡាញនិងអនុសាសន៍ ស្តីពីការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ សម្រាប់ជនទេសន្តរប្រវេសន៍ ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយតំណាងពីក្រុមការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការ USAID និងអង្គការដៃគូពាក់ព័ន្ធការងារជួយជនរងគ្រោះពីទេសន្តរប្រវេសន៍ ដោយមានគាំទ្រពីគម្រោងអភិវឌ្ឍន៍របស់ USAID ក្នុងការអនុវត្តការងារនេះ។ ៩.ស្តីពីសកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិរបស់ក្រសួងសុខាភិបាល ក្រោមការសម្របសម្រួលដោយ **លោកជំទាវ ឧត្តមសេនីយ៍**ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ ១០.ពិភាក្សា ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់(២០១៧-២០៣០) ក្រោមសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ ១១.ជំនួបកិច្ចប្រជុំក្រុមអ្នក

ជំនាញក្នុងតំបន់ ស្តីពី"កិច្ចសហប្រតិបត្តិការជំរុញការធ្វើពាណិជ្ជកម្មរវាងវិស័យសាធារណៈ និងឯកជនដើម្បីប្រឆាំងការជួញដូរមនុស្សនៅអាស៊ីប៉ាស៊ីហ្វិក" ដែលមានការសម្របសម្រួលដោយអង្គការ UNODC។ **១២**.សិក្ខាសាលាពិគ្រោះយោបល់លើកទី២ តាមវីដេអូ ZOOM ស្តីពីដំណើរការជ្រើសពលករប្រកបដោយក្រមសិលធ៌ម( និម្មិត ) ក្រោមការដឹកនាំសម្របសម្រួលរបស់លោកជំទាវឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ ដែលរៀបចំសម្របសម្រួល ដោយអង្គការសង់ត្រាល់ នៅ គ.ជ.ប.ជ។ **១៣**.កិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធ Video Conference កែសម្រួលកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលាASEAN-ACT ស្តីពីការឆ្លើយតបដោយយុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មី សិក្ខាសាលាទី៦ ក្រោមប្រធានបទ វិធីសាស្រ្តរបស់ស្រ្តីក្នុងតួនាទីជាអ្នកសម្របសម្រួល និងងជួយកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការឆ្លើយតបការជួញដូរមនុស្ស" ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ដែលរៀបចំ និងសម្របសម្រួលដោយអង្គការASEAN-ACT។ **១៤**.សិក្ខាសាលាពិគ្រោះយោបល់ SOMTC លើផែនការការងារអាស៊ាន អូស្រ្តាលី ២០២០-២០២៣ **«ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស»** ដែលមានសមាជិកអាស៊ាន ទាំង១០ និងតំណាង ASEAN-ACT Australia, ASEAN-ACT Cambodia, ASEAN-ACT Philippine, ASEAN-ACT Vietnam និង Asia Foundation សរុបអ្នកចូលរួមចំនួន **៩២**នាក់ ដឹកនាំសម្របសម្រួលដោយប្រធានSOMTC Philippine។ **១៥**.ចូលរួមកម្មវិធីប្រជុំអនឡាញលើកិច្ចពិភាក្សារវាង ASEAN-ACT និងគ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្កើនកិច្ចសហការរវាង ស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព ការចូលរួមឆ្លើយតបទៅនឹងបញ្ហាប្រឈមតាមរយៈអង្គការដៃគូរបស់កម្មវិធី ASEAN-ACT។ ការពិភាក្សានេះ បានផ្តោតសំខាន់ទៅលើគម្រោងរយៈពេលមួយឆ្នាំ របស់ ASEAN-ACT ក្នុងការជំរុញការអនុវត្ត អនុសញ្ញា និងផែនការអាស៊ានស្តីពីការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស។ គម្រោងនេះនឹងចាប់ ផ្តើមពីខែកក្កដា ឆ្នាំ២០២១នេះតទៅ។

- **ក្រុមជំនួយកិច្ចការទេន្តរប្រវេសន៍** ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួម៖

**១**.កិច្ចប្រជុំជាមួយគណៈកម្មាធិការប្រឹក្សាគ្រោង ស្តីពីការពិនិត្យ និងរៀបចំផែនការ សកម្មភាពបន្ត សម្រាប់អនុវត្តគម្រោ ILI-Triangle ឆ្នាំ២០២០ ដោយរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ នៅសណ្ឋាគារភ្នំពេញ។ **២**.សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងប្រចាំឆ្នាំ គម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព និងធ្វើជាវាគ្មិន ក្រោមការដឹកនាំរបស់លោកជំទាវ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង នៅសាលាខេត្តកំពង់ស្ពឺ ក្រោមការឧបត្ថម្ភគាំទ្រដោយអង្គការឃែរអន្តរជាតិ ប្រចាំកម្ពុជា។ **៣**.បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការធ្វើផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ក្រោមការឧបត្ថមគាំទ្រមូលនីធិ UN-WOMEN អង្គការកម្ពុជាដើម្បីជួយស្តីមានវិបត្តិ CWCC នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។ **៤**.ពិនិត្យ និងកែតម្រូវខ្លឹមសារសេចក្តីព្រាង MOU រវាង គ.ជ.ប.ជ និងអង្គការ វីវើលអនលូស (WE WORLD ONLUS) ក្រោមការដឹកនាំដោយ **លោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **៥**.ពិនិត្យ និងកែសម្រួលខ្លឹមសារ "សេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ" របស់ក្រសួងសុខាភិបាល ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និង**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៦**. ពិនិត្យពិភាក្សា និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលក្នុងផែនការសកម្មភាពដំណាក់កាលទី២

នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ (២០១៧-២០៣០) ក្រោមការសម្របសម្រួលដោយ **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៧.**ពិភាក្សាផ្តល់ចម្លើយតបពាក់ព័ន្ធអំពើជួញដូរមនុស្សទាំង១២សំណួរ របស់អង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង (Global Initiative against Transnational Organized Crime) ដឹកនាំសម្របសម្រួលដោយ លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៅគ.ជ.ប.ជ។ **៨.**ពិនិត្យខ្លឹមសារពាក់ព័ន្ធអំពើជួញដូរមនុស្សដែលមាននៅក្នុងឯកសារពីរប្រភេទរបស់ក្រសួងមហាផ្ទៃបញ្ជូនមកដូចជា៖ ១-សេចក្តីសង្ខេតសន្និដ្ឋាននៃរបាយការណ៍ជាតិ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) និង២-ឆ្លើយតបនូវអនុសាសន៍នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ ២០១៩ ជុំទី៣ ក្នុងនាមលោកជំទាវជាអនុប្រធានក្រុមការងារទទួលបន្ទុកសិទ្ធិមនុស្សក្រសួងមហាផ្ទៃ ដើម្បីប្រមូលធាតុចូលឆ្លើយតបទៅវិញ។ **៩.**ពិនិត្យ ពិភាក្សា ផ្តល់ធាតុចូលបំពេញចម្លើយទៅក្នុងឯកសារទាំងពីរប្រភេទរបស់ក្រសួងមហាផ្ទៃ នូវចំណុចណាដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវឧត្តម សេនីយ៍ឯក អគ្គលេខាធិការ។ **១០.**បានបញ្ជូនលិខិតទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ ដើម្បីស្នើសុំជួបសម្ភាសន៍ជាមួយមន្ត្រីជំនាញ នាយកដ្ឋានទទួលបន្ទុកអធិការកិច្ចការងារ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនាយកដ្ឋានកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធអនឡាញ។ **១១.**បានបញ្ជូនលិខិតទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ ដើម្បីស្នើសុំចាត់អញ្ជើញ **ឯកឧត្តម ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ ដើម្បីចូលរួមកិច្ចប្រជុំសម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់តុមូល ស្តីពី គោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលប្រព្រឹត្តិទៅនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋានគជ។.ប.ជ.

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖**

-ឯកឧត្តម ឧត្តមសេនីយ៍ទោ **តែ សុថារេត** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួម៖

១.បានចូលរួមកិច្ចប្រជុំ ឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ ជាមួយអន្តរក្រសួង ស្ថាប័ន ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃអគារ ទ ។ ២.បានចូលរួមកិច្ចប្រជុំប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន(SOMTC) ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ កក្កិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំក្រសួងមហាផ្ទៃ។ ៣.បានចូលរួមកិច្ចប្រជុំ ក្រុមការងារបច្ចេកកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្យសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN-ACT កម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

-ឯកឧត្តម ឧត្តមសេនីយ៍ត្រី **តែ សុថារេត** អគ្គលេខាធិការរង និងលោក ឧត្តមសេនីយ៍ទោ **ប៊ុណ្ណ ចន្ថា** ប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ គ.ជ.ប.ជ បានចូលរួមកិច្ចប្រជុំ៖ ១-ពិនិត្យលើការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាស នីមួយៗ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវអគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទីប្រឹក្សា គ.ជ.ប.ជ ប្រធានក្រុមជំនួយកិច្ចការទាំង៦ ប្រធានលេខាធិការ ដ្ឋានរដ្ឋបាលសរុប និងមន្ត្រីពាក់ព័ន្ធផងដែរ។ **២-**អំពីសកម្មភាពការងារជាអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ក្រោមអធិបតីភាព

| | |
|---|---|
| | លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ ៣-បានចូលរួមកិច្ចប្រជុំបន្តស្តីពីសកម្មភាពការងារជាអាទិភាពសំខាន់ៗប្រចាំត្រីមាសទី១ និងទិសដៅត្រីមាសទី២ របស់អគ្គលេខាធិការដ្ឋាន**គ.ជ.ប.ជ** ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ៤- ស្តីពីផែនការសកម្មភាព ការងារ ជាអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ក្រោមអធិបតី ភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌** ឯកឧត្តម ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួមប្រជុំក្នុងពិធី៖<br>១.ប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន (SOMTC) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និង ជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំ "ទ"តូច ទីស្តីការក្រសួងមហាផ្ទៃ។ ២.ជាតំណាង **លោកជំទាវ ឧត្តមសេនីយ៍ឯកអគ្គលេខាធិការ**គ.ជ.ប.ជ ប្រជុំក្រុមការងារបច្ចេកទេសកម្មវិធី អាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT) ស្តីពីវឌ្ឍនភាពដែលកម្មវិធីនេះ សម្រេចបានក្នុងឆ្នាំ ២០២០ និងសេចក្តីព្រាងផែនការការងារឆ្នាំ ២០២១ ក្រោមអធិបតីភាព **ឯកឧត្តម ប៉ែន ពេជ្យសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN-ACT កម្ពុជា នៅសណ្ឋាគារ កាំបូឌីយ៉ាណា។ ៣.ប្រជុំជាមួយតំណាងក្រុមការងារជំនាញអន្តរក្រសួងទាំង០៦ ដើម្បីពិភាក្សាពីចំណុចសេសសល់ ដែលមាននៅក្នុងសេចក្តីព្រាង "SOP" ទ្វេភាគី កម្ពុជា-ថៃចុងក្រោយស្តីពី « កិច្ចសហប្រតិបត្តិពង្រឹងការអនុវត្តច្បាប់ រវាងកម្ពុជា-ថៃ ដោយផ្តោតសំខាន់ទៅលើឧត្តមប្រយោជន៍ និងសិទ្ធិមនុស្សពិតប្រាកដរបស់ពលករ និងពលរដ្ឋខ្មែរដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ» ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ។ ៤.ពិនិត្យផ្ទៀងផ្ទាត់ខ្លឹមសារ និងឃ្លោងឃ្លាSOP ស្តីពីនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាង គ.ជ.ប.ជ និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សរបស់ប្រទេសថៃជាភាសាខ្មែរម្តងទៀត មុននឹងនាំយកទៅសុំការណែនាំចង្អុលបង្ហាញពី **ឯកឧត្តម ឡាំ ជា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ តាមអនុសាសន៍ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ។ ៥.ពិនិត្យ កែសម្រួល និងផ្ទៀងផ្ទាត់ខ្លឹមសារ SOP រវាងភាសាខ្មែរ និងអង់គ្លេស តាមការចង្អុលបង្ហាញពី **ឯកឧត្តម ឡាំ ជា** មុននឹងដាក់ជូន **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ពិនិត្យ និងស្នើសុំ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្តល់សិទ្ធិប្រទានជូន **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ ចុះហត្ថលេខជំនួស។ ៦.ប្រជុំពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងរបាយការណ៍ជាតិឆ្នាំ២០២០ជាមួយថ្នាក់ដឹកនាំអគ្គលេខាដ្ឋាន គ.ជ.ប.ជ ដើម្បីពិនិត្យ កែសម្រួលទិន្នន័យ និងខ្លឹមសារមួយចំនួនទៀត ក្រោមអធិបតីភាព **លោកជំទាវ រដ្ឋលេខាធិការ ក្រសួង មហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ និង**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ**។ ៧.ចូលរួមពិនិត្យកម្រងសំណួរលក្ខណៈវិច្ឆ័យ នៃ សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ គ.រ.ប.ជ/គ.ខ.ប.ជ ប្រចាំឆ្នាំ ២០២០ " និងបន្តចូលរួម រៀបចំសេចក្តីជូនដំណឹងទៅ **ឯកឧត្តមអភិបាល** នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ស្តីពីការបញ្ចប់អនុស្សរណៈ យោគយល់រវាង **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** និង **សមាគមមូលនិធិ ឈាន ឆាយ ដើម្បីមនុស្សធម៌** ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសក្នុងចំណោមពលករទេសន្តប្រវេសន៍នៅប្រទេសថៃ ក្រោមការសម្របសម្រួលដោយ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ និង**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ ៨.ក្នុងពិធីប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន(SOMTC) ដើម្បីបានស្គាល់គ្នា និងស្វែងយល់ពីការងារពាក់ព័ន្ធមួយចំនួនដែលត្រូវធ្វើទៅថ្ងៃមុខ ជាមួយអគ្គលេខាធិការរងគ.ជ.ប.ជ (ឈ្មោះក្នុងសេចក្តីសម្រេចលេខ៤៧៣៩ សសរ ចុះថ្ងៃទី |

| | |
|---|---|
| | ១៦ ធ្នូ ២០២០ ) ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍** ប៉ោ ភក្តិ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំក្រសួងមហាផ្ទៃ។ ៩.ចូលរួមជាមួយ ឯកឧត្តម ឧត្តម.ត្រី **តែ សុថារ៉េត** អគ្គលេខាធិការរង គ.ជ.ប.ជ ជាតំណាង**លោកជំទាវឧត្តមសេនីយ៍ឯកអគ្គលេខាធិការគ.ជ.ប.ជ** នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស កម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT ) ស្តីពី វឌ្ឍនភាពដែលកម្មវិធីនេះសម្រេចបានក្នុងឆ្នាំ ២០២០ និងសេចក្តីព្រាងផែនការការងារឆ្នាំ ២០២១ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ សាលី** អគ្គនាយកកិច្ចការអយ្យការនិងព្រហ្មទ័ណ្ឌក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN-ACT និងលោកជំទាវ នាយឧត្តមសេនីយ៍ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។ **១០**.កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតំណាងក្រុមការងារជំនាញអន្តរក្រសួងទាំង០៦ ដើម្បីពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងរបាយការណ៍ជាតិឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ ២០២១ ដើម្បីបំពេញបន្ថែមនូវភាពខ្វះចន្លោះ មុននឹងធ្វើការជួបប្រជុំផ្សព្វផ្សាយជាផ្លូវការ ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ នៅសាលប្រជុំក្រសួងមហាផ្ទៃ។ **១១**.កិច្ចប្រជុំពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងរបាយការណ៍ជាតិឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ ២០២១ ជាមួយថ្នាក់ដឹកនាំអគ្គលេខាដ្ឋាន គ.ជ.ប.ជ និងក្រុមធ្វើរបាយការណ៍ ដើម្បីបំពេញទិន្នន័យនៅខ្វះចន្លោះដែលសាមីក្រសួងនីមួយៗស្នើសុំដាក់បញ្ចូលបន្ថែម ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ នៅសាលប្រជុំក្រសួងមហាផ្ទៃ។ **១២**.បានទំនាក់ទំនងទៅលោកស្រី **ស៊ុន សុខាលីដា** ប្រធាននាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោសនៃក្រសួងយុត្តិធម៌ ដើម្បីស្នើសុំបច្ចុប្បន្នភាពស្តីពី វឌ្ឍនភាពការចុះអនុសញ្ញា សន្ធិសញ្ញា បត្យាប័ន ដែលក្រសួងយុត្តិធម៌បានធ្វើជាមួយប្រទេសពាក់ព័ន្ធ ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាលទ្ធផលបានទទួលហើយ។ **១៣**.ចូលរួមប្រជុំដើម្បីពិភាក្សាពីលទ្ធផលការងារដែលអនុវត្តកន្លងមករយៈពេល ០៦ ឆ្នាំ(២០១៥-២០២១) តាមវិស័យរៀងខ្លួន ឆ្លើយតបសំណើអង្គការទេសន្តរប្រវេសន៍អន្តរជាតិ តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និង**លោកជំទាវ អគ្គលេខាធិការ**។**១៤**.ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ដើម្បីពិភាក្សាពីការជំរុញការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ដែលក្នុងនោះគ.ជ.ប.ជ មានទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១ ចំនួន០៦ចំណុចធំ តម្រូវឱ្យក្រុមជំនួយកិច្ចការទាំង០៦ ពិនិត្យមើលផែនការធ្វើសកម្មភាពរបស់ខ្លួន ទាំង០៤ត្រីមាសនិងលើកទិសដៅការងារច្បាស់លាស់។ **១៥**.ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ស្តីពីការជំរុញទិសដៅអនុវត្តការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ដែលបានដាក់ចេញ០២ចំណុចគឺ សកម្មភាពការងារអាទិភាពសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ និងរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវរដ្ឋលេខាធិការ**ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និង**លោកជំទាវ អគ្គលេខាធិការ**គ.ជ.ប.ជ។ **១៦**.បានស្រាវជ្រាវ និងដកស្រង់សកម្មភាព របស់ក្រុមការងារជំនាញកិច្ចការយុត្តិធម៌អន្តរក្រសួង ចេញពីផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ(២០២៣-២០១៩) ដើម្បីបង្កើតតារាងផែនការអនុសកម្មភាពឆ្នាំ២០២១ របស់ ក្រុមជំនួយកិច្ចការយុត្តិធម៌។ **១៧**.បានចូលរួមប្រជុំដើម្បីពិភាក្សាការងារជាមួយ **ឯកឧត្តម ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងឯកឧត្តម **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីត្រៀមផ្តល់ធាតុចូលក្នុងកិច្ចប្រជុំពិគ្រោះ គុម្ពលមួយ «**ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស**» ដែលគ្រោងនឹងធ្វើនៅពាក់កណ្តាលខែ មិថុនាខាងមុខ ទៅតាមការស្នើសុំរបស់អង្គការកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស( ASEAN-ACT) ឱ្យខាងគ.ជ.ប.ជ ជួយសម្របសម្រួល។ **១៨**.បានទំនាក់ទំនងទៅ |

<table>
<tr><td></td><td>ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន នៃក្រសួងយុត្តិធម៌ ទទួលបន្ទុកធ្វើរបាយការណ៍ផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ដើម្បីស្នើសុំទិន្នន័យផ្តន្ទាទោសទាំង៣ដំណាក់កាល នៃនីតិវិធីតុលាការក្នុងត្រីមាសទី១ឆ្នាំ២០២១។</td></tr>
<tr><td colspan="2">អន្តរក្រសួង ស្ថាប័ន ដឹកនាំសម្របសម្រួល ចំនួន ៥៦លើក អ្នកចូលរួមសរុបចំនួន ៦២៣នាក់ (ស្រី ២៦៣នាក់)</td></tr>
<tr><td>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា</td><td>- ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញចុះពិនិត្យទីតាំងសំណង់អគារមជ្ឈមណ្ឌលស្តារយុវនីតិសម្បទា នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។<br>- ក្រុមការងារអន្តរក្រសួង (ក្រុមការងាការពារជនរងគ្រោះ) ដែលដឹកនាំដោយ ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ចុះពិនិត្យការគ្រប់គ្រងស្ថានភាពការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលវិលត្រឡប់តាមច្រកព្រំដែនអន្តរជាតិ និងច្រកតំបន់នៃ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តស្វាយរៀង បានរៀបចំកិច្ចប្រជុំ ត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។<br>- បានចូលរួមកិច្ចប្រជុំ ស្តីពីគ្រោងកំណត់អត្តសញ្ញាណ និងសមាហរណកម្មជនរងគ្រោះ រវាងអង្គការរតនៈអន្តរជាតិ ជាមួយមជ្ឈមណ្ឌលប៉ោយប៉ែត នៅខេត្តបន្ទាយមានជ័យ។<br>- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុសាសន៍នៃវេទិកាអាស៊ាន ស្តីពីទេសន្តរប្រវេសន៍ការងារលើកទី១៣ នៅសណ្ឋាគារភ្នំពេញ។<br>- បានសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ បើកវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ លើការគ្រប់គ្រងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។<br>- ចូលរួមកិច្ចប្រជុំជាមួយ គ.ជ.ប.ជ ចំនួន ០៣លើក៖ ១.កិច្ចប្រជុំឆ្លងបាយការណ៍ឆ្នាំ២០២០។ ២-៣. កិច្ចប្រជុំត្រៀម និងកិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃ ស្តីពី ស្តង់ដារនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់។<br>- ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ដែលរៀបចំដោយក្រសួងយុត្តិធម៌ និងASEAN-ACT ចំនួន០១លើក។<br>- ចូលរួមវគ្គបណ្តុះបណ្តាលចំនួន០៣លើក៖ ១.គ្រូបង្គោលស្តីពី ផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការ CWCC ។ ២.ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបចំដោយអង្គការតំណក់ទឹកប៉ោយប៉ែត(មណ្ឌលសំចតប៉ោយប៉ែត)។ ៣.ស្តីពីការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់នៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីគ្រប់គ្រងការវិលត្រឡប់មកវិញនៃជនទេសន្តរប្រវេសន៍ នៅខេត្តសៀមរាប។<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ លើកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលកម្លាំងសេវាសង្គម ដោយផ្តោតលើកិច្ចការពារកុមារ តាមវីដេអូរ Zoom។<br>- ក្រុមការងារការិយាល័យប្រឆាំងការជួញដូរមនុស្ស បានទទួលជនរងគ្រោះដែលមាតុភូមិនិវត្តន៍ពីក្រៅប្រទេសនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ០៦លើក និងនៅច្រកព្រំដែនអន្តរជាតិបាវិត ម៉ុកបាយ ០១លើក។</td></tr>
</table>

| | |
|---|---|
| | - ក្រុមការងារនាយកដ្ឋាន បានធ្វើសមាហរណកម្ម និងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើចត្តាឡីស័កចំនួន១៤នាក់ ត្រឡប់ទៅសហគមន៍វិញ ដែលមានទីតាំងនៅ២៥រាជធានី ខេត្ត ដោយមានការចូលរួមគាំទ្រពីអង្គការដៃគូ។ |
| ក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ | - បានចាត់មន្ត្រីជំនាញ១០រូប និងមន្ត្រីជាន់ខ្ពស់១រូប ចូលរួមកិច្ចប្រជុំ៖ ១.ត្រៀមសម្រាប់ការប្រជុំទ្វេភាគីរវាងគ.ជ.ប.ជ និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស នៃរដ្ឋាភិបាលថៃ ស្តីពីស្តង់ដារនៃនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការការអនុវត្តច្បាប់។ ២."Asia-pacific Regional Review of Implementation of Global Compact for Safe, Orderly and Regular Migration"។ ៣-ពិភាក្សាការងារជាមួយគណៈប្រតិភូអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO)។ ៤-ជាមួយគណៈកម្មការអាស៊ានស្តីពីការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍លើកទី១៤ (14th ACMW) តាមរយៈប្រព័ន្ធវីដេអូ។ ៥-ពិភាក្សាត្រៀមឆ្លើយតបនឹងកម្រងសំណួរនៃគម្រោងស្រាវជ្រាវ "Integrating Human Mobility into Cross-Border Trade Facilitation, and Border Management in the Greater Mekong Subregion" របស់អង្គការជាតិខាងការងារ (IOM)។<br>- បានចាត់មន្ត្រី១៧រូប ចូលរួមសិក្ខាសាលា ចំនួន ០៦លើក៖ ១.សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីរបាយការណ៍ សូចនាករ អភិបាលកិច្ចទេសន្តរប្រវេសន៍ និងកតិកាសញ្ញាពិភពលោកសម្រាប់ ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ ២.សិក្ខាសាលាពិគ្រោះយោបល់ និងកែសម្រួលលើ "សៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស" លើកទី២។ ៣.សិក្ខាសាលាស្តីពីការណែនាំសៀវភៅសិក្សាភាសាជប៉ុនថ្មី អ៊ីរ៉ូដូរី សម្រាប់សិក្ខាកាមដែលមានបំណងចង់ទៅធ្វើការនៅប្រទេសជប៉ុន។ ៤.សិក្ខាសាលាពិគ្រោះយោបល់ និងផ្តល់ធាតុចូលក្នុងកម្រងព័ត៌មានជាតិលើកទី២ ស្តីពីសុខភាព និងសុវត្ថិភាពការងារ នៃព្រះរាជាណាចក្រកម្ពុជា។ ៥.សិក្ខាសាលាភាពជាដៃគូក្នុងតំបន់អាស៊ីតាមប្រព័ន្ធអនឡាញ ស្តីពីការបាត់ខ្លួន ជនទេសន្តរប្រវេសន៍ អំឡុងពេលទេសន្តរប្រវេសន៍អន្តរជាតិ។ ៦.សិក្ខាសាលាស្តីពីក្របខណ្ឌត្រួតពិនិត្យតាមដានផែនទីបង្ហាញផ្លូវអាស៊ាន សម្រាប់ការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។ ៧- ចាត់មន្ត្រី៧រូប ចូលរួមវេទិកាផ្សព្វផ្សាយ និងប្រកាសជាផ្លូវការនូវរបាយការណ៍សិក្ខសាលាស្តីពី ផលិតភាពការងារនៅក្នុងអាស៊ានតាមប្រព័ន្ធអនឡាញ។ ៨-បានចាត់មន្ត្រីចំនួន ៨រូប ចូលរួមសិក្ខាសាលាពិគ្រោះយោបល់តុមូលស្តីពីគោលការណ៍តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប បានចូលរួមជាមួយក្រុមការងារលេខាធិការដ្ឋាននៃ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្របសម្រួលទទួលពីអាជ្ញាធរខេត្ត និងដឹកជញ្ជូនបងប្អូនពលករពីខេត្តបន្ទាយមានជ័យសរុបចំនួន ៣២៤នាក់ (ស្រី ១៣៨នាក់) ទៅមណ្ឌលចត្តាឡីស័ក គរុកោសល្យខេត្តសៀមរាប។ |
| ក្រសួងអប់រំ យុវជន និងកីឡា | -បានចូលរួមកិច្ចប្រជុំ៖ (១)ឆ្លងរបាយការណ៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ។ (២)ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ។ (៣)ក្នុងកម្មវិធីស្តីពី "យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធ័រណិត និងលើកកម្ពស់សីលធម៌ដើម្បីសុវត្ថិភាពសង្គម" នៅវិទ្យាស្ថានជាតិអប់រំ។ (៤)ជួបសម្តាសន៍ជាមួយក្រុមហ៊ុនរ៉ាកឹត |

| | |
|---|---|
| | អេសៀ(Rapid Asia) ដែលជាក្រុមហ៊ុនឯករាជ្យផ្តល់សេវាកម្មប្រឹក្សាការងារ ធ្វើការវិភាគស្តីពី ការការពារជនរងគ្រោះពីអំពើជួញដូរក្នុងតំបន់អាស៊ាន តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងអប់រំ មានអ្នកចូលរួមចំនួន ២២៦នាក់(ស្រី ១២៣នាក់)។ |
| **ក្រសួងកិច្ចការនារី** | - បានចូលរួមពិនិត្យ និងកែសម្រួលលើសំណៅបកប្រែឯកសារជាភាសាអង់គ្លេស មកជាភាសាខ្មែរ របស់គណៈកម្មការអាស៊ាន(ACWC) ដើម្បីលើកកម្ពស់ការពារសិទ្ធិស្ត្រី និង កុមារ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់នៃគណៈកម្មការអាស៊ានទទួលបន្ទុក សម្រាប់ឆ្លើយតបតម្រូវការនៃជនរងគ្រោះដោយអំពើជួញដូរមនុស្ស។<br>- បានចូលរួមបង្កើតគណៈកម្មាការប្រឹក្សាយោបល់ ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៃកម្មវីធីក្នុងតំបន់អាស៊ាន ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>- ក្រុមការងាររបស់នាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី បានធ្វើការបញ្ជូន និងសម្របសម្រួលដល់គ្រួសាររបស់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សនៅប្រទេសចិន ចំនួន ០៣ករណី ដោយបានដាក់ពាក្យប្តឹងនៅអគ្គស្នងការនគរបាលជាតិ និងសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងបានផ្តល់ប្រឹក្សាដោយផ្ទាល់ដល់ស្ត្រីរងគ្រោះនៅចិនតាម Wechat , Telegram , Fecebook រហូតបានធ្វើមាតុភូមិនិវត្តន៍មកដល់ប្រទេសកម្ពុជា ដោយសុវត្ថិភាព ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ |
| **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** | - ចាត់បញ្ជូនមន្ត្រីនគរបាល ចំនួន០៦រូប ចូលរួមវគ្គបណ្តុះបណ្តាល(BCAMP)លើកទី២៥ អន្តោប្រវេសន៍ឆ្ពោះទៅកាន់ឆ្នាំ២០៣០។<br>- ប្រជុំកែសម្រួលខ្លឹមសារសេចក្តីព្រាងច្បាប់ស្តីពី ច្បាប់អន្តោប្រវេសន៍ថ្មី នៅសាលប្រជុំអគ្គនាយកដ្ឋានអន្តោប្រវេសន៍។<br>- ប្រជុំស្តីពីសកម្មភាព វិធានការអនុវត្តក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនខុសច្បាប់ និងការលួចលាក់នាំជនបរទេសចេញពីតំបន់បិទខ្ទប់។ |
| **អង្គការរេតនៈអ៊ីនធើណេសិនណល** | បានចូលរួមកិច្ចប្រជុំ៖ ១-តុមូល ស្តីពីប្រព័ន្ធតុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ និងរៀបចំឡើងដោយអង្គការ ASEAN-ACT ។ ២-ជាមួយក្រសួង ស.អ.យ ដែលមានផែនការរួមគ្នា នៃនិតិវិធីបទដ្ឋាន ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងកម្ពុជា ថៃ ឆ្នាំ២០១៩-២០២១។ ៣-ជាមួយអង្គការដៃគូរ ដែលធ្វើការងារប្រឆាំងការជួញដូរមនុស្ស ដើម្បីបង្ហាញពីបញ្ហាប្រឈម និងទិសដៅអនុវត្តបន្តក្នុងឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលរៀបចំឡើងដោយ គ.ជ.ប.ជ និងអង្គការ USAID។ ៤-ស្តីពីកិច្ចសហការរវាងមណ្ឌលសំចតប៉ោយប៉េត ដើម្បីធ្វើការពិភាក្សាអំពីករណី ដែលបានកំណត់អត្តសញ្ញាណ និងការរៀបចំផែនការសកម្មភាពចុះកំណត់អត្តសញ្ញាណជនរងគ្រោះជាផ្លូវការ។ ៥-បានចូលរួមសិក្ខាសាលា ពិគ្រោះយោបល់ និងកែសម្រួលលើសៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សលើកទី២ ដែលមានអ្នកចូលពីបណ្តាក្រសួង និងអង្គការដៃគូពាក់ព័ន្ធ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៣០លើក អ្នកចូលរួមសរុបចំនួន ៣.១៩៩នាក់ (ស្រី ៩៦៩នាក់)** | |

| | |
|---|---|
| ខេត្តកណ្តាល | - គ.ខ.ប.ជ និងលេខាធិការដ្ឋាន ដឹកនាំដោយលោកជំទាវ **ហ៊ុន កុសនី** បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆ្នាំ២០២១ តាមប្រព័ន្ធតេឡេក្រាម ចំនួន**០២**លើក អ្នកចូលរួម**៦៧**នាក់ ស្រី**៤៣**នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែ និងប្រជុំពង្រឹងតួនាទី ភារកិច្ច ចំនួន**២៤**លើក អ្នកចូលរួមចំនួន **៦៩៣**នាក់ ស្រី**៣៧៣**នាក់។<br>- ក្រុមការងារលេខាធិការដ្ឋានថ្នាក់ខេត្ត និងថ្នាក់ស្រុក បានចូលរួមកិច្ចប្រជុំពិភាក្សាតាមតេឡេក្រាម ជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) ០១លើក ស្តីពីការលើកកម្ពស់ការរាយការណ៍ករណីសង្ស័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។<br>- បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែមិថុនា ត្រីមាសទី២ និងឆមាសទី១ និង លើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២១ ចំនួន**០១**លើក អ្នកចូលរួមចំនួន**៥៦**នាក់ ស្រី**២៨**នាក់។<br>- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការកិច្ចការពារកុមារថ្នាក់ខេត្ត ផ្តោតលើការថែទាំជំនួស និងអំពើហិង្សាលើកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន**៥៧**នាក់ ស្រី **២៥**នាក់។ |
| ខេត្តសៀមរាប | - បានដឹកនាំកិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ចំនួន១៤លើក អ្នកចូលរួមចំនួន៣៥៩នាក់ ស្រី១១៨នាក់។<br>- សហការជាមួយរដ្ឋបាលខេត្តបន្ទាយមានជ័យ ស្តីពីការផ្ទេរពលករខេត្តសៀមរាប មកពីប្រទេសថៃ ពីមណ្ឌលចត្តាឡីស័កខេត្តបន្ទាយមានជ័យ មកធ្វើចត្តាឡីស័កបន្តនៅខេត្តសៀមរាប ០១លើក។<br>- បានរៀបចំកិច្ចប្រជុំ ស្តីពីការត្រៀមប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន**០១**លើក អ្នកចូលរួមចំនួន**៨០**នាក់ ស្រី**៣៩**នាក់។<br>- បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន១៨០នាក់ ស្រី៥៩នាក់។<br>- បានរៀបចំកិច្ចប្រជុំនៅថ្នាក់ខេត្តប្រចាំខែ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០៣លើក អ្នកចូលរួមចំនួន១២៤នាក់ ស្រី៧២នាក់។<br>- បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- បានអមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អង្គការ UNFPA, UNICEF, WHO និងអង្គការ IOM ចុះពិនិត្យ និងវាយតម្លៃបញ្ចប់គម្រោងលើកកម្ពស់ជីវភាពពលករចំណាកស្រុកពីក្រៅប្រទេស ចំនួន០១លើក នៅស្រុកសូទ្រនិគម ស្រុកក្រឡាញ់ និងស្រុកពួក ខេត្តសៀមរាប។ |

| | |
|---|---|
| | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសលើកទី១ ចំនួន០១លើក អ្នកចូលរួមចំនួន **៦៣**នាក់ ស្រី**៣៧**នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា ជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **០៥**លើក។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋានខេត្ត ប្រជុំពង្រឹងសមត្ថភាពដល់មន្ត្រីយន្តការនៃ គ.ខ.ប.ជ ចំនួន**៤១**លើក អ្នកចូលរួមចំនួន**១.០៨៤**នាក់។<br>- បានចូលរួមសិក្ខាសាលាស្តីពី គោលការណ៍ណែនាំក្នុងការដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍ និងគោលនយោបាយទេសន្តរប្រវេសន៍ការងារប្រទេសកម្ពុជា ២០១៩-២០២៣ នៅខេត្តសៀមរាប អ្នកចូលរួម ៤៥នាក់ ស្រី០៥នាក់។<br>- គ.ខ.ប.ជ ខេត្ត ប្រជុំប្រចាំខែ ចំនួន០១លើក អ្នកចូលរួមចំនួន ៣១នាក់ ស្រី២២នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០៣លើក ស្តីពីចំណេះដឹងក្នុងការគ្រប់គ្រងការងារទេសន្តរប្រវេសន៍ ការដោះស្រាយវិវាទ ព្រមទាំងការផ្តល់សេវាគាំទ្រដល់ពលករ ដែលរៀបចំដោយអង្គការ OLO, Legal Aids និង LSCW អ្នកចូលរួមចំនួន**១១០**នាក់ ស្រី**៤៦**នាក់។ |
| **ខេត្តត្បូងឃ្មុំ** | - លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំពិភាក្សាលើការងារ ពង្រឹងតួនាទី ភារកិច្ច រចនាសម្ព័ន្ធ របៀបរបបធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| **ខេត្តក្រចេះ** | **មន្ទីរអប់រំ យុវជន និងកីឡាខេត្តៈ** ១.បានចុះផ្សព្វផ្សាយពីរបៀបធ្វើទិវាទប់ស្កាត់ការជួញដូរមនុស្សបានចំនួន**០១**ស្រុក នៅស្រុកចិត្របុរី តាមសាលាបឋមសិក្សា ១០៥ និងបឋមសិក្សាស្រះ ដែលមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចូលរួមសរុបចំនួន **២៧**នាក់ ស្រី**១៦**នាក់។ **២.**មន្ទីរបានរៀបចំឲ្យមានគណៈកម្មការទប់ស្កាត់ការជួញដូរមនុស្ស ពីថ្នាក់មន្ទីរអប់រំរហូតដល់ថ្នាក់ស្រុក និងសាលារៀន។ |
| **ខេត្តកំពង់ឆ្នាំង** | - លោកជំទាវប្រធានលេខាធិការដ្ឋានបានដឹកនាំកិច្ចប្រជុំក្រុមការងារគ.ខ.ប.ជ តាមរយៈប្រព័ន្ធវីដេអូរ Zoom ចំនួន **០១**លើក។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ជាមួយនឹងមន្ត្រីថ្នាក់ក្រុង ស្រុក ចំនួន០៥លើក ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការងាររដ្ឋបាលផ្សេងៗ អ្នកចូលរួមចំនួន**១៣៩**នាក់ ស្រី**៤៥**នាក់។ |
| **ខេត្តកំពង់ធំ** | - ឯកឧត្តមអភិបាលខេត្ត បានដឹកនាំក្រុមការងារគ.ខ.ប.ជ ខេត្ត ចុះសួរសុខទុក្ខពលករវិលត្រឡប់ពីប្រទេសថៃ ដែលត្រូវដាក់ក្នុងមណ្ឌលចត្តាឡីស័កតាមបណ្តាក្រុង ស្រុកទាំង៩ ក្នុងខេត្ត ចំនួន០២លើក និងបានចែកសម្ភារប្រើប្រាស់ ថវិកាមួយចំនួនផងដែរ។<br>- លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមទទួលពលករវិលត្រឡប់ពីប្រទេសថៃ ០១លើក។ |
| **ខេត្តព្រៃវែង** | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ |
| **ខេត្តកោះកុង** | - លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត ប្រជុំក្រុមការងារថ្នាក់ក្រុង-ស្រុក ចំនួន០២លើក អ្នកចូលរួម ៥១នាក់ ស្រី១៦នាក់។ |

| | |
|---|---|
| | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| **ខេត្តកំពង់ស្ពឺ** | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| **ខេត្តបន្ទាយមានជ័យ** | - ឯកឧត្តមអភិបាលខេត្ត បានចុះសំណេះសំណាលជាមួយប្រជាពលករដែលកំពុងធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កកងវ៉ា ០១លើក។<br>- លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចុះពិនិត្យមើលស្ថានភាពប្រជាពលករដែលបានវិលត្រឡប់ពីប្រទេសថៃ និងកំពុងធ្វើចត្តាឡីស័កនៅក្នុងក្រុងសេរីសោភ័ណ ចំនួន០៩លើក។ |
| **ខេត្តឧត្តរមានជ័យ** | - រៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន១២នាក់ ស្រី០៩នាក់។<br>- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន២១នាក់ ស្រី១៦នាក់។<br>- បានចូលរួមកិច្ចប្រជុំពិភាក្សាលើការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការ ស្តីពីការការពារក្តីស្ត្រី និងក្មេងស្រី រងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅទីស្តីការក្រសួងកិច្ចការនារី។ |
| **ខេត្តបាត់ដំបង** | បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការបង្រ្កាបបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទនៅភូមិសាស្ត្រ ស្រុកកំរៀង ស្រុកភ្នំព្រឹក ស្រុកសំពៅលូន និងស្រុកសំឡូត ដើម្បីពង្រឹងសមត្ថភាពការងាររបស់មន្ត្រីដែលមានតួនាទីភារកិច្ចនៅព្រំដែន។ |
| **ខេត្តមណ្ឌលគិរី** | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- មន្ទីរកិច្ចនារី បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី សកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច ០១លើក។ |